នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨ សភាសហរដ្ឋអាមេរិក បានទទួលស្គាល់ច្បាប់យុត្តិធម៌ស្តីពីអំពើប្រល័យពូជសាសន៍របស់ ប្រជាជនកម្ពុជាដែលសេចក្តីថ្លែងការណ៍បង្ហាញថា «គោលការណ៍របស់សហរដ្ឋអាមេរិកដើម្បីគាំទ្រក្នុងការនាំយកសមាជិកខ្មែរក្រហម មកកាត់ទោសចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តក្នុងប្រទេសកម្ពុជានៅអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩» ។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលត្រូវបានបង្កើតឡើងជាផ្លូវការក្នុងបេសកកម្មយុត្តិធម៌អំពើប្រល័យពូជសាសន៍កម្ពុជារយៈពេលពីរឆ្នាំ ក្រោមការជួយឧបត្ថម្ភរបស់កម្មវិធីប្រល័យពូជសាសន៍កម្ពុជារបស់សាកលវិទ្យាល័យយែល ។ (ការិយាល័យស៊ើបអង្កេតអំពើប្រល័យពូជសាសន៍កម្ពុជា អឹអេភី ឬ ស៊ីជីអាយ, ការិយាយកិច្ចការអាស៊ី-ប៉ាស៊ីហ្វិក, ក្រសួងការ-បរទេសអាមេរិក និងឯកសារដែលបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ។

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាបានលើកលែងទោសឲ្យ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការលើកលែងទោសនេះគិតតាំងពីពេលដែល អៀង សារី ត្រូវបានផ្តន្ទាទោស នៅក្នុងឆ្នាំ១៩៧៩ សូមបញ្ជាក់ថា អៀង សារី ត្រូវបានតុលាការប្រជាជនកាត់ទោសប្រហារជីវិតនិងរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ ។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ គណៈកម្មាធិការអាមេរិក ស្តីអំពីសិទ្ធិមនុស្សបានអនុម័តសម្រេចក្នុងមាត្រា៨៩ ឆ្នាំ១៩៩៧ ។ សេចក្តីសម្រេចនោះបានស្នើសុំអគ្គលេខាធិការតាមរយៈតំណាងរបស់លោក ដើម្បីពិនិត្យទៅលើសំណើសុំការជួយឧបត្ថម្ភក្នុងការ ឆ្លើយតបទៅនឹងអំពើហិង្សាពីអតីតកាលរបស់ប្រជាជនកម្ពុជា និងច្បាប់អន្តរជាតិ ។

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៧ សម្តេចព្រះនរោត្តម សីហនុ បានមានព្រះបន្ទូលថាព្រះអង្គត្រូវបានវិច្ឆ័យទោសជាមួយ មេដឹកនាំខ្មែរក្រហមដើម្បីឆ្លើយបំភ្លឺទៅពួកអ្នករិះគន់ព្រះអង្គដែលបានអះអាងថា ព្រះអង្គត្រូវទទួលខុសត្រូវមួយផ្នែកចំពោះអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងក្នុងរវាងឆ្នាំ១៩៧៥ដល់ ឆ្នាំ១៩៧៨ ។

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានប្រកាសថា សុន សេន និងប្រពន្ធរបស់គាត់ឈ្មោះ យុន យ៉ាត ត្រូវបានចាប់ខ្លួនពីបទចារកម្មនិងសកម្មភាពក្បត់ប្រឆាំងនឹងចលនាខ្មែរក្រហម ។ ខ្មែរក្រហមបានចោទប្រកាន់អ្នកទាំងពីរថាជាចារកិច្ចរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២និងរដ្ឋាភិបាលរបស់វៀតណាម ។

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន និងភរិយា ឈ្មោះ យុន យ៉ាត និងសាច់ញាតិ៨នាក់ទៀតត្រូវបានសម្លាប់យ៉ាងវេទ្ធាល ។

នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ «ក្នុងការនាំអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសចំពោះអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ»ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ សំណើសុំជំនួយមានអត្ថន័យទាំងស្រុងដូចខាងក្រោម ៖

ជម្រាបជូនលោកអគ្គលេខាធិការ ៖

តាងនាមឲ្យប្រជាជន និងរាជរដ្ឋាភិបាលកម្ពុជា យើងខ្ញុំសរសេរជូនលោក ដើម្បីស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍ អន្តរជាតិក្នុងការនាំមេដឹកនាំដែលខុសត្រូវខ្ពស់បំផុតមកកាត់ទោសពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

នៅខែមេសា ឆ្នាំ១៩៩៧ សេចក្តីសម្រេចចំពោះកម្ពុជារបស់បេសកកម្មអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្សបានស្នើថា «លោកអគ្គលេខាធិការតាមរយៈតំណាងពិសេសរបស់លោក ក្នុងកិច្ចប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្ស ដើម្បីពិនិត្យរាល់សំណើរបស់កម្ពុជាចំពោះជំនួយក្នុងការឆ្លើយតបទៅនឹងអំពើ ហិង្សាដ៏ធ្ងន់ធ្ងរពីអតីតកាលរបស់ប្រជាជនកម្ពុជានិងច្បាប់អន្តរជាតិក្នុងន័យនាំមកនូវការផ្សះផ្សាជាតិ លទ្ធិប្រជាធិបតេយ្យពេញលេញ និងការបកស្រាយពីបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ» ។

ប្រទេសកម្ពុជាពុំមានធនធាននិងអ្នកជំនាញ ដើម្បីរៀបចំដំណើរការដ៏សំខាន់នេះបានត្រឹមត្រូវតាមនីតិវិធីទេ ។ ដូច្នេះយើងជឿថា ដំណើរតាមនីតិវិធីគឺជាការចាំបាច់ត្រូវការជំនួយពីអង្គការសហប្រជាជាតិ ។ យើងដឹងថា ជាការខិតខំប្រឹងប្រែងស្រដៀងគ្នានឹងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសរ៉្វាន់ដា និងអតីតយូហ្គោស្លាវី ហើយដែលថា ជំនួយប្រហាក់ប្រហែល គ្នានេះត្រូវបានផ្តល់មកឲ្យកម្ពុជា ។

សូមលោកអគ្គលេខាធិការទទួលនូវការគោរពរាប់អានដ៏ខ្ពស់អំពីយើងខ្ញុំ ។

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តសម្រេចលេខ៥២,១៣៥ ដែលបង្គាប់ឲ្យអគ្គលេខាធិការត្រួតពិនិត្យសំណើរបស់អាជ្ញាធរកម្ពុជាចំពោះជំនួយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាពីអតីតកាលរបស់ប្រជាជនកម្ពុជា និងច្បាប់ ។ ខាងក្រោមនេះជាផ្នែកខ្លះនៃសេចក្តីសម្រេច ៖

ក្នុងឆន្ទៈថា ប្រវត្តិសាស្ត្រដ៏ខ្មៅខ្មាំរបស់ប្រទេសកម្ពុជាតម្រូវឲ្យមានការដាក់សម្ពាធដើម្បីធានាឲ្យបាននូវសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដើម្បីកុំឲ្យរបបនយោបាយនិងការអនុវត្តនៃអតីតកាលវិលត្រឡប់មកម្តងទៀតដូចច្បាប់ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ។

តាមការអធិប្បាយព្រមព្រៀងរបស់តំណាងពិសេសថ្លែងថា អំពើហិង្សារំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជាក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ គឺបង្កឡើងដោយខ្មែរក្រហមនិងថា បទឧក្រិដ្ឋរបស់មេដឹកនាំទាំងនោះ ដែលរាប់បញ្ចូលទាំងការសម្លាប់អ្នកទោស ហើយដែលបានបន្តមកដល់បច្ចុប្បន្ននិងតាមកត់សម្គាល់ ដោយការព្រួយបារម្ភថា គ្មានមេដឹកនាំណាម្នាក់ត្រូវបាននាំមកកាត់-ទោសចំពោះបទឧក្រិដ្ឋទាំងនោះឡើយ ។

លោកអគ្គលេខាធិការស្នើសុំឲ្យពិនិត្យលើសំណើរបស់អាជ្ញាធរ កម្ពុជាសម្រាប់ជំនួយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាដ៏ធ្ងន់ធ្ងររបស់ប្រជាជនកម្ពុជានិងច្បាប់អន្តរជាតិដែលរួមទាំងលទ្ធភាពនៃការកំណត់ពេលដោយអគ្គលេខាធិការរបស់ក្រុមអ្នកជំនាញមួយក្រុមដើម្បីវាយតម្លៃលើភ័ស្តុតាងដែលមាននិងដាក់សម្ពាធបន្ថែមដើម្បីជាមធ្យោបាយក្នុងការនាំមកនូវការផ្សះផ្សាជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហាទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ។

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពត បានស្លាប់ដោយសារជំងឺគាំងបេះដូង នៅក្នុងជន្មាយុ៧៣ឆ្នាំ នៅស្រុកអន្លង់វែង ក្បែរព្រំដែនថៃ ជាកន្លែងដែល ប៉ុល ពត ត្រូវបានឃុំឃាំងបន្ទាប់ពី ត្រូវកាត់ទោសនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧ ។

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៨ អនុលោមតាមមហាសន្និបាតសម្រេចលេខ52/135 ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ មហាសន្និបាតបានតែងតាំងក្រុមអ្នកជំនាញការបីរូបមកកម្ពុជាដើម្បីវាយតម្លៃលើភ័ស្តុតាងដែលមាននិងដើម្បីពិនិត្យជម្រើសក្នុងការនាំ យកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសនៅចំពោះមុខយុត្តាធិការជាតិនិងអន្តរជាតិ ។

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨ លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ បានបង្កើតក្រុមអ្នកជំនាញមួយក្រុមដោយ មានលោក នីនៀន ស្ទីហ្វិន មកពីប្រទេសអូស្ត្រាលី ជាប្រធាន,

ចៅក្រម រ៉ាសូមម័រ ឡាឡាស មកពីកោះម៉ូរីស៊ីស និងសាស្ត្រាចារ្យ ស៊ីរិន រ៉ាន័រ មកពីសហរដ្ឋអាមេរិក ដើម្បីដំណើរការលទ្ធភាពនៃការនាំខ្លួនមេដឹកនាំមកកាត់ទោស ។

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបាន ប្រកាសពីការចុះចូលជាមួយរដ្ឋាភិបាលរបស់មេដឹកនាំជាន់ខ្ពស់ពីររូប គឺ នួន ជា និង ខៀវ សំផន ។

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ប្រជាជនកម្ពុជាចំនួន២៣គ្រួសារបានបំពេញពាក្យបណ្ដឹងនៅក្នុងតុលាការប៉ែលហ្សិកប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម នួន ជា, ខៀវ សំផន និង អៀង សារី ដោយចោទប្រកាន់ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ដើមបណ្ដឹងត្រូវបានលើកទឹកចិត្តឲ្យធ្វើការចោទប្រកាន់ បន្ទាប់ពីជនរងគ្រោះ នៅក្រោមអំណាចផ្ដាច់ការរបស់ ពីណូជេ បានទទួលជោគជ័យក្នុងការចេញដីកាចាប់ខ្លួនជាអន្តរជាតិចំពោះអតីតអ្នកកាន់លទ្ធិផ្ដាច់ការរូបនេះ ។

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចិនបានសម្ដែងការប្រឆាំងនឹងការបង្កើតតុលាការអន្តរជាតិមួយសម្រាប់អតីតមេដឹកនាំខ្មែរក្រហម ដោយនិយាយថា វាគឺជាកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ។ ថាង ជាស៊ាន់ (Tang Jia Xuan) មន្ត្រីក្រសួងការបរទេសនៃប្រទេសចិនបានថ្លែងថា ការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការអន្តរជាតិដែលជាការរៀបចំដោយអង្គការសហប្រជាជាតិគឺជាគំនិតរបស់ប្រទេសលោកខាងលិចជាពិសេសប្រទេសអាមេរិក ។

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ អៀង ធីរិទ្ធ ដែលជាប្រពន្ធរបស់ អៀង សារី និងជារដ្ឋមន្ត្រីនៃក្រសួងអប់រំនិងសង្គមកិច្ចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យបានសរសេរលិខិតមួយឆ្លើយតបនឹងអត្ថបទនៅក្នុងខេមបូឌាដេលី កាលពីថ្ងៃទី៥ ខែកុម្ភៈ ដែលមានចំណងជើងថា « អៀង សារី ព្រមានមិនឲ្យមានការរំដើបរំជួលពាក់ព័ន្ធនឹងអង្គជំនុំជម្រះ» ។ អត្ថបទនេះសរសេរថា អៀង ធីរិទ្ធ គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិក៤នាក់ នៃគណៈកម្មាធិការមជ្ឈិមខ្មែរក្រហមដែលរស់នៅតំបន់ប៉ៃលិន ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានបញ្ចូលអ្នកដែលនៅសល់ពីរបបខ្មែរក្រហមទៅជាកងយោធពលខេមរភូមិន្ទ ។

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ របាយការណ៍របស់ក្រុមអ្នកជំនាញការកម្ពុជាអនុលោមទៅតាមការសម្រេចរបស់មហាសន្និបាតលេខ៥២,១៣៥ត្រូវបានចេញផ្សាយ ។ របាយការណ៍នេះបានស្នើសុំឲ្យមានការបង្កើតតុលាការអន្តរជាតិនិងគណៈកម្មការស្វែងរកការពិតដើម្បីដោះស្រាយឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។

នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឈិត ជឿន ដែលហៅថា ម៉ុក ឬ តាម៉ុក ត្រូវបានចាប់ខ្លួនដោយកងកម្លាំងកម្ពុជាក្រោមច្បាប់កម្ពុជា ឆ្នាំ១៩៩៤ប្រឆាំងនឹងខ្មែរក្រហម ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ របាយការណ៍របស់ក្រុមអ្នកជំនាញកម្ពុជាអនុលោមទៅតាមការសម្រេចរបស់មហាសន្និ-បាតលេខ52/135 ត្រូវបានបញ្ជូនទៅកាន់ក្រុមប្រឹក្សាសន្តិសុខ និងអគ្គមហាសន្និបាត ។ នៅក្នុងរបាយការណ៍នោះ ក្រុមអ្នកជំនាញបានស្នើសុំឲ្យមានការបង្កើតតុលាការអន្តរ-ជាតិដើម្បីកាត់ទោសខ្មែរក្រហមជាផ្លូវការចំពោះឧក្រិដ្ឋប្រឆាំងមនុស្សជាតិនិងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ពីថ្ងៃ១៧មេសា១៩៧៥ដល់ថ្ងៃ៧ មករា ១៩៧៩ ។

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៩ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានគុកទួលស្លែងខ្មែរក្រហម ។ ឌុច និយាយថា នួន ជា បានបញ្ជាឲ្យគាត់សម្លាប់ជនបរទេសនៅទួលស្លែងដោយ "ដុតជាមួយកង់ឡានដើម្បីកុំឲ្យនៅសល់ឆ្អឹង" ។

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៩ នៅក្នុងកិច្ចពិភាក្សា ជាមួយអ្នកតំណាងអចិន្ត្រៃយ៍របស់កម្ពុជា ការិយាល័យកិច្ចការ ច្បាប់បង្ហាញសំណើជូនអគ្គការសហប្រជាជាតិដើម្បីឲ្យបង្កើតតុលាការចម្រុះសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ (កំណត់សម្គាល់បង្ហាញពីមូលដ្ឋានគ្រឹះរបស់តុលាការចម្រុះត្រូវបានផ្សព្វផ្សាយ ។)

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ សភាជាតិរបស់កម្ពុជា យល់ស្របនឹងច្បាប់ថ្មីចំពោះការឃុំខ្លួននៅសវនាការដំបូងពី៦ខែ ទៅ៣ឆ្នាំចំពោះអ្នកដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៩ មន្ត្រីសិទ្ធិមនុស្សរបស់អគ្គការសហប្រជាជាតិបានរិះគន់ពីច្បាប់ដែលបានយល់ស្របដោយសភាជាតិកម្ពុជាដែលអនុញ្ញាតឲ្យមានការឃុំខ្លួនរយៈពេល៣ឆ្នាំ នៅសវនាការដំបូងចំពោះជនសង្ស័យដែលត្រូវចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ រ៉ូសម៉ារី ម៉ាក់គ្រីរី ប្រធានការិយាល័យរបស់អភិបាលអគ្គការសហប្រជាជាតិជាន់ខ្ពស់សិទ្ធិមនុស្សប្រចាំនៅកម្ពុជាបានថ្លែងថា ការឃុំខ្លួនរយៈពេល៣ឆ្នាំជាការបំពានដល់បទដ្ឋានយុត្តិធម៌អន្តរជាតិ ។

រដ្ឋាភិបាលកម្ពុជាថ្លែងថា ចង់រក្សាការត្រួតពិនិត្យរបស់អគ្គការសហប្រជាជាតិចំពោះតុលាការដែលមានលក្ខណៈជាអន្តរជាតិ ។ ឧបនាយករដ្ឋមន្ត្រី សុខ អាន និយាយថា ការកាត់ទោសនឹងបង្កើត

ឡើងនៅក្នុងតុលាការកម្ពុជា ប៉ុន្តែគាត់ក៏អនុញ្ញាតឲ្យមានការចូលរួមពីចៅក្រមបរទេសនិងអ្នកជំនាញច្បាប់ដែរ ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ រដ្ឋាភិបាលបានបង្កើត«ក្រុមការងារជំនាញសម្រាប់កិច្ចសហប្រតិបត្តិការច្បាប់បរទេស និងរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម» ដែលមានឧបនាយករដ្ឋមន្ត្រី សុខ អាន ជាប្រធាន ។

ក្រុមការងារបានចាប់ផ្តើមការងាររបស់ខ្លួនដោយការធ្វើសេចក្តីព្រាងច្បាប់ ។ សេចក្តីព្រាងច្បាប់ដំបូងត្រូវបានបង្កើត ឡើងនៅខែសីហា ឆ្នាំ១៩៩៩ ហើយបានប្រគល់ឲ្យគណៈប្រតិភូអង្គការសហប្រជាជាតិដែលដឹកនាំដោយលោក រ៉ាហ្វ ហ្សា៉ក់គ្លីន (Ralph Zacklin) តំណាងលេខាធិការ ហែន កូរែល (Hans Corell) ដែលទទួលបន្ទុកកិច្ចការច្បាប់នៅអង្គការសហប្រជាជាតិ ។ សេចក្តីព្រាងច្បាប់កម្ពុជាទទួលបានវិភាគទានខាងបច្ចេកទេសនិងអ្នកជំនាញការច្បាប់មកពី បារាំង ឥណ្ឌា រុស្ស៊ី អូស្ត្រាលី ព្រមទាំងមានសហរដ្ឋអាមេរិកដែលចេញមកពីអង្គការសហប្រជាជាតិ ។

នៅខែសីហា ឆ្នាំ១៩៩៩ គណៈប្រតិភូដំបូងរបស់អង្គការសហប្រជាជាតិបានសិក្សាពីច្បាប់ព្រាងដំបូង និងច្បាប់ព្រាងរបស់ខ្លួន ។ នៅពេលនោះពុំទាន់មានការយល់ស្របគ្នាទេ ។ ចំណុចខុសគ្នាភាគច្រើនគឺថា ហ្សាគ្លីន ចង់ឲ្យចៅក្រមបរទេសមានសិទ្ធិអំណាចធំ ខណៈពេលដែលកម្ពុជាក៏ចង់ឲ្យចៅក្រមខ្លួនមានសិទ្ធិអំណាចធំដែរ ។

នៅថ្ងៃទី២៥ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ បេសកកម្មដំបូងរបស់អង្គការសហប្រជាជាតិនៅកម្ពុជា គឺស្នើសុំឲ្យមានការដឹកនាំកិច្ចចរចាអំពីច្បាប់និងការអនុវត្តដើម្បីបង្កើតជាតុលាការចម្រុះនៅក្រោមច្បាប់កម្ពុជាដោយមានបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ ការអត្ថាធិប្បាយអំពីសេចក្តីព្រាងច្បាប់កម្ពុជាត្រូវបានដាក់ស្នើ ។

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ អង្គការសហប្រជាជាតិ និងមន្ត្រីកម្ពុជាបានបញ្ចប់កិច្ចចរចាក្នុងរយៈពេលមួយសប្តាហ៍ ដោយមិនមានការព្រមព្រៀងគ្នាអំពីរបៀបនៃការបង្កើតតុលាការប្រល័យពូជសាសន៍ ។ ជំនួយការលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ លោក រ៉ាហ្វ ហ្សាគ្លីន (Ralph Zacklin) និយាយថា ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាមិនឆ្លោះទៅដល់លក្ខខណ្ឌដែលអង្គការសហប្រជាជាតិយល់ថាមានសារសំខាន់ចំពោះតុលាការទេ «អង្គការសហប្រជាជាតិនឹងបញ្ឈប់ដំណើរការនេះ» ។ គណៈប្រតិភូអង្គការសហប្រជាជាតិបានសង្ខេបសារដែលមានសារសំខាន់ ៖

…ប្រសិនបើការកាត់ទោសមេដឹកនាំខ្មែរក្រហមឈានទៅដល់បទដ្ឋានអន្តរជាតិដែលមានយុត្តិធម៌ ភាពមិនលម្អៀង និងដំណើរការច្បាប់សមរម្យ ព្រមទាំងបង្កើនការគាំទ្រនិងយល់ស្របពីសហគមន៍អន្តរ-ជាតិ នោះវាសំខាន់ណាស់ថា សមាសភាពអន្តរជាតិនៃតុលាការ មានលក្ខណៈពិសេសដែលនឹងមានប្រសិទ្ធភាពជាលក្ខណៈជាតិក៏ដូចជាអន្តរជាតិ ។ ប្រការនេះមិនអាចសម្រេចបានដោយគ្រាន់តែបន្ថែមចំនួនចៅក្រមបរទេសទៅក្នុងប្រព័ន្ធតុលាការដែលមានស្រាប់នោះទេ ។ មានតែតុលាការមួយពិសេសចម្លែកខុសពីប្រព័ន្ធតុលាការដែលមានស្រាប់ ដែលប្រជាជនកម្ពុជានិងមិនមែនកម្ពុជាអាចបម្រើការជាចៅក្រមព្រះរាជអាជ្ញានិងបុគ្គលិកប្រតិបត្តិ ។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ តាម៉ុក និង ឌុច ត្រូវបានចោទប្រកាន់ពី«បទប្រល័យពូជសាសន៍» នៅក្រោមច្បាប់មាត្រា១ ចេញប្រកាសនៅថ្ងៃទី១៥ សីហា ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ អតីតមេដឹកនាំខ្មែរក្រហម អៀងសារី និង នួន ជា ដែលបានចងសម្ព័ន្ធភាពជាមួយរដ្ឋាភិបាល ហ៊ុន សែន ធ្វើសេចក្តីថ្លែងការណ៍ថា ប្រសិនបើមានតុលាការកាត់ក្តីមេដឹកនាំខ្មែរក្រហម វាប្រហែលជាបណ្តាលឲ្យកើតមានសង្គ្រាមស៊ីវិល ។ សេចក្តីថ្លែងការណ៍នេះថែមទាំងបានរិះគន់ពីការប្តឹងទាមទាររបស់ក្រុមសិទ្ធិមនុស្ស និងអ្នកនយោបាយគណបក្សប្រឆាំងដែលចង់កាត់ទោស នួន ជា និង អៀង សារី ។

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៩ ខណៈពេលដែលចូលរួមក្នុងមហាសន្និបាតលើកទី៥៤ សម្តេច ហ៊ុន សែន បានបញ្ជូនឯកសារមួយទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដោយរួមមានជម្រើសពាសម្រាប់អង្គការសហប្រជាជាតិនៅក្នុងតុលាការ ។ ១) ផ្តល់ក្រុមអ្នកច្បាប់និងចូលរួមក្នុងការដឹកនាំតុលាការនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។ ២) ផ្តល់ជាទីប្រឹក្សាច្បាប់ដោយមិនចូលរួមដោយផ្ទាល់នៅក្នុងតុលាការ និង ៣) ដកខ្លួនចេញពីតុលាការ ។

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ ពេលដែលត្រឡប់មកពីជួបពិភាក្សាជាមួយ កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិអំពីរបៀបនៃការកាត់ទោសអតីតបក្ខពួក ប៉ុល ពត មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់សច្ចាថានឹងដំណើរការការកាត់ទោសដោយផ្ទាល់ ។ ជំនួសមុខដោយការចូលរួមរបស់តុលាការដែលមានបែបបទអន្តរជាតិដែលស្នើដោយអង្គការសហប្រជាជាតិ ឧបនាយករដ្ឋមន្ត្រី សុខ អាន បានថ្លែងថា រដ្ឋាភិបាលកម្ពុជានឹងស្វែងរកយោបល់ពីសហរដ្ឋអាមេរិកនិងអ្នកជំនាញច្បាប់របស់បារាំង ដែលមានឯករាជ្យដើម្បីការពារការរិះគន់ថាកម្ពុជាខ្វះខាតប្រព័ន្ធតុលាការ ។ លោក សុខ អាន និយាយថា «យើងនឹងបន្តការងារជាមួយច្បាប់ព្រាងរបស់យើង ហើយខ្ញុំសន្យាថានឹងរក្សាការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិចំពោះដំណើរការនេះ» ។

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៩៩ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកលុបឈ្មោះខ្មែរក្រហមចេញពីបញ្ជីភេរវករ ពីព្រោះថា «មិនយូរប៉ុន្មានខ្មែរក្រហមនឹងមិនមានវត្តមានជាភេរវករទៀតទេ» ។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន យល់ព្រមតាមសំណើរបស់អង្គការសហប្រជាជាតិចំពោះតុលាការឲ្យមានចៅក្រមកម្ពុជា៣រូប និងចៅក្រមពីររូបដែលជ្រើសរើស ដោយអង្គការសហប្រជាជាតិ ។ សេចក្តីសម្រេចតម្រូវឲ្យ«មានមតិភាគច្រើនលើសលប់» ដែលយ៉ាងហោចណាស់មានចៅក្រមមួយរូបដែលជ្រើសរើសដោយអង្គការសហប្រជាជាតិយល់ស្របនឹងសេចក្តីសម្រេចរបស់តុលាការ ។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនច្បាប់ព្រាងទៅអង្គការសហ-ប្រជាជាតិរៀបរាប់ពីមធ្យោបាយកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងការប្រជុំពិសេសនៅក្នុងតុលាការភ្នំពេញដោយមានចៅក្រមកម្ពុជាភាគច្រើន ដែលមានចៅក្រមបរទេសមួយរូបនិងចៅក្រមខ្មែរមួយរូបធ្វើការសម្រេចចិត្ត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា «កម្ពុជានឹងចាប់ផ្តើមអនុម័តិច្បាប់ទោះបីជាមាន ឬមិនមានការយល់ស្របពីអង្គការសហប្រជាជាតិក៏ដោយ» ។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៩ សុខ អាន និយាយថា «អគ្គលេខាធិការអង្គការសហប្រជា-ជាតិ កូហ្វី អាណាន់ បានអត្ថាធិប្បាយទៅលើសេចក្តីព្រាង ហើយបញ្ចេញយោបល់ថា អង្គការសហ-ប្រជាជាតិជ្រើសរើសជម្រើសទីពីរនៃអនុស្សរណៈរបស់យើង» ។ (ក្នុងចំណោមជម្រើស៣ដែលសម្តេច ហ៊ុន សែន បានស្នើជូន អាណាន់ កាលពីថ្ងៃទី២០ ខែកញ្ញា) ។

ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានកែប្រែវិសោធនកម្មច្បាប់ថា ការចំណាយពីមុនដែលជាការចំណាយរបស់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិទៅលើតុលាការគឺជាការចំណាយរួមដែលមូលនិធិនេះបានមកពីជំនួយរបស់អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋា-ភិបាល និងប្រទេសដទៃទៀត ក្នុងនោះរួមមានរដ្ឋាភិបាលកម្ពុជាផងដែរ ។ សេចក្តីកែប្រែនោះ អះអាងថា ប្រសិនបើប្រទេសដទៃចង់បញ្ជូនចៅក្រម ឬព្រះរាជអាជ្ញាមកកាន់អង្គជំនុំជម្រះ ប្រទេសទាំងនោះត្រូវតែចេញថ្លៃ ចំណាយដោយខ្លួនឯង ។

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ បែនសុន សម័យ មេធាវី របស់ តាម៉ុក និយាយថា គាត់មានគម្រោងកោះហៅអតីតមេដឹកនាំនៅក្នុងពិភពលោករួមទាំងអតីតប្រធានាធិបតីរបស់សហរដ្ឋអាមេរិកផងដើម្បីសួរចម្លើយអំពីការជួយឧបត្ថម្ភរបបកម្ពុជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ នៅក្នុង

នោះគាត់មានបំណងកោះហៅ ជីមី ខាធ័រ, រ៉ូណាល់ រីហ្គេន, ហ្សក ប៊ូស, ម៉ាហ្គារេត ថាតឆឺ និង ហេនរី ឃីស៊ីងជឺ ។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ ច្បាប់ព្រាងទីពីររបស់តុលាការត្រូវបានបញ្ជូនទៅឲ្យលេខា-ធិការដ្ឋានអង្គការសហប្រជាជាតិដោយមានការស្នើសុំផ្សេងទៀតដើម្បីឲ្យមានការឆ្លើយតបភ្លាមៗ ។

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០០ ទីប្រឹក្សាច្បាប់អង្គការសហប្រជាជាតិ លោក ហែន កូរេល បានជួបពិភាក្សាជាមួយអគ្គរាជ ទូត អ៊ុច បូរិទ្ធ អ្នកតំណាងកម្ពុជានៅអង្គការសហប្រជាជាតិ ដើម្បី បញ្ជូនការឆ្លើយតបរបស់អង្គការសហប្រជាជាតិអំពីច្បាប់ព្រាងទីពីរពាក់ព័ន្ធនឹងអង្គជំនុំជម្រះ ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០០ ឧបនាយករដ្ឋមន្ត្រីកម្ពុជា យល់ស្របនឹងច្បាប់ព្រាងសម្រាប់ កាត់ទោសមេដឹកនាំខ្មែរក្រហម ដែលនៅរស់ចំពោះអំពើប្រល័យពូជសាសន៍ ប៉ុន្តែអង្គការសហប្រជា-ជាតិនៅតែបារម្ភអំពីភាពមានកម្រិតរបស់ចៅក្រមអន្តរជាតិ ។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ ឧបនាយករដ្ឋមន្ត្រីបានកែប្រែច្បាប់ព្រាងរបស់តុលាការ ដោយអនុញ្ញាតឲ្យមានការចូលរួមពីចៅក្រមបរទេសនៅក្នុងដំណើរការនេះ ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ អង្គការសហប្រជាជាតិទទួលបានច្បាប់ព្រាងដែលកែប្រែ រួចអំពីការកាត់ទោសខ្មែរក្រហមជាឯកសារបកប្រែ ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០០ ឯកឧត្តម សុខ អាន បានប្រាប់អ្នកសារព័ត៌មានថា គាត់ បានបញ្ជូនច្បាប់ព្រាងរបស់តុលាការ ទៅកាន់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដើម្បីយកទៅពិភាក្សា នៅក្នុងសភាជាតិកម្ពុជា ។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ វេទិកាពិភាក្សាសាធារណៈរបស់កម្ពុជាអំពីតុលាការខ្មែរ-ក្រហមត្រូវបានប្រារព្ធឡើងនៅទិសពាយ័ព្យនៃខេត្តបាត់ដំបង ។ ប្រជាជនប្រហែល១០០នាក់ រួមទាំង មន្ត្រីខ្មែរក្រហមថ្នាក់កណ្តាលបានចូលរួមការពិភាក្សានេះ ។

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០០ អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ខៀវ សំផន និយាយថា គាត់តាំងចិត្តថានឹងមកនិយាយនៅក្នុងវេទិកាសាធារណៈ ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០០ រហូតដល់ពេលនេះនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនទាន់បាន ប្រគល់ការត្រួតពិនិត្យអង្គជំនុំជម្រះទៅឲ្យអង្គការសហប្រជាជាតិនៅឡើយទេ ដូច្នេះក្តីសង្ឃឹមរបស់ តុលាការពីបទប្រល័យពូជសាសន៍អន្តរជាតិគឺនៅស្រពេចស្រពិល ។ ក្នុង"កាសនិយាយទៅកាន់អ្នកសារ ព័ត៌មានបន្ទាប់ពីបិទការប្រជុំ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់ការទាមទាររបស់អង្គការសហ ប្រជាជាតិឲ្យមាន "ការកាត់ទោសជាអន្តរជាតិទៅលើរបបវាលពិឃាតថាជាកលល្បិចមួយ" និងជំរុញ

ឲ្យពិភពលោកចាប់អារម្មណ៍ទៅលើភាពក្រីក្ររបស់កម្ពុជាវិញ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា "ខ្ញុំសូមផ្ញើសារដ៏សំខាន់មួយគឺថា ពិភពលោកគួរតែចាប់អារម្មណ៍ទៅលើសន្តិភាព ការផ្សះផ្សាជាតិ សហគមន៍ជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រជាជាងបង្កើតតុលាការខ្មែរក្រហម" ។

លោកអគ្គលេខាធិការ កូហ្វី អាណាន់ និយាយថា គាត់មិនបានយល់ស្របនឹងច្បាប់ព្រាង កម្ពុជា ដែលយល់ព្រមដោយរាជរដ្ឋាភិបាលកម្ពុជាទេ ។ គាត់បង្ហាញពីបញ្ហាសំខាន់៤គឺ ធានាថាអ្នកដែលត្រូវបានចោទប្រកាន់នឹងត្រូវចាប់ខ្លួន ។ មិនមានការអភ័យទោសឬលើកលែងទោស ហើយមានការតែងតាំងព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមបរទេសភាគច្រើនដោយឯករាជ្យ ។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនយល់ស្របនឹងការឆ្លើយតបរបស់ កូហ្វី អាណាន់ ចំពោះច្បាប់ព្រាងតុលាការខ្មែរក្រហមដោយយល់ថាគ្មានយុត្តិធម៌ ។ នៅក្នុងលិខិតផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ នាយករដ្ឋមន្ត្រីអះអាងថា គាត់មិនបានស្វាគមន៍មុខងារខុសគ្នារវាងអង្គការសហប្រជាជាតិនិងកម្ពុជា ជាពិសេសមុខងារដែលជ្រើសតាំងដោយប្រទេសជាសមាជិក ។

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០០នៅចំកណ្តាលសន្និសីទពាណិជ្ជកម្មអង្គការសហប្រជាជាតិនៅទីក្រុងបាងកក អគ្គលេខាធិការ កូហ្វី អាណាន់ និយាយថាខ្លួនមានសុទិដ្ឋិនិយមថា បេសកកម្មថ្មីរបស់អង្គការសហប្រជាជាតិនៅកម្ពុជា នឹងដោះស្រាយភាពមិនយល់ស្របគ្នាជាមួយរដ្ឋាភិបាលអំពីការបង្កើតតុលាការ ។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០ អតីតរដ្ឋមន្ត្រីការបរទេស របស់សហរដ្ឋអាមេរិក លោកហេនរី ឃីស៊ីងជឺ បានឲ្យយោបល់ថា គាត់គួរតែធ្វើជាកសិណសាក្សីនៅក្នុងតុលាការប្រល័យពូជសាសន៍ខ្មែរក្រហមដោយនិយាយថា នយោបាយសង្គ្រាមត្រជាក់អាចបញ្ឈប់កងទ័ពព្រៃកម្ពុជា ។ ឃីស៊ីងជឺនិយាយថា "ខ្ញុំអាចជាសាក្សីម្នាក់ឲ្យព្រះរាជអាជ្ញាខាងចុងចោទ ហើយខ្ញុំជឿថា ប្រជាជនទាំងអស់នៅតំបន់នេះដែលដឹងអំពីកម្ពុជានឹងគាំទ្រការងារនេះ" ។

ថ្ងៃទី៦ ខែមីនា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់អង្គការសហប្រជាជាតិថា អតីតអគ្គលេខាអង្គការសហប្រជាជាតិ៣រូបគួរតែទទួលខុសត្រូវចំពោះមុខងាររបស់ខ្មែរក្រហមដែលមានអាសនៈមួយនៅអង្គការសហប្រជាជាតិក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៧០និង១៩៨០ ។ ព្រះអង្គម្ចាស់ រណឫទ្ធិ មានព្រះបន្ទូលប្រាប់អ្នកសារព័ត៌មានថា ព្រះអង្គយល់អំពី"ការពិត"នៃគំណែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែព្រះអង្គម្ចាស់និងព្រះបិតា (សម្តេច សីហនុ) សង្ឃឹមថា នឹងឈានទៅដល់ការសម្របសម្រួលមួយ ។

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិនិងកម្ពុជា បានបើកការប្រជុំចុងក្រោយដើម្បីពិភាក្សាពីភាពខុសគ្នាខ្លាំងនៅក្នុងតុលាការខ្មែរក្រហម ។ បញ្ហាសំខាន់៤ស្ថិតនៅចំពោះមុខ តើអ្នកណានឹងឲ្យឈ្មោះជនសង្ស័យនៅក្នុងអង្គជំនុំជម្រះ? តើរាជរដ្ឋាភិបាលកម្ពុជានឹងចាប់រាល់ជនសង្ស័យទាំងអស់ឬទេ? តើរាជរដ្ឋាភិបាលដែលពាក់ព័ន្ធជាមួយ ខ្មែរក្រហមនឹងការពារអតីតអ្នកបះបោរពីការកាត់ទោសឬទេ? តើចៅក្រមបរទេសនិងចៅក្រមកម្ពុជានឹងព្រមព្រៀងគ្នាដោយរបៀបណា?

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០០ មានលិខិតឆ្លើយឆ្លងរវាងអ្នកតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការងារច្បាប់ ហែន កូរេល និងឧបនាយករដ្ឋមន្ត្រី សុខ អាន ចំពោះបញ្ហាពាក់ព័ន្ធនឹងការលើកលែងទោស សហព្រះរាជអាជ្ញានិងអំណាចឯករាជ្យករណីគ្មានការឯកភាពគ្នា យន្តការនៃការសម្របជម្លោះ នៅតែមិនទាន់សម្រេច ។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០ កិច្ចចរចាប្រព្រឹត្តទៅអស់រយៈមួយសប្តាហ៍ កម្ពុជានិងអង្គការសហប្រជាជាតិប្រកាសថា គេមិនបានឆ្ពោះទៅការយល់ស្របគ្នាអំពីរបៀបនៃការរៀបចំតុលាការសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ សម្តេច សីហនុ ប្រកាសថា ទ្រង់មានបំណងប្រឈមមុខនឹងប្រជាជនកម្ពុជា ព្រមទាំងតុលាការអំពើប្រល័យពូជសាសន៍អន្តរជាតិដើម្បីប្រាប់ពីតួនាទីរបស់ទ្រង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០លោក អាណាន់ បានសរសេរលិខិតមួយផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឆ្លើយតបនឹងការគាំទ្រគម្រោងសហរដ្ឋអាមេរិករបស់មេដឹកនាំកម្ពុជាអំពីរបៀបនៃការដោះស្រាយបញ្ហាចំពោះការចោទប្រកាន់មេដឹកនាំនៅក្នុងតុលាការ ។ អ្នកដឹកនាំការចរចាលោក សុខ អាន ឆ្លើយតបនឹងសំបុត្ររបស់លោក អាណាន់ ថា “ខ្ញុំមិនទាន់បានត្រួតពិនិត្យនៅឡើយទេ” ។ លោក អាណាន់ ប្រាប់អ្នកសារព័ត៌មាននៅទីស្នាក់ការអង្គការសហប្រជាជាតិថា “មានតែឆ្លងកាត់ការត្រួតពិនិត្យទើបធ្វើឲ្យមានការបកស្រាយនិងការពិសោធអំពីដំណើរការ ។ មានសំណើមួយចំនួនត្រូវបានរក្សាទុកនៅលើតុសម្រាប់ឲ្យដោះស្រាយ ប៉ុន្តែមានភាពរាំងស្ទះមួយ គឺរបៀបនៃការរក្សាស្ថានភាពនៅពេលដែលព្រះរាជអាជ្ញាមួយរូបមិនយល់ស្របនឹងគំនិតព្រះរាជអាជ្ញាឯទៀត” និងរបៀបនៃយន្តការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពអាចដំណើរការបាន ។

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបនឹងសំបុត្ររបស់អគ្គលេខាធិការកាលពីថ្ងៃទី១៩ ខែមេសា ដែលក្នុងនោះសម្តេចអះអាងថា ការឆ្លើយតបនឹងសំបុត្រ

រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាមិនអាចធ្វើអ្វីបានទេ មុនពេលដែលច្បាប់មិនទាន់បានអនុម័តិ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើសុំឲ្យមាន"សវនាការពិសេស" ដើម្បីដោះស្រាយការមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញា ។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០ លោក អាណាន់ បានផ្ញើលិខិតទីពីរជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឆ្លើយតបនឹងលិខិតកាលពីថ្ងៃ២២ ខែមេសា ដែលជំរុញឲ្យលោកទទួលយកសំណើរបស់អង្គការសហប្រជាជាតិ ។

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបនឹងលិខិតរបស់លោក អាណាន់ កាលពីថ្ងៃទី២៥ ហើយស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកាត់ទោសឧក្រិដ្ឋកម្មដែលមានតាំងពីឆ្នាំ១៩៧០ ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បានយល់ស្របនឹងសំណើរបស់សមាជិកព្រឹទ្ធសភាអាមេរិក លោក ចន ខេរី ។ នៅក្នុងសំណើនោះ ក្រុមចៅក្រមត្រូវមានចៅក្រមកម្ពុជា ៣រូប និងចៅក្រមបរទេស២រូប ។ ចំពោះការដោះស្រាយជម្លោះក្នុងការចោទប្រកាន់ត្រូវតែមានចៅក្រម៤រូបយល់ស្របគ្នាដើម្បីរក្សាដំណើរការកាត់ក្តីនេះ ។

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០០ លោក អាណាន់ បានសរសេរលិខិតមួយផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីចង់បានការអះអាងបញ្ជាក់បន្ថែមដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមជាមួយនឹងសមាជិកព្រឹទ្ធសភា ចន ខេរី ដែលសំណើបាន ធ្វើឡើងនៅក្នុងលិខិតរបស់អគ្គលេខាធិការនៅថ្ងៃទី១៩ ខែមេសា ពាក់ព័ន្ធនឹងយន្តការដោះស្រាយភាពមិនយល់ស្របគ្នារវាងសហ-ចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញា ហើយសវនាការអង្គជំនុំជម្រះនេះអាចកាត់សេចក្តីត្រឹមឧក្រិដ្ឋកម្មដែលកើតឡើងតែ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ប៉ុណ្ណោះ ។

នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បានផ្ញើលិខិតមួយទៅលោក កូហ្វី អាណាន់ ដើម្បីបង្ហាញពីការគាំទ្ររបស់ខ្លួនចំពោះយុត្តិសាស្ត្រសម្របសម្រួលដែលចរចាដោយ ខេរី នៅខែមេសា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០០ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា បញ្ចប់សេចក្តីសង្ខេបនៃច្បាប់ព្រាងសម្រាប់អង្គជំនុំជម្រះ ។ អង្គជំនុំជម្រះនឹងប្រព្រឹត្តទៅនៅក្នុងតុលាការកម្ពុជាដែលមានការចូលរួមពីព្រះរាជអាជ្ញានិងចៅក្រមអន្តរជាតិ ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ ហាន់ កូរ៉ែល បង្ហាញពីអនុស្សរណៈព្រាងនៃការយល់ដឹងដែលនឹងផ្តល់ការសហការរវាងអង្គការសហប្រជាជាតិ និងកម្ពុជាស្តីអំពីការបង្កើតនិងប្រតិបត្តិការរបស់

អង្គជំនុំជម្រះ ។ អនុស្សរណៈត្រូវបានចុះហត្ថលេខាដោយអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបន្ទាប់ពីសភាកម្ពុជាអនុម័តច្បាប់ ។ លោក កូរ៉ែល និងលោក ឌិម យិនទៀង ទីប្រឹក្សាជាន់ខ្ពស់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុងសាលចតុមុខអំពីលទ្ធភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះមុនពេល ដែលក្រុមប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិចាកចេញពីកម្ពុជា ។

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បង្ហាញថា អតីតរដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហម អៀង សារី មិនគួរយកទៅកាត់ទោសអំពីបទប្រល័យពូជសាសន៍ទេ ។ នៅឆ្នាំ ១៩៧៩ អៀង សារី និង ប៉ុល ពត ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខ ប៉ុន្តែ អៀង សារី ទទួលបានការលើកលែងទោសពីសម្តេច សីហនុ បន្ទាប់ពីបានចុះចូលជាមួយរដ្ឋាភិបាលនៅឆ្នាំ ១៩៩៦ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ថែមទៀតថា វាអាស្រ័យទៅលើតុលាការ និងសភាជាតិចំពោះការពិចារណាទៅលើច្បាប់ព្រាងសម្រាប់អង្គជំនុំជម្រះថា តើគួរធ្វើយ៉ាងណាចំពោះអង្គជំនុំជម្រះ-វិសាមញ្ញ ។

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០០ ព្រះអង្គម្ចាស់ រណឫទ្ធិ ប្រាប់អ្នកសារព័ត៌មានថា សម្តេច សីហនុ បានបួងសួងឲ្យតុលាការពន្យារពេលពីព្រោះទ្រង់កំពុងតែព្រួយបារម្ភអំពីសន្តិភាពនិងស្ថិរភាពនៅក្នុងប្រទេស ។ ព្រះអង្គម្ចាស់បានបន្ថែមទៀតថា សេចក្តីព្រាងច្បាប់របស់តុលាការមិនទាន់មានការស្រុះស្រួលគ្នានៅឡើយទេនៅឆ្នាំនេះ ពីព្រោះរដ្ឋាភិបាលព្រួយបារម្ភអំពីទឹកជំនន់ថ្មីៗនេះដាង ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្សព្វផ្សាយតាមវិទ្យុជាតិថា គាត់ព្យាយាមជំរុញឲ្យច្បាប់របស់តុលាការមានដំណើរការទៅមុខ ។ គាត់អះអាងថា «យើងត្រូវការឲ្យមានតុលាការនៅពេលឆាប់ៗនេះ បើមិនដូច្នេះភាពព្រៃផ្សៃរបស់ខ្មែរក្រហមនៅតែដក់ជាប់ក្នុងចិត្តយើង» ។

នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០០ មានប្រទេសចំនួន១១ រួមមានប្រទេសជប៉ុន អូស្ត្រាលី កាណាដា និង ញូហ្សឺលេន ស្នើសុំឲ្យគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិសំណូមពរឲ្យរដ្ឋាភិបាកកម្ពុជាបង្កើតច្បាប់សម្រាប់តុលាការដើម្បីកាត់ទោសខ្មែរក្រហម ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០០ យោងទៅតាមរបាយការណ៍របស់កាសែតបានឲ្យដឹងថា សមាជិកព្រឹទ្ធសភាលោក ចន ខេរី ធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាប្រហែលជាអាចជំរុញឲ្យការប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបង្កើតអង្គជំនុំជម្រះបានសម្រេច ។ លោក ខេរី សន្យាចំពោះមុខ លោក សុខ អាន នាយករដ្ឋមន្ត្រី ហ៊ុន សែន និងព្រះអង្គម្ចាស់ រណឫទ្ធិ ថា ដំណើរការរបស់អង្គជំនុំជម្រះនឹងដើរទៅមុខតាមការរៀបចំដែលអាចជំរុញឲ្យសភាជាតិធ្វើការសម្រេចច្បាប់នៅខែធ្នូ ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ គណៈកម្មាធិការតាក់តែងច្បាប់របស់សភាកម្ពុជានិងក្រុមការងាររបស់រដ្ឋាភិបាលធ្វើការសម្រេចសេចក្ដីព្រាងច្បាប់របស់តុលាការ ។ ដូច្នេះ សភាជាតិអាចធ្វើការពិភាក្សាទៅលើច្បាប់នេះ ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ នៅក្នុងបទសម្ភាសន៍ជាមួយប្រទេសជប៉ុន នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ម្ដងទៀតថា ការកាត់ទោស អៀង សារី ប្រហែលជាអាចបង្កើតបញ្ហាចំពោះប្រទេសកម្ពុជា ។ ប៉ុន្តែ លោកបញ្ជាក់ទៀតថា "ការកាត់ទោស ខៀវ សំផន និង នួន ជា ប្រហែលជាមិនមានបញ្ហាអ្វីទេ" ។

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០០ សេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ UNGA A/RES/55/95:

កថាខណ្ឌទី១៨ : ទទួលស្វាគមន៍ចំពោះសេចក្ដីសម្រេចដ៏ជោគជ័យអំពីកិច្ចពិភាក្សារវាងរដ្ឋាភិបាលកម្ពុជានិងអគ្គលេខាធិការដ្ឋាន អង្គការសហប្រជាជាតិស្ដីពីការកាត់ទោសមេដឹកនាំខ្មែរ-ក្រហម ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ធានាចំពោះរដ្ឋាភិបាល ដោយជួយសម្រួលសេចក្ដីសម្រេចដែលចាំបាច់ចំពោះដំណើរការតាក់តែងច្បាប់ឲ្យបានឆាប់រហ័សដើម្បីយកមេដឹកនាំខ្មែរក្រហមមកទទួលខុសត្រូវ យោងទៅតាមប្រព័ន្ធយុត្តិធម៌ ភាពមិនលម្អៀង ដែលមានបទដ្ឋានអន្តរជាតិ សុភនិច្ឆ័យនិងដំណើរការនីតិវិធីស្របច្បាប់ ហើយជំរុញឲ្យរដ្ឋាភិបាលបន្តសហការជាមួយអង្គការសហប្រជាជាតិចំពោះបញ្ហានេះ ព្រមទាំងស្វាគមន៍ការខំប្រឹងប្រែងរបស់អគ្គលេខាធិការដ្ឋាននិងសហគមន៍អន្តរជាតិក្នុងការជួយរដ្ឋាភិបាលមកដល់ទីបញ្ចប់នេះ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ អៀង សារី ប្រាប់សារព័ត៌មានថា គាត់បានធ្វើវិភាគទានកសាងជាតិនិងផ្សះផ្សាជាតិតាំងពីគាត់ចុះចូលជាមួយរដ្ឋាភិបាលនៅខែកញ្ញា ឆ្នាំ១៩៩៦ ។ គាត់បានបន្ថែមទៀតថា គាត់គ្រាន់តែទទួលបន្ទុកកិច្ចការក្រសួងការបរទេសនៅអំឡុងកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ មិនមែនអំពើប្រល័យពូជសាសន៍នោះទេ ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ សភាជាតិរបស់កម្ពុជាទទួលបានសេចក្ដីសម្រេចព្រាងច្បាប់របស់តុលាការពីក្រុមការងាររបស់រដ្ឋាភិបាល ។ សមាជិកសភាចំនួន៩៨រូបក្នុងចំនួន១២២រូបគាំទ្រជំពូកទីមួយនៃច្បាប់របស់អង្គជំនុំជម្រះ ។ ច្បាប់នេះត្រូវបានរំពឹងទុកថានឹងត្រូវសម្រេចដោយពេញលេញនៅដើមខែមករា ។

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ សភាជាតិរបស់កម្ពុជា យល់ស្របនឹងច្បាប់ព្រាងរបស់អង្គជំនុំជម្រះក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០០១ សហរដ្ឋអាមេរិកស្វាគមន៍សភាជាតិរបស់កម្ពុជាក្នុងការបង្កើតមធ្យោបាយស៊ើបអង្កេតនិងកាត់ទោសមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ លោក ហាន់ កូរ៉ែល ផ្ញើសំបុត្រមួយទៅឲ្យរដ្ឋាភិបាលកម្ពុជាដើម្បីបង្ហាញពីភាពមិនយល់ស្របអំពីសេចក្ដីព្រាងច្បាប់ ។ អង្គការសហប្រជាជាតិស្នើសុំឲ្យមានការផ្លាស់ប្ដូរសេចក្ដីព្រាងច្បាប់ប្រហែល១៨មាត្រា ។ លោក កូរ៉ែល ក៏បានអះអាងថា សេចក្ដីព្រាងច្បាប់ខ្វះខាតច្បាប់ត្រៀម ដើម្បីធានាឲ្យមានការត្រួតពិនិត្យគ្រប់គ្រាន់ពីអង្គការសហប្រជាជាតិក្នុងការរ៉ាប់រងឲ្យព្រះរាជអាជ្ញាមានអំណាចចោទប្រកាន់ជនសង្ស័យដែលមានការលើកលែងទោស ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅភ្នំពេញផ្ញើឯកសារបកប្រែច្បាប់ជាលក្ខណៈមិនផ្លូវការដែលមានការយល់ស្របពីសភាជាតិនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ។ នៅក្នុងលិខិតថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ លោក កូរ៉ែល បានបង្ហាញពីការព្រួយបារម្ភអំពីច្បាប់ត្រៀមនេះ ។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ ព្រឹទ្ធសភាកម្ពុជាសុទ្ធតែយល់ស្របនឹងសេចក្ដីព្រាងច្បាប់របស់អង្គជំនុំជម្រះ ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីខែមេសា ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៩ បានផ្ញើសារមួយថា គាត់នឹងប្រឈមមុខចំពោះអង្គជំនុំជម្រះប្រសិនបើមានករណីចាំបាច់ ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០១ លោក កូរ៉ែល ស្នើសុំឲ្យមានការបកប្រែច្បាប់ដែលមានការយល់ស្របគ្នាជាលក្ខណៈផ្លូវការ ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញយល់ស្របនឹងសេចក្ដីព្រាងច្បាប់ ។ យ៉ង់ សែម ដែលជាសមាជិករបស់ក្រុមប្រឹក្សាសម្រេចថា ច្បាប់«មានលក្ខណៈផ្លូវការនៅក្រោមច្បាប់រដ្ឋធម្មនុញ្ញ» ។ យ៉ាងណាមិញ ក្រុមប្រឹក្សាសម្គាល់ឃើញភាពមិនយល់ស្របគ្នាខាងបច្ចេកទេសនៅក្នុងវិធានទី៣នៃសេចក្ដីព្រាងច្បាប់ ដែលស្នើឲ្យមានការកាត់ទោសប្រហារជីវិតចំពោះទោសធ្ងន់បំផុត ។ ដោយសារតែរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នបានលុបបំបាត់ការកាត់ទោសប្រហារជីវិត ដូច្នេះក្រុមប្រឹក្សាប្រកាស ថានឹងផ្ញើសេចក្ដីព្រាងច្បាប់ទៅឲ្យសភាដើម្បីធ្វើវិសោធនកម្ម ។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា សេចក្តីព្រាងច្បាប់ត្រូវតែបញ្ជូនទៅដំណាក់កាលព្រាងដំបូង ហើយធ្វើកិច្ចពិភាក្សាដោយសភាម្តងទៀតអំពីភាពមិនយល់ស្របគ្នាខាងបច្ចេកទេសដែលរកឃើញដោយក្រុមប្រឹក្សាធម្មនុញ្ញអំពីកំហុសឆ្គងខាងបច្ចេកទេសនៅក្នុងការតាក់តែងច្បាប់ ដែលពាក់ព័ន្ធនឹងការកាត់ទោសប្រហារជីវិតនៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ តាមការពិត ច្បាប់ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យ លើកទីពីរពីសភាជាតិដែលនេះធ្វើឲ្យអង្គការសហប្រ-ជាជាតិមានភាពអស់សង្ឃឹម ។ អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិប្រាប់អ្នកសារព័ត៌មាននៅទីក្រុងញូវយ៉ក៍ថា "វាហាក់ដូចជាយើងកំពុងតែចាប់ផ្តើមពីក្រោមឡើងទៅម្តងទៀត" ។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា គាត់ចង់រក្សាទុកអដ្ឋិធាតុរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ដើម្បីជាភស្តុតាងសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនៅតុលាការដែលបានគ្រោងទុក ដែលវាសនានៃតុលាការនេះត្រូវបានសម្រេចដោយប្រជាជន ។ នាយករដ្ឋមន្ត្រីមានប្រសាសន៍ទៀតថា គណៈរដ្ឋមន្ត្រីត្រូវតែពិភាក្សាអំពីច្បាប់នេះ ជាលើកទីពីរមុនខែមិថុនា បន្ទាប់ពីបញ្ជូនទៅឲ្យសភាជាតិ ។

គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ យល់ស្របនឹងដំណោះស្រាយរបស់ប្រ-ទេសជប៉ុនដែលជំរុញឲ្យរដ្ឋាភិបាលកម្ពុជាបង្កើតអង្គជំនុំជម្រះឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន បដិសេធការចោទប្រកាន់របស់អ្នកសារព័ត៌មានដែលថា ប្រទេសចិនកំពុងតែដាក់សម្ពាធទៅលើរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាអង្គជំនុំជម្រះ ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា "អ្នកដែលដាក់សម្ពាធមកលើខ្ញុំគឺអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ ប្រធានមន្ត្រីច្បាប់របស់អង្គការសហប្រជាជាតិ លោក ហាន់ កូរ៉ែល និង សមាជិកព្រឹទ្ធសភារបស់អាមេរិក លោក ចន ខេរី ។

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០១ លោក កូហ្វី អាណាន់ បង្ខំឲ្យរដ្ឋាភិបាលកម្ពុជាធ្វើច្បាប់សម្រាប់អង្គជំនុំជម្រះឲ្យបានលឿន ។ លោក អាណាន់ បានប្រាប់អ្នកសារព័ត៌មានថាគាត់មិនបានឮដំណឹងអ្វីពីរដ្ឋាភិបាលកម្ពុជាអំពីអង្គជំនុំជម្រះអស់រយៈពេល៦ខែមកហើយ ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន សន្យាថានឹងឲ្យសច្ចាប័នច្បាប់រ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ប្រសិនបើមានការយល់ស្របដោយសភាប្រទេសកម្ពុជាអាចជាប្រទេសដំបូងគេនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលបានឲ្យសច្ចាប័នច្បាប់ ។ នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា "ប្រទេសកម្ពុជានឹងទទួលផលប្រយោជន៍ច្រើនជាងគេដោយសារបទពិសោធន៍ ដែលគ្មានអ្វីប្រៀបផ្ទឹមនៃអំពើប្រល័យពូជសាសន៍ថ្មីៗនេះ" ។

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០១ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ ស្នើឲ្យសាកលវិទ្យាល័យធម្មសាស្ត្រ ប្រគល់កំណត់ហេតុ នួន ជា ដែលគាត់ទទួលបានអាហារូបករណ៍ ដើម្បីរៀនច្បាប់នៅទសវត្សរ៍ឆ្នាំ១៩៤០នៅទីនោះ ហើយបន្ទាប់មកគាត់ធ្វើការឲ្យក្រសួងការបរទេសថៃបានមួយរយៈពេលវែង ដោយនិយាយថាកំណត់ហេតុនេះប្រហែលជាមានផ្ទុកនូវភស្តុតាងសំខាន់សម្រាប់តុលាការខ្មែរក្រហម ។

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន លោក កូរ៉ែល ស្នើឲ្យមានការបកប្រែច្បាប់ជាផ្លូវការនិងឲ្យមានភាពរលូននៃឧបករណ៍បកប្រែទាំងពីរនេះ ។

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់ដំណឹងឲ្យម្ចាស់ជំនួយអន្តរជាតិនៅពេលជួបប្រជុំ ពិគ្រោះយោបល់រយៈពេលពីរថ្ងៃដែលប្រារព្ធឡើងនៅតូក្យូ អំពីប្រទេសកម្ពុជាដែលមានគម្រោងអនុម័តច្បាប់តុលាការនៅពេលឆាប់ៗនេះ ។ នាយករដ្ឋមន្ត្រីនិយាយថា លោកនឹងគោរពតាមយុត្តិធម៌ហើយតុលាការខ្មែរក្រហមនឹងចាប់ផ្តើមនៅចុងឆ្នាំនេះ ។

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០១ នួន ជា អតីតខ្មែរក្រហមដែលជាអ្នកមនោគមន៍វិជ្ជា និងជាបងធំទីពីរនិយាយថា គាត់នឹងប្រឈមមុខចំពោះតុលាការព្រមទាំងច្បាប់ ។ យ៉ាងណាមិញ នួន ជា បដិសេធរហូតថា គាត់មិនបានដឹងអំពីការសម្លាប់ទេបន្ទាប់ពីការចាកចេញពីរដ្ឋាភិបាលនៅខែធ្នូ ឆ្នាំ១៩៩៨ ។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ រដ្ឋាភិបាលកម្ពុជាកែប្រែសេចក្តីព្រាងច្បាប់របស់តុលាការដោយប្តូរទោសប្រហារជីវិត ឲ្យទៅជាជាប់ពន្ធនាគារអស់មួយជីវិតវិញ ចំពោះទោសធ្ងន់ធ្ងរបំផុត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថែមទាំងបានបង្ហាញពីសុទិដ្ឋិនិយមថា អង្គជំនុំជម្រះនឹងដំណើរការនៅចុងឆ្នាំនេះ ។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ សមាជិកគណៈកម្មការជាន់ខ្ពស់របស់អង្គការសហប្រជា-ជាតិនៃអ្នកតំណាងសិទ្ធិមនុស្ស ពិសេសប្រចាំប្រទេសកម្ពុជា លោក ភីតជឺ ឡឺប្រឺត្យ និយាយថា អៀង សារី គួរតែត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មពីឆ្នាំ១៩៧៥-១៩៧៩ ហើយប្រសិនបើមានតែការកាត់ទោស តា ម៉ុក និង ឌុច នោះវានឹងមិនមានប្រសិទ្ធភាពទេ ។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ ដើម្បីឆ្លើយតបនឹងសេចក្តីថ្លែងការណ៍ព័ត៌មានថ្មីៗដែលថាអង្គជំនុំជម្រះអាចនឹងត្រូវបានបង្កើតឡើងនៅឆ្នាំនេះ អង្គការសហប្រជាជាតិបានចេញសេចក្តីប្រកាសព័ត៌មានថា គ្មានការទទួលស្គាល់អង្គជំនុំជម្រះជាលក្ខណៈអន្តរជាតិទេ ដរាបណាអនុស្សរណៈយល់ស្របគ្នារវាងអង្គការសហប្រជាជាតិនិងកម្ពុជាមិនទាន់ត្រូវបានចុះហត្ថលេខានិងឲ្យសច្ចាប័ន ។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ សម្តេច សីហនុ ធានា ចំពោះ ភីតជី ឡឺប្រឺត្យ ថា ព្រះអង្គនឹងចុះហត្ថលេខាទទួលស្គាល់ច្បាប់ដើម្បីបង្កើតតុលាការដែលមានជំនួយពីអង្គការសហប្រជាជាតិ ក្នុងគោលបំណងកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា ប្រសិនបើ អង្គការសហប្រជាជាតិមិនពេញចិត្តនឹងច្បាប់ថ្មី គឺអាចដកខ្លួនចេញពីអង្គជំនុំជម្រះបាន ។ លោកបន្ត ទៀតថា «ប្រសិនបើអង្គការសហប្រជាជាតិមិនចូលរួមនោះ វាងាយស្រួលដល់ខ្ញុំ ។ ខ្ញុំមានបំណងនឹងចុះ កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ» ។

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០១ ព្រះអង្គម្ចាស់ រណឫទ្ធិ បន្ថែមលើសម្តីរបស់នាយក រដ្ឋមន្ត្រី ហ៊ុន សែន ថា ប្រទេសកម្ពុជាមិនត្រូវធ្វើតាមតម្រូវការរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធ នឹងច្បាប់របស់អង្គជំនុំជម្រះ ។ ព្រះអង្គសង្កត់ធ្ងន់ថា «ប្រទេសកម្ពុជា នឹងមិនធ្វើការចរចាបន្តទៀតទេ ហើយទោះបីជាអង្គការសហប្រជា ជាតិមិនយល់ព្រមនឹងច្បាប់នេះក៏ដោយ នោះគឺជារឿងរបស់គេ» ។

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក កូរ៉ែល លោក សុខ អាន សម្តែងភាពយល់ស្របពីទំនាក់ទំនងរវាងច្បាប់និងកិច្ចព្រមព្រៀង ។ ខណៈពេលដែលយល់ស្របនឹង គោលការណ៍ដែលគួរតែអនុវត្តន៍ លោកក៏បានបដិសេធនឹងការ«បន្ទំ» ។

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០១ លោក កូរ៉ែល ឆ្លើយតបថា គាត់ត្រូវការភាពស៊ីគ្នារវាង ឯកសារទាំងពីរ ។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០១ សភាជាតិយល់ស្របនឹងច្បាប់ដើម្បីបង្កើតតុលាការកាត់ ទោសខ្មែរក្រហម ។ បន្ទាប់ពីមានការយល់ព្រមគ្នា លោក សុខ អាន ប្រាប់អ្នកសារព័ត៌មានថា គាត់ និងលោក កូរ៉ែល «នឹងបន្តចរចាជាមួយគ្នាទៀតបន្ទាប់ពីច្បាប់មានសុពលភាព» ។

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ សម្តេច សីហនុ ប្រកាសថាទ្រង់នឹងមិនពាក់ព័ន្ធនៅក្នុង ដំណើរការរបស់អង្គជំនុំជម្រះ ជាពិសេសចំពោះបញ្ហាថានឹង«ការកាត់ទោស អៀង សារី, នួន ជា និង ខៀវ សំផន » ។

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ព្រឹទ្ធសភាកម្ពុជាទទួលច្បាប់តុលាការខ្មែរក្រហមដែលអាច កែប្រែបាន ។

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០១ ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនៅសាកល វិទ្យាល័យអាមេរិកផ្សាយព័ត៌មានដោយ ស្ទេហ៊ិន ហេដឺ និង ប្រាយអេន ធីតជឺម៉ាន បង្ហាញពីការ ចោទប្រកាន់និងភ័ស្តុតាងសមស្របពាក់ព័ន្ធនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម៧នាក់ដែលនៅរស់ ។

មេដឹកនាំដែលត្រូវបានយកមកពិចារណានៅក្នុងរបាយការណ៍គឺ នួន ជា, អៀង សារី, ខៀវ សំផន, តា ម៉ុក, កែ ពក, ស៊ូ មេ៉ត និង មាស មុត ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា ការចោទប្រកាន់មេដឹកនាំខ្មែរក្រហមសម្រេចទៅលើការសម្រេចចិត្តរបស់តុលាការ មិនមែនអ្នកមានចំណេះដឹងទេ ។ លោកនាយករដ្ឋមន្ត្រីចាត់ទុកសេចក្តីសម្រេចថាជាការធ្វើអន្តរាគមន៍របស់បរទេសនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ព្រឹទ្ធសភាកម្ពុជាយល់ស្របនឹងច្បាប់ថ្មីរបស់តុលាការ ។ បន្ទាប់ពីការបោះឆ្នោត លោក សុខ អាន ប្រាប់អ្នកសារព័ត៌មានថា គាត់មានសុទិដ្ឋិនិយមថាប្រទេសកម្ពុជា និងអង្គការសហប្រជាជាតិនឹងឆ្ពោះទៅកាន់ដំណោះស្រាយ ហើយ“វត្តមានរបស់តុលាការត្រូវពឹងផ្អែកលើការធ្វើកិច្ចចរចាទាំងនេះ” ។

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថានៅក្នុងសាលាគរុកោសល្យថា “រដ្ឋាភិបាលមិនទាន់បានចេញដីកាចាប់ខ្លួន ខៀវ សំផន, នួន ជា ឬ កែ ពក” ហើយស្នើសុំថាការចាប់ខ្លួនត្រូវតែមានតុល្យភាពរវាងសន្តិភាពនិងការផ្សះផ្សាជាតិ ។

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០១ លោក សុខ អាន បង្ហាញថា រដ្ឋាភិបាលកម្ពុជាកំពុងតែស្វែងរកការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការប្រល័យពូជសាសន៍ ។ លោកមានប្រសាសន៍នៅក្នុងផ្ទះរបស់គាត់នៅខេត្តតាកែវថា “យើងត្រូវការដៃគូរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម” ។

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញយល់ស្របនឹងសេចក្តីព្រាងច្បាប់ដែលនឹងត្រូវយកមកកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ សម្តេច សីហនុ ឡាយព្រហស្តលេខាលើច្បាប់ “ក្នុងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍នៅឯការសម្ពោធមួយ ដែលមានការចូលរួមរបស់អតីតមេបញ្ជាការទ័ពខ្មែរក្រហម មេដឹកនាំថ្នាក់ខ្ពស់យ៉ាងតិច ១០នាក់ត្រូវយកមកកាត់ទោសនៅតុលាការដែលបានគ្រោងទុក ហើយកម្មាភិបាលថ្នាក់ទាបនិងមធ្យមនឹងមិនត្រូវយកមកកាត់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។ “ដូច្នេះកុំភ័យខ្លាច និងរត់ចូលព្រៃអី ។ តុលាការនេះកាត់ទោសតែមេដឹកនាំថ្នាក់ខ្ពស់របស់ខ្មែរក្រហមប៉ុណ្ណោះ” ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ឯកអគ្គរដ្ឋទូតអាមេរិក លោក ខេន វីដីមេន មានប្រសាសន៍ថា រដ្ឋាភិបាលបានសន្យាថា អៀង សារី អាចត្រូវបានចាប់ខ្លួនមុនពេលមានការកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រសិនបើ អៀង សារី មិនត្រូវបានយកមកកាត់ទោសទេ អាមេរិកនឹងដកជំនួយពីតុលាការ ។

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០១ លោក សុខ អាន ស្នើច្បាប់ក្នុងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានយល់ស្របនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ជាភាសាខ្មែរដោយមានកំណត់សម្គាល់ថា ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេសនិងបារាំងនឹងសម្រេចនៅពេលខាងមុខនៅអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា ខៀវ សំផន មិនអាចគេចផុតពីការប្រឈមមុខនឹងការកាត់ក្ដី ទោះបីជាគាត់បដិសេធថាគាត់មិនជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ក៏ដោយ ។ ដកស្រង់ចេញពីច្បាប់អង្គជំនុំជម្រះរបស់កម្ពុជាដែលសេចក្ដីចម្លងត្រូវបានបញ្ជូនទៅឲ្យអង្គការសហប្រជាជាតិនៅញូវយ៉ក បានឲ្យដឹងថា ខៀវ សំផន បដិសេធថាគាត់មិនបានបញ្ជាឲ្យមានការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ អង្គការសហប្រជាជាតិទទួលបានការបកប្រែជាផ្លូវការពីភាសាខ្មែរទៅអង់គ្លេសនិងបារាំង នៅក្នុងលិខិតដែលលោក សុខ អាន ផ្ញើឲ្យលោក ហាន់ កូរ៉ែល ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ សមាជិកព្រឹទ្ធសភាអាមេរិកពីររូបស្នើថា អង្គការសហប្រជាជាតិនឹងមិនចូលរួមក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ប្រសិនបើរដ្ឋាភិបាលកម្ពុជាមិនផ្ដល់ការការពារដើម្បីធានាឲ្យមានច្បាប់ដែលមានបទដ្ឋានអន្តរជាតិកម្រិតខ្ពស់ ។

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ ទ័ពកម្ពុជានិយាយថា បានដករថក្រោះនិងកាំភ្លើងធំពីអតីតទីបញ្ជាការខ្មែរក្រហមដោយការផ្លាស់ប្ដូរនេះ គឺដើម្បីចៀសវាងកុំឲ្យមានអសន្តិសុខចំពោះតុលាការប្រល័យពូជសាសន៍ដែលបានគ្រោងទុក ។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ កែ ពក ដែលជាអតីតមេបញ្ជាការទ័ពរងរបស់ខ្មែរក្រហម បដិសេធថា មិនបានជាប់ពាក់ព័ន្ធនឹងអំពើឃោរឃៅដែលបានសម្លាប់ប្រជាជនកម្ពុជាជាង១លាននាក់ ដោយនិយាយថាគាត់ គឺជាសមាជិកថ្នាក់តូចម្នាក់ ហើយយល់ដឹងពីស្ថានការណ៍ប្រទេសតែបន្តិចបន្តួចប៉ុណ្ណោះ ។ គាត់ថែមទាំងបដិសេធនឹងពាក្យចចាមអារ៉ាមដែលថាគាត់កំពុងតែស្វែងរកទិដ្ឋាការដើម្បីធ្វើដំណើរទៅប្រទេសចិន ។

នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០១ លោក សុខ អាន ផ្ញើលិខិតអញ្ជើញទៅឲ្យលោក ហាន់ កូរ៉ែល ដើម្បីអញ្ជើញលោកមកប្រទេសកម្ពុជាក្នុងគោលបំណងបញ្ចប់ការសហប្រតិបត្តិការ ។

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់ឯកអគ្គរដ្ឋទូតអាមេរិក លោក ខេន វីដឺមេន ថា គាត់«ពិតជាចង់ចូលរួមក្នុងអង្គជំនុំជម្រះ» ដោយប្រើប្រាស់ច្បាប់ដែលមានការយល់ស្របពីរដ្ឋាភិបាលនិងឡាយព្រហស្តលេខាដោយសម្តេច សីហនុ កាលពីខែសីហា ។ រដ្ឋាភិបាលកម្ពុជាផ្ញើលិខិតអញ្ជើញទៅឲ្យអង្គការសហប្រជាជាតិ ដើម្បីបន្តពិភាក្សាអំពីការកាត់ទោសដើម្បីជំរុញឲ្យឆ្ពោះទៅដល់ទីបញ្ចប់ ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន នៅថ្ងៃទី១០ ខែតុលា លោក ហាន់ កូរ៉ែល ថ្លែងថា អង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភចំពោះបញ្ហាមួយចំនួន ។ ការព្រួយបារម្ភធំបំផុតគឺឯកសារច្បាប់ ឬក៏ការយល់ស្របគ្នារវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិដែលនឹងត្រួតពិនិត្យការគ្រប់គ្រងអង្គជំនុំជម្រះក្នុងករណីដែលមានភាពមិនយល់ស្របគ្នា ។

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចក្រភពអង់គ្លេសផ្តល់ជំនួយ៥សែនដុល្លារទៅឲ្យអង្គការសហប្រជាជាតិដើម្បីជាមូលនិធិជួយដល់ការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជា នេះគឺជាប្រទេសដំបូងដែលផ្តល់ជំនួយហិរញ្ញវត្ថុជាផ្លូវការទៅឲ្យតុលាការដែលបានគ្រោងទុក ។ ឯកអគ្គរាជទូតប្រទេសអង់គ្លេស លោក ស៊ីហ៊ុន ប្រ៊ីត្យ និយាយថា «ថ្មីៗនេះរដ្ឋាភិបាលអង់គ្លេសបានឲ្យប្រាក់៥សែនដុល្លារទៅឲ្យអង្គការសហប្រជាជាតិនៅឯញូវយ៉ក ដើម្បីជាជំនួយដល់ដំណើរកាត់ទោសខ្មែរក្រហមនៅកម្ពុជា» ។

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០១ ប្រទេសជប៉ុនមានគម្រោងរៀបចំឲ្យលោក គូនីជី ស៊ីបាហារ៉ា ដែលជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យហ្គាគីសឺអ៊ីនធ្វើជាចៅក្រមនៅអង្គជំនុំជម្រះ ។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក ហាន់ កូរ៉ែល លោក សុខ អាន ថ្លែងថា «ខណៈពេលដែលកិច្ចព្រមព្រៀងសហប្រតិបត្តិការប្រហែលជាមានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងច្បាប់និងមិនបានបរិយាយពីសេចក្តីលម្អិតជាក់លាក់មួយ តែយើងមិនអាចធ្វើការកែប្រែទេ ទុកឲ្យច្បាប់ដែលទើបតែត្រូវបានប្រកាសឲ្យប្រើនេះដំណើរការទៅមុខ» ។

លោក សុខ អាន ទទួលស្គាល់លិខិតនេះ ហើយធ្វើការកែប្រែសេចក្តីព្រាងច្បាប់នៃកិច្ចព្រមព្រៀងដោយថ្លែងថា ការឆ្លើយតបរបស់លោកនៅតែមិនទាន់ច្បាស់នៅឡើយទេ ។ គាត់បាននិយាយអំពីភាពមិនយល់ស្របគ្នាចំពោះកិច្ចព្រមព្រៀងផ្នែកច្បាប់ ។

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០១ កិច្ចចរចារវាងប្រទេសកម្ពុជានិងអង្គការសហប្រជាជាតិ ចំពោះការជ្រើសរើសភាសាផ្លូវការដើម្បីប្រើប្រាស់នៅក្នុងសវនាការអង្គជំនុំជំម្រះ ។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាដោះស្រាយសារាចរ ការរៀបចំជនងគ្រោះដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨) និងរៀបចំស្រុកអន្លង់វែងឲ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន លោក កូរ៉ែល បង្ហាញថា ការឆ្លើយតបដ៏ច្បាស់លាស់នឹងបញ្ជូនទៅ ប្រសិនបើកម្ពុជាបំពេញការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របាយការណ៍សន្និសីទរបស់អង្គការសហប្រជាជាតិ H.R.2506 កិច្ចប្រតិបត្តិការបរទេស ការនាំចេញហិរញ្ញវត្ថុ និងច្បាប់សមស្របកម្មវិធីដែលពាក់ព័ន្ធឆ្នាំ២០០២ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១) "លក្ខខណ្ឌជំនួយរបស់តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាចំពោះការសម្រេចចិត្តនិងការអះអាងដើម្បីធានាថា តុលាការមានលទ្ធភាពផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលក្ខណៈយុត្តិធម៌និងជឿទុកចិត្តបាន" ។

សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជា ជាតិលេខ UNGA A/RES/56/169 ជំពូក៨ : តុលាការខ្មែរក្រហម

កថាខណ្ឌទី២ : ស្វាគមន៍ចំពោះការប្រកាសឲ្យប្រើប្រាស់ច្បាប់ បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានកើតឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាមួយនឹងការពេញចិត្តនឹងបញ្ញត្តិទូទៅនិងច្បាប់ដ៏មានប្រសិទ្ធភាពព្រមទាំងតួនាទីដែលបានរៀបចំទុកឲ្យអង្គការសហប្រជាជាតិ ធ្វើឲ្យរដ្ឋាភិបាលកម្ពុជាធានាថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិព្រមទាំងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយកម្ពុជា ។ អ្នកទាំងនោះនឹងត្រូវយកទៅកាត់ទោស ដោយយុត្តិធម៌តាមបទដ្ឋានអន្តរជាតិ ភាពមិនលម្អៀង និងដំណើរការនីតិវិធីស្របច្បាប់ ។ នេះជំរុញឲ្យរដ្ឋាភិបាលបន្តសហការជាមួយអង្គការសហប្រជាជាតិទៅលើបញ្ហានេះ ។ ស្វាគមន៍ចំពោះ កិច្ចប្រឹងប្រែងរបស់លេខាធិការដ្ឋាន និងសហគមន៍អន្តរជាតិក្នុងការជួយឲ្យរដ្ឋាភិបាលឆ្ពោះទៅកាន់ទីបញ្ចប់នេះដែលជំរុញឲ្យរដ្ឋាភិ បាលនិងអង្គការសហប្រជាជាតិសម្រេចកិច្ចព្រមព្រៀងដោយមិនមានការពន្យារពេល ។ ទាំងនេះបានធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញ អាចចាប់ផ្តើមដំណើរការដោយ

ជោគជ័យនិងធ្វើឲ្យសហគមន៍អន្តរជាតិផ្តល់ជំនួយជាហិរញ្ញវត្ថុ និងឧបត្ថម្ភជាបុគ្គលិកទៅឲ្យអង្គជំនុំជម្រះ ។

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០២ មន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង បង្ហាញពីទុទិដ្ឋិនិយមទៅលើអង្គជំនុំជម្រះដោយមានហេតុផលថា "យោងទៅតាមអធិបតេយ្យភាពរបស់អង្គការសហប្រជាជាតិ ការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងមិនសង្ឃឹមថាអាចដំណើរការបានក្នុងពេលឆាប់ៗនេះទេ ពីព្រោះថា មេដឹកនាំខ្មែរក្រហមប្រហែលជាស្លាប់មុនពេលដែលអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលព្រមព្រៀងគ្នាដើម្បីបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ លោក សុខ អាន ផ្ញើលិខិតបីទំព័រទៅឲ្យអង្គការសហប្រជាជាតិ "ដើម្បីលុបបំបាត់ចម្ងល់ និងបង្ហាញច្បាស់លាស់" អំពីមុខងាររបស់រដ្ឋាភិបាលចំពោះការបង្កើតអង្គជំនុំជម្រះ ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ អគ្គលេខាធិការប្រាប់ឲ្យទីប្រឹក្សាច្បាប់របស់គាត់ លោក ហាន់ កូរ៉ែល បញ្ជូនលិខិតមួយច្បាប់ទៅកាន់រដ្ឋាភិបាលកម្ពុជា ដោយប្រាប់ថាអង្គការសហប្រជាជាតិនឹងមិនបន្តចរចាជាមួយរដ្ឋាភិបាលចំពោះការបង្កើតតុលាការពិសេសដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។ នៅក្នុងការសន្និបាតព័ត៌មានប្រចាំថ្ងៃ លោក កូរ៉ែល ថ្លែងការណ៍ថា "នៅក្នុងការណែនាំរបស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានឲ្យដឹងថា អង្គការសហប្រជាជាតិនឹងមិនបន្តចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្មនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យទេ" ។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០២ លោក សុខ អាន មានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាពិតជាសម្តែងការសោកស្តាយ ចំពោះការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិដែលបានប្រកាសកាលពីថ្ងៃទី៨ ខែកុម្ភៈ ។ "រដ្ឋាភិបាលកម្ពុជាកំពុងតែបើកទ្វាររង់ចាំធ្វើការពិភាក្សាបន្តទៅទៀត ។ យើងមិនទាន់បានបញ្ឈប់ការពិភាក្សាដូចលោក កូរ៉ែល ទេ" ។

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ សេចក្តីប្រកាសព័ត៌មានជាអន្តរជាតិចំពោះការលើកលែងទោសថ្លែងថា "សេចក្តីប្រកាស ដែលថាអង្គការសហប្រជាជាតិកំពុងតែដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីនាំយកអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរឲ្យសង្ស័យដែលរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនៅសម័យខ្មែរក្រហមយកមកកាត់ទោសគឺមិនមែនជាការភ្ញាក់ផ្អើលអ្វីទេ ។ លទ្ធផលការងារពិតនៅឆ្នាំនេះគឺប្រជាជនកម្ពុជានៅតែមិនទាន់ទទួលបានយុត្តិធម៌ ហើយនេះគឺជាសោកនាដកម្ម" ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន សុំឲ្យអង្គការសហប្រជាជាតិពិចារណាម្តងទៀតចំពោះការមិនពិភាក្សាទៅលើការនាំយកអតីត មេដឹកនាំខ្មែរក្រហមទៅកាត់ទោសដែលអាចធ្វើឲ្យពិភពលោកមិន«ធ្លាក់ក្នុងផ្លូវខុសម្តងទៀត» ក្រោមការដឹកនាំរបស់អ្នកគ្រប់គ្រងប្រទេស ។ លោកនាយករដ្ឋមន្ត្រីប្រាប់អ្នកសារព័ត៌មានថា ប្រទេសកម្ពុជាអាចរង់ចាំរយៈពេល«ពីរឬបីខែ» ដើម្បីឲ្យអង្គការសហប្រជាជាតិផ្លាស់ប្តូរការសម្រេចចិត្ត ប៉ុន្តែរដ្ឋាភិបាលនឹងមិនរង់ចាំជារៀងរហូតទេ ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ នៅក្នុងសេចក្តីថ្លែងការណ៍ឆ្លើយតបនឹងការប្រកាសដកខ្លួនរបស់អង្គការសហប្រជាជាតិចេញពីកិច្ចចរចាស្តីពីអង្គជំនុំជម្រះ លោក សុខ អាន មានប្រសាសន៍ថា «រាជរដ្ឋាភិបាលកម្ពុជា នៅតែព្យាយាមស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហមក្នុងនាមជាប្រជាជន កម្ពុជានិងមនុស្សជាតិ ។ យើងជឿថា ច្បាប់ដែលប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ បានឲ្យដឹងថា មូលដ្ឋាននៃដំណើរការនីតិវិធីមានទីតាំងនៅតុលាការកម្ពុជា ដោយមានការចូលរួមពីអន្តរជាតិនិងមានបទដ្ឋានអន្តរជាតិ ហើយយើងពិតជាសង្ឃឹមថាអង្គការសហប្រជាជាតិនឹងជាចំណែកមួយនៃដំណើរការនេះ» ។ សហរដ្ឋអាមេរិកជំរុញឲ្យអង្គការសហប្រជាជាតិកុំបោះបង់កិច្ចខំប្រឹងប្រែងចូលរួមក្នុងអង្គជំនុំជម្រះ ។

លោក សុខ អាន សរសេរលិខិតមួយទៅឲ្យលោក ហាន់ កូរ៉ែល បង្ហាញពីភាពសោកស្តាយចំពោះការប្រកាសដកខ្លួនចេញពីកិច្ចចរចារបស់អង្គការសហប្រជាជាតិ ហើយសង្ឃឹមថាអង្គការសហប្រជាជាតិនឹងងាកមកធ្វើការបញ្ចប់ក្នុងកិច្ចព្រមព្រៀងសហប្រតិបត្តិការ និងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០២ មេធាវីសុំឲ្យដោះលែង តា ម៉ុក បន្ទាប់ពីអង្គការសហប្រជាជាតិដកខ្លួនចេញពីដំណើរការកាត់ទោស ។ តា ម៉ុក អាយុ៧៥ឆ្នាំ ត្រូវបានឃុំខ្លួននៅឆ្នាំ១៩៩៩ នៅក្រុងភ្នំពេញ រង់ចាំការកាត់ទោសចំពោះតួនាទីរបស់គាត់នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ។ នៅក្រោមច្បាប់កម្ពុជា តា ម៉ុក ទទួលការចោទប្រកាន់ជាផ្លូវការ ហើយដោះលែងវិញនៅថ្ងៃទី៦ ខែមីនា ។

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ មេបញ្ជាការកងពលខ្មែរក្រហម កែ ពក អាយុ៦៨ឆ្នាំ ស្លាប់ដោយជំងឺលើសឈាម និងទឹកនោមផ្អែម ។ គាត់បានធ្វើដំណើរទៅប្រទេសថៃនៅខែមករា ដើម្បីធ្វើការព្យាបាល ក្រោយមកគាត់ក៏ដាច់សរសៃឈាម ហើយបញ្ជូនមកស្រុកអន្លង់វែងខាងជើងប្រទេសកម្ពុជាហើយស្លាប់នៅ ទីនោះ ។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ សហគមន៍អឺរ៉ុបជំរុញឲ្យអង្គការសហប្រជាជាតិកុំបោះបង់ការចរចាជាមួយកម្ពុជាស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហម ។

សមាជិករដ្ឋសភា១៨រូបរបស់គណបក្ស សម រង្ស៊ី សុំឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាលកំពូល២រូបទៀត បង្ហាញខ្លួននៅរដ្ឋសភាជាតិដើម្បីពន្យល់ពីមូលហេតុបរាជ័យក្នុងការចរចាជាមួយអង្គការសហប្រជាជាតិស្តីពីតុលាការកាត់ទោសខ្មែរ ក្រហម ។

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០២ យោងតាមសេចក្តីប្រកាសរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លេខ E/CN.4/2002/89 ចែងថា ៖

កថាខណ្ឌទី១៨ ៖ នឹងមានការស្នើទៅរដ្ឋាភិបាលកម្ពុជាដើម្បីធានាថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនឹងត្រូវយកមកកាត់ទោសចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ដើម្បីឲ្យស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងស្របទៅតាមនីតិវិធី ។ កិច្ចការនេះតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិសហការគ្នា ហើយអំពាវនាវដល់ភាគីទាំងពីរឲ្យធ្វើការពិភាក្សាឡើងវិញស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហម និងអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យផ្តល់ជំនួយការក្នុងការដោះស្រាយបញ្ហានេះ ។

នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ លោក កូហ្វី អាណាន់ និយាយថា ប្រទេសកម្ពុជាត្រូវតែផ្លាស់ប្តូរជំហររបស់ខ្លួនប្រសិនបើចង់ឲ្យអង្គការសហប្រជាជាតិជួយបង្កើតតុលាការឧក្រិដ្ឋកម្មសង្គ្រាមដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ឯកអគ្គរដ្ឋទូតចំនួន១២រូប បានមកជួបខ្ញុំនិយាយពីរឿងនេះហើយអ្នកទាំងនោះយល់ថា យើងគួរតែពិចារណាឡើងវិញ ។ ខ្ញុំបានណែនាំគេថា វានឹងមានប្រសិទ្ធភាពប្រសិនបើគេធ្វើសំណើទៅទីក្រុងភ្នំពេញ ហើយបញ្ចុះបញ្ចូលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យផ្លាស់ប្តូរជំហរ និងឥរិយាបថរបស់លោក ហើយផ្ញើសារជាក់លាក់មួយទៅគាត់ថា លោកនាយករដ្ឋមន្ត្រីចាប់អារម្មណ៍ទៅលើតុលាការដែលគួរឲ្យទុកចិត្តមួយ ស្របទៅតាមបទដ្ឋានអន្តរជាតិដែលនឹងត្រូវចាប់ផ្តើមនៅទីនោះ ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ ក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាសាលាក្តីខ្មែរក្រហមថ្លែងថា សេចក្តីថ្លែងការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ ឆ្លុះបញ្ចាំងពីការយល់ច្រឡំជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ច្បាប់ខ្មែរក្រហមដែលជាលទ្ធផលនៃការចរចាទាំងនោះផ្តល់ការត្រួតពិនិត្យ និងតុល្យភាពរវាងចំនួនសមាជិក និងអំណាចសម្រេចចិត្តរបស់ចៅក្រមកម្ពុជា និងបរទេសចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា ហើយផ្តល់ការធានាសិទ្ធិ

ស្របច្បាប់ឲ្យចុងចោទ ។ កម្ពុជាបានបង្ហាញឆន្ទៈដើម្បីរៀបចំឲ្យមានសិទ្ធិដែលចែងលម្អិតនៅក្នុងមាត្រា នៃកិច្ចសហប្រតិបត្តិការ ។ អង្គការសហប្រជាជាតិមិនបានរកឃើញការរំលោភបំពានដល់បទដ្ឋានដែលទទួល ស្គាល់ជាអន្តរជាតិណាមួយឡើយ នៅក្នុងច្បាប់ខ្មែរក្រហមរបស់កម្ពុជា ហើយក៏មិនបានឆ្លើយតប ទៅនឹងលិខិតរបស់រាជរដ្ឋាភិបាលកម្ពុជាដែលផ្ញើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ដែលនៅក្នុងនោះ ការឆ្លើយតបលម្អិតមួយផ្តោតលើការលើកឡើងចំនួន១១ចំណុចរបស់ឯកឧត្តម ហាន់ កូរ៉ែល ។

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០២ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា អង្គការសហប្រជាជាតិមានពេល៣ខែ ដើម្បីជជែកឡើងវិញជាមួយកម្ពុជាក្នុងការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ លោកបានថ្លែងថា បើការជជែកនោះមិនលេចរូបរាងតាមពេលកំណត់កម្ពុជានឹងពិចារណានូវជម្រើសដទៃទៀត ដែលអាចជាសាលាក្តីជួយដោយបរទេស ឬសាលាក្តីខ្មែរទាំងស្រុង ដើម្បីនាំយកយុត្តិធម៌ជូនជនរងគ្រោះ១លាន៧សែននាក់ ដែលបានស្លាប់ក្រោមអំពើដ៏សាហាវឃោរ ឃៅនៃអ្នកប្រកាន់លទ្ធិម៉ៅជ្រុលហួសហេតុ ។ ខ្ញុំចង់ប្រកាសម្តងទៀតថា ទ្វារនៅតែបើកចំហរយៈពេល៣ខែទៀត ។ ភាពអត់ធ្មត់របស់យើងមានដែនកំណត់ ។ យើងមិនចង់ឲ្យនរណាម្នាក់ដើរចេញទេ យើងចង់ឲ្យគេចូលរួម ។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០២ ទីក្រុងញូដែលីសន្យាបន្តការគាំទ្រដល់សាលាក្តីចម្រុះខ្មែរក្រហម បើអង្គការសហប្រជាជាតិដកខ្លួនចេញជាអចិន្ត្រៃយ៍ ។ ពេលធ្វើទស្សនកិច្ចនៅកម្ពុជា នាយករដ្ឋមន្ត្រីឥណ្ឌា អាតាល់ ប៊ីហារី វ៉ាជ៉ាយី បានសន្យាថា ឥណ្ឌានឹងបញ្ជូនចៅក្រមសម្រាប់សាលាក្តីប្រសិនបើអង្គការសហប្រជាជាតិនៅតែរក្សាការសម្រេចចិត្តដកខ្លួនចេញ ។

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០២ នាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហាញឆន្ទៈសម្រុះសម្រួលដើម្បីចាប់ផ្តើមការចរចាដែលជាប់គាំងឡើងវិញ ។ លោកបានផ្តល់ការធ្វើវិសោធនកម្មច្បាប់សាលាក្តី ។

នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០២ បេសកជនផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ភិទើ ឡឺប្រិច បង្ហាញក្តីសង្ឃឹមថា សាលាក្តីនឹងដំណើរការទៅមុខ ហើយនិយាយថា ប្រទេសជាមិត្តមួយចំនួនបន្តព្យាយាមឲ្យរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ រួមគ្នាពិភាក្សាពីសាលាក្តីរួមមួយ ។ អង្គការសហប្រជាជាតិបដិសេធការស្នើសុំរបស់កម្ពុជាដើម្បីបង្កើតគម្រោងសម្រាប់សាលាក្តី ដែលជាប់គាំងនោះឡើងវិញ ដោយនិយាយថា ខ្ញុំចង់បានការធានាបន្ថែមថាកម្ពុជានឹងធ្វើការកាត់ទោសមេដឹកនាំ វាលពិឃាត ដោយយុត្តិធម៌ ។

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ លិខិតមួយច្បាប់ពី លោក កូហ្វី អាណាន់ ជូនសម្តេច ហ៊ុន សែន មានខ្លឹមសារថា "ការសម្រេចចិត្តបញ្ចប់ការចរចានៅថ្ងៃទី៨ ខែកុម្ភៈ គឺដោយសារតែ

ការិយាល័យដែលខ្ញុំបានផ្តល់ជូនមិនទាន់ចេញជាលទ្ធផល» ហើយថា «ដើម្បីឲ្យខ្ញុំចូលរួមការចរចាទៀត ខ្ញុំត្រូវការការប្រគល់សិទ្ធិពីមហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខ។ ប្រសិនការប្រគល់សិទ្ធិត្រូវបានផ្តល់ឲ្យ ខ្ញុំនឹងរៀបចំខ្លួនចូលរួមការជជែកជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបញ្ចប់កិច្ចការនេះ»។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០២ លិខិតមួយច្បាប់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ជូនលោក កូហ្វី អាណាន់ ថ្លែងថា យើងរង់ចាំការសន្និដ្ឋានបន្ទាន់មួយ ដោយសារលោកគិតថា វាចាំបាច់សម្រាប់អង្គការសហប្រជាជាតិដើម្បីវិលត្រឡប់ទៅតុពិភាក្សា ដូច្នេះយើងអាចសន្និដ្ឋានការចរចាជាមួយនឹងកិច្ចព្រមព្រៀងដែលបំពេញចិត្តភាគីទាំងពីរ ហើយបន្ទាប់មកបន្តការពិភាក្សាអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២ លោក អាណាន់ ប្រាប់កម្ពុជាថា លោកនឹងធ្វើការជជែកឡើងវិញស្តីពីការកាត់ទោសអំពើប្រល័យពូជសាសន៍ ប្រសិនបើរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចង់ឲ្យលោកធ្វើ។ លោកបានសរសេរទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា ដើម្បីឲ្យគាត់ចូលរួមការចរចា គាត់ត្រូវការការប្រគល់សិទ្ធិច្បាស់លាស់ពីមហាសន្និបាត ឬក្រុមប្រឹក្សាសន្តិសុខ។

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០២ កិច្ចប្រជុំនៅទីក្រុងញូវយ៉ករៀបចំដោយជប៉ុនដែលប្រារព្ធនៅទីស្នាក់ការគណៈកម្មាធិការជប៉ុនដោយមានការចូលរួមពីប្រទេសចាប់អារម្មណ៍ រួមមាន បារាំង ចក្រភពអង់គ្លេស កាណាដា អូស្ត្រាលី សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប កូរ៉េខាងត្បូង ជប៉ុន និងប្រទេសអាស៊ាន ហ្វីលីពីន សិង្ហបូរី ថៃ ឥណ្ឌូនេស៊ី និងកម្ពុជា។ ជាការប្រជុំលើកដំបូងដើម្បីផ្លាស់ប្តូរយោបល់អំពីអ្វីដែលសហគមន៍អន្តរជាតិអាចធ្វើដើម្បីចរចាឡើងវិញ។

នៅថ្ងៃទី២១ ខែវិច្ឆិការ ឆ្នាំ២០០២ មហាសន្និបាតរបស់អង្គការសហប្រជាជាតិអនុម័តនូវដំណោះស្រាយដែលស្នើឲ្យអគ្គលេខាធិការធ្វើការចរចាឡើងវិញដោយគ្មានការពន្យារពេលដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជាផ្អែកលើការចរចាពីមុន និងដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញស្របតាមវិធាននៃដំណោះស្រាយបច្ចុប្បន្ន ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមធ្វើការបានឆាប់រហ័ស។ ដំណោះស្រាយត្រូវបានអនុម័តដោយមានសំឡេងចំនួន៣៩អនុបវាទ។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០២ លោក ខៀវ សំផន និយាយថា មេដឹកនាំខ្មែរក្រហមថ្នាក់លើដទៃទៀតត្រៀមខ្លួនផ្តល់ភ័ស្តុតាងស្តីពីការផ្លាស់ប្តូរក្នុងនៃរបបម៉ៅជ្រុលនិយមដ៏អាថ៌កំបាំងនេះ ដែលដឹកនាំដោយបងធំទី១ ប៉ុល ពត ប្រសិនបើគណៈកម្មាធិការស្វែងរកការពិតបែបអាហ្វ្រិកខាងត្បូងត្រូវបានបង្កើតឡើង។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា រដ្ឋាភិបាលរបស់លោកកំពុងរង់ចាំការអនុម័តដំណោះស្រាយនៅសប្ដាហ៍ខាងមុខ ។ អ្វីដែលយើងព្រួយបារម្ភ គឺការរស់រានរបស់ប្រជាជនកម្ពុជាដែលរួចផុតពីកណ្ដាប់ដៃរបស់ ប៉ុល ពត ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ អង្គការសហប្រជាជាតិអនុម័តការប្រគល់សិទ្ធិដែលតម្រូវឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ត្រឡប់ទៅតុចរចាពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជាវិញ ។ ដំណោះស្រាយតម្រូវឲ្យលោក អាណាន់ ជជែកសាជាថ្មី ដោយគ្មានការពន្យារពេលដែលអនុម័តដោយការបោះឆ្នោតដែលមានសំឡេងចំនួន១៥០យល់ព្រមនិង៣០អនុបវាទ ។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ បែនសុន សម័យ មេធាវីរបស់ តាម៉ុក ស្នើឲ្យដោះលែងកូនក្ដីគាត់ជាបណ្ដោះអាសន្ន ដោយសំអាងលើបញ្ហាសុខភាព និងមនុស្សធម៌ ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២ សម្ដេចក្រុមព្រះនរោត្ដម រណឫទ្ធិ មានព្រះបន្ទូលថា រដ្ឋាភិបាលត្រូវតែធ្វើសម្បទានដល់អង្គការសហប្រជាជាតិ ប្រសិនបើចង់ឲ្យការជជែកពីសាលាក្ដីខ្មែរក្រហមដំណើរការទៅមុខ ។ ទាំងអង្គការសហប្រជាជាតិ និងកម្ពុជាបានដឹងពីជំហររបស់គ្នារួចហើយ ។ បើយើងត្រឡប់ទៅជជែកពីទិដ្ឋភាពដដែល ដែលជាជំហរនាំឲ្យយើងជាប់គាំងដូចមុនយើងអាចនឹងគ្មានការចរចា ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០៣ ជាការឆ្លើយតបនឹងការអញ្ជើញរបស់អគ្គលេខាធិការគណប្រតិភូមួយក្រុមរបស់កម្ពុជា ដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី សុខ អាន បានទៅដល់ក្រុងញូវយ៉ក និងរៀបចំធ្វើកិច្ចប្រជុំចំនួន៧លើកទីមួយ ៖ ជួបជាមួយលោកអគ្គលេខាធិការនិងចំនួន៦លើកទៀត ជួបជាមួយតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិដែលដឹកនាំដោយ លោក ហាន់ កូរ៉ែល ដើម្បីរៀបចំការចរចាឡើងវិញសម្រាប់ការកាត់ទោសខ្មែរក្រហមស្របតាមដំណោះស្រាយរបស់មហាសន្និបាត លេខ ៥៧,២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងកម្ពុជាសម្រេចកិច្ចព្រមព្រៀងដើម្បីបង្កើតតុលាការប្រល័យពូជសាសន៍ពិសេសមួយសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ ក្រុមអ្នកច្បាប់របស់អង្គការសហប្រជាជាតិ និងកម្ពុជាបានយល់ព្រមនិងគាំទ្រមាត្រានៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងរដ្ឋសភាជាតិកម្ពុជាមុនពេលការងារអាចបន្តធ្វើដើម្បីបង្កើតតុលាការមួយ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣ ស្ថានទូតចក្រភពអង់គ្លេស នៅទីក្រុងភ្នំពេញបានចេញសេចក្ដីប្រកាសព័ត៌មានមួយស្វាគមន៍ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងសម្ដែងការប្ដេជ្ញាចិត្តបន្តគាំទ្រតុលាការដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិ ។ ជាការផ្ដល់មតិលើកិច្ចព្រមព្រៀង រដ្ឋមន្ត្រី

ក្រសួងការបរទេស ម៉ៃ អូប្រៀន មានសុទិដ្ឋិនិយមថា នៅទីបំផុតសាលាក្តីនឹងលាតត្រដាងសម័យកាលសោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជានៅពេលថ្មីៗ និងនាំយកអ្នកដែលទទួលខុសត្រូវសំខាន់ជាងគេដែលប្រព្រឹត្តអំពើព្រៃផ្សៃក្រោមរបបខ្មែរក្រហមមកឲ្យតុលាការជំនុំជម្រះ ។ វានឹងផ្តល់"កាសមួយដល់ប្រជាជនកម្ពុជាអស់ចិត្តនឹងរឿងអតីតកាល ហើយដើរទៅរកការផ្សះផ្សាជាតិឡើងវិញ ។

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៣ អង្គការលើកលែងទោសអន្តរជាតិនិយាយថា មានការព្រួយបារម្ភយ៉ាងខ្លាំងពីបទបញ្ញត្តិនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង «ដែលឆ្លុះបញ្ចាំងពីភាពផ្ទុយគ្នារវាងច្បាប់និងបទដ្ឋានអន្តរជាតិនាពេលបច្ចុប្បន្ន» ។ មានការអះអាងថា កិច្ចព្រមព្រៀងមានភាពខ្វះចន្លោះច្រើនដែលរារាំងមិនឲ្យអង្គការសហប្រជាជាតិចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះ ដរាបណាមានការត្រួតពិនិត្យឡើងវិញយ៉ាងត្រឹមត្រូវ ។ ទោះជាយ៉ាងនេះក្តី សេចក្តីព្រាងបទបញ្ញត្តិដែលអង្គការលើកលែងទោសអន្តរជាតិស្វាគមន៍នឹងមិនរាប់បញ្ចូលការលើកលែងទោស ឬអនុគ្រោះ ទោសនរណាម្នាក់ដែលត្រូវធ្វើការស៊ើបអង្កេតឬចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលមានក្នុងកិច្ចព្រមព្រៀងឡើយ ។ ខ-មួយដែលបានអនុវត្តចំពោះអ្នកដែលត្រូវផ្តល់ការលើកលែងទោសដោយអាជ្ញាធរកម្ពុជា (សេចក្តីព្រាងច្បាប់មាត្រា១១) បទបញ្ញត្តិដែលបណ្តឹងទាំងអស់ត្រូវធ្វើឡើងជាសាធារណៈ (សេចក្តីព្រាងមាត្រា១២.២) និងការមិនរួមបញ្ចូលទោសប្រហារជីវិត (មាត្រា១០) ដែលស្របតាមច្បាប់អន្តរជាតិដទៃទៀត ។

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រីកម្ពុជា យល់ព្រមចំពោះសេចក្តីព្រាងនៃកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ អគ្គលេខាធិការអង្គការសហប្រជាជាតិចេញរបាយការណ៍មួយលេខ (A/57/769) នៅឯមហាសន្និបាត ដោយធ្វើការរិះគន់ទៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ។ លោកបានប៉ាន់ប្រមាណថា អង្គជំនុំជម្រះវិសាមញ្ញអាចនឹងចំណាយជាង១៩លានដុល្លារ ដូច្នេះលោកបានស្នើមូលនិធិ រួមរបស់អង្គការសហប្រជាជាតិឲ្យផ្តល់វិភាគទានកំណត់ដែលមិនមែនជាការស្ម័គ្រចិត្ត ។

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការទីបីនៃ មហាសន្និបាតអង្គការសហប្រជា-ជាតិអនុម័តលើដំណោះស្រាយ ដោយយល់ស្របចំពោះកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក្រោមច្បាប់របស់កម្ពុជា ។

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការទីបី អនុម័តដំណោះស្រាយដោយយល់ស្របនឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ហើយថ្លែងថា អង្គការសហប្រជាជាតិគួរតែផ្តល់មូលនិធិទៅអង្គជំនុំជម្រះវិសាមញ្ញដោយវិភាគទានស្ម័គ្រចិត្ត ។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ កិច្ចប្រជុំពេញអង្គលើកទី៨៥ នៃមហាសន្និបាតលើកទី៥៧ អនុម័តដំណោះស្រាយលេខ57/228B ដោយយល់ព្រមចំពោះសេចក្តីព្រាងនៃកិច្ចព្រមព្រៀង និងវិភាគទានស្ម័គ្រចិត្ត ។

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចុះហត្ថលេខានៅឯសាលមហោស្រពចតុមុខក្រុងភ្នំពេញ ។

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាដាក់ជូនកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យក្រោមច្បាប់របស់កម្ពុជាទៅរដ្ឋសភាជាតិ ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ ប្រទេសអូស្ត្រាលី សន្យាផ្តល់ប្រាក់១លាន៥សែនដុល្លារអូស្ត្រាលី សម្រាប់អង្គជំនុំជម្រះវិសាមញ្ញបន្ថែមលើទឹកប្រាក់២៦៦,០០០ដុល្លារអូស្ត្រាលី ដែលបានផ្តល់ក្នុងទម្រង់ជាជំនួយបច្ចេកទេសទាក់ទងនឹងការកាត់ទោសខ្មែរក្រហម ។

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣ លោកស្រី ខៀវ ប៉ុណ្ណារី ប្រពន្ធទីមួយរបស់អតីតមេដឹកនាំខ្មែរក្រហម ប៉ុល ពត ស្លាប់ក្នុងអាយុ៨៣ឆ្នាំ នៅទីក្រុងប៉ៃលិន ។

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៣ ឯកសាររាប់ពាន់សន្លឹកអះអាងពីអំពើឃោរឃៅដែលធ្វើឡើងដោយខ្មែរក្រហមត្រូវបានបញ្ជូនទៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសបារាំង បន្ទាប់ពីមានការគំរាមកំហែងផ្នែកសន្តិសុខជាបន្តបន្ទាប់ ។ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ និយាយថា ភ័ស្តុតាង ប្រមាណ៧០ភាគរយត្រូវបានរក្សាយ៉ាងមានសុវត្ថិភាពនៅប្រទេសទាំងនោះ ។

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៣ បន្ទាប់ពីសិក្សាគម្រោងរយៈពេល៣ឆ្នាំសម្រាប់សាលាក្តី អង្គការសហប្រជាជាតិយល់ព្រមថា ការចំណាយគួរតែអស់៤០លានដុល្លារ ។ លោក ឱម យិនទៀង ទីប្រឹក្សានាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាសមាជិកក្រុមការងារសាលាក្តីបាននិយាយថា អង្គការសហប្រជាជាតិស្នើលុយចំនួន២០លានដុល្លារ ចំណែកកម្ពុជាចំណាយ២០លានដុល្លារ ។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៣ សភាសហរដ្ឋអាមេរិកអនុម័តដំណោះស្រាយមួយលេខ (H. CON. RES. 83) ដោយគោរពដល់ជនរងគ្រោះនៃសម័យខ្មែរក្រហម ។ ដំណោះស្រាយបញ្ជាក់ថា សហរដ្ឋអាមេរិកប្តេជ្ញាបន្តស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ សមាជិកសភាសហរដ្ឋអាមេរិក លោក

ដាណា រ៉ូរ៉ាបាឆឺ និយាយថា ដំណោះស្រាយនេះជាសញ្ញានៃការទទួលស្គាល់នូវតួនាទីរបស់អាមេរិកក្នុងជម្លោះនៅឥណ្ឌូចិនពេលដែលរបបខ្មែរក្រហមបានឡើងកាន់អំណាច ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៣ លោក ខាស្តែន ហ៊ែរែល ប្រធានក្រុមរៀបចំសាលាក្តីដែលមានសមាជិក៥នាក់និយាយថា ទាំងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាកំពុងចាប់ផ្តើមធ្វើការសន្មតថា អង្គជំនុំជម្រះវិសាមញ្ញនឹងចាប់ប្រតិបត្តិការងារនៅឆ្នាំ២០០៤ ។

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ លោក កូហ្វី អាណាន់ និយាយថា ដំណើរការនៃការបង្កើតសាលាក្តីនឹងចាប់ផ្តើមបានលុះត្រាតែការសន្យាសម្រាប់រយៈពេល៣ឆ្នាំដំបូងនៃប្រតិបត្តិការរបស់តុលាការត្រូវបានទទួលស្គាល់ ហើយទឹកប្រាក់សម្រាប់ប្រតិបត្តិការឆ្នាំដំបូងត្រូវបានតម្កល់គ្រប់គ្រាន់នៅក្នុងមូលនិធិរួម ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣ នាយកគម្រោងអ្នកការពារក្តីកម្ពុជាមានប្រសាសន៍ថា លោក ខៀវ សំផន គណៈប្រធានរដ្ឋសម័យខ្មែរក្រហមបានមកការិយាល័យរបស់គាត់ ដើម្បីស្វែងរកជំនួយផ្នែកច្បាប់នៃគម្រោងសាលាក្តីកាលពីដើមឆ្នាំនេះ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៣ ប្រទេសអូស្ត្រាលីចេញសេចក្តីថ្លែងការណ៍ថា នឹងផ្តល់ប្រាក់ ២លាន ១សែនដុល្លារ សម្រាប់តុលាការចម្រុះកម្ពុជា និងអន្តរជាតិ ។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ ស្របតាមការអំពាវនាវសុំ ជំនួយផ្នែកច្បាប់របស់លោក ខៀវ សំផន អ្នកជិតដិតរបស់គាត់ ដែលជាអ្នកបដិវត្តន៍ដូចគ្នា លោក នួន ជា និយាយថា គាត់នឹងតំណាងឲ្យខ្លួនគាត់ ប្រសិនបើគាត់ត្រូវកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍វិញ ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ នៅក្នុងលិខិតចំហមួយច្បាប់ លោក ខៀវ សំផន បដិសេធការរួមចំណែកក្នុងការសម្លាប់ប្រជាជនខ្មែរជាង១លាននាក់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិប-តេយ្យ ប៉ុន្តែគាត់សារភាពថារបបនេះបានធ្វើការសម្លាប់ជាប្រព័ន្ធ ។

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤ ក្រុមអ្នកច្បាប់របស់អង្គការសហប្រជាជាតិមកដល់ប្រទេសកម្ពុជា ដើម្បីរៀបចំគម្រោងសម្រាប់សាលាក្តីមុនពេលប្រគល់សំណើសុំថវិកាទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ សម្តេចព្រះនរោត្តម សីហនុ មានព្រះទ័យទិតៀនចំពោះការបោះពុម្ពផ្សាយចម្លើយកសិណសាក្សីរបស់អតីតមេដឹកនាំខ្មែរក្រហម ដែលក្នុងនោះបានអះអាងថាពួកគេគ្មានទោសពីបទប្រព្រឹត្តអំពើឃោរឃៅនៅក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ឡើយ ។ ដោយ

ហៅឧក្រិដ្ឋកម្មនោះថា "អាក្រក់ណាស់" សម្តេចព្រះ នរោត្តម សីហនុ បានអះអាងថា បើមេដឹកនាំខ្មែរក្រហមត្រូវបានប្រកាសជាសាធារណៈថាគ្មានទោសកំហុសមេដឹកនាំទាំងនេះក៏មិនចាំបាច់មានការលើកលែងទោសចំពោះបទឧក្រិដ្ឋនោះដែរ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ លោក ខាស្តែន ហ៊ែវែល ប្រធាននៃគណៈប្រតិភូអង្គការសហប្រជាជាតិនិយាយថា ក្នុងអំឡុងបេសកកម្មលើកទីពីរមកទីក្រុងភ្នំពេញ ដើម្បីរៀបចំការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលសាលាក្តីនឹងចំណាយអស់ថវិកាយ៉ាងច្រើន គឺ៥០លានដុល្លារ ។ ហ៊ែវែល បានបដិសេធមិនផ្តល់នូវតួលេខថវិកាច្បាស់លាស់ដោយនិយាយថា ធាតុពិតនៃការចំណាយខ្លះមិនត្រូវបានដឹងទាំងស្រុងនោះទេ ។

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ កិច្ចប្រជុំសភាអាមេរិក លើកទី១០៨(2nd Session-H.CON.RES.399) ដោយមានការដោះស្រាយពីតំណាងរដ្ឋសភានៅក្នុងកិច្ចប្រជុំនេះគឺ ទីមួយ ៖ ជំរុញឲ្យប្រធានាធិបតីលើកទឹកចិត្តសភាជាតិកម្ពុជាឲ្យផ្តល់សច្ចាប័នចំពោះកិច្ចព្រមព្រៀងរវាងអង្គការសហ-ប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតសាលាក្តីមួយដែលជាអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនិងកាត់-ទោសមេដឹកនាំនៅមានជីវិតក្នុងរបបខ្មែរក្រហមដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សចាប់ពីថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និងទីពីរ ៖ ជំរុញឲ្យប្រធានាធិបតីផ្តល់ការគាំទ្រក្នុងការបង្កើត និងការផ្តល់ថវិកាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញស្របតាមច្បាប់យុត្តិធម៌ ដើម្បីប្រឆាំងនឹងអំពើប្រល័យពូជសាសន៍កម្ពុជា ។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៤ នៅទីក្រុងឡុងប៊ិច អ្នកច្បាប់កាលីហ្វនីញ៉ាទទូចដល់ប្រជា-ធិបតី ប៊ូស ឲ្យជួយផ្តល់មូលនិធិសម្រាប់សាលាក្តី ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅមានជីវិត ។ សមាជិកសភា ជូនីតា មីលែនដឺ ម៉ាកដូណាល់ និង ដាណា រ៉ូរ៉ាប៉ាឆឺ អ្នកទាំងពីរតំណាងឲ្យសហគមន៍មួយក្នុងចំណោមសហគមន៍កម្ពុជាធំជាងគេបាននិយាយថា យុត្តិធម៌សម្រាប់អ្នកនៅរស់រានពីសម័យខ្មែរក្រហមហួសពេលកំណត់ហើយ ។

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៤ អ្នកដឹកនាំពលរដ្ឋ១៧នាក់ និងសមាជិកសភាចុះហត្ថលេខាលើញត្តិមួយសុំឲ្យព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ចេញដីកាចាប់ខ្លួនមេដឹកនាំខ្មែរក្រហមកំពូលដែលនៅរស់៣នាក់ ។

នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៤ រដ្ឋមន្ត្រីក្រសួងការបរទេស សហរដ្ឋអាមេរិក ខូលីន ផូវែល និយាយថា ចៅក្រមអន្តរជាតិអាចនឹងផ្តល់ការជឿទុកចិត្តចំពោះសាលាក្តីកាត់ទោសមេដឹកនាំខ្មែរ

ក្រហម ។ លោក ដូវែល កំពុងធ្វើជាសាក្សីនៅក្នុងសវនាការនៅកិច្ចប្រជុំសភា ដែលក្នុងនោះសមាជិកសភាម្នាក់បានសួរថា ហេតុអ្វីបានជាសហរដ្ឋអាមេរិកគាំទ្រសាលាក្តីខ្មែរក្រហមដែលខុះចន្លោះ ហើយផ្អែកលើប្រព័ន្ធច្បាប់ដ៏ទន់ខ្សោយ ។ ខ្ញុំមានការព្រួយបារម្ភ ដូចដែលអ្នកមានអំពីអត្ថិភាពនៃយុត្តិធម៌ ទោះបីជាប្រជាជនខ្មែរអាចនឹងមិនចង់បានយុត្តិធម៌ដូចដែលយើងចង់បានក៏ដោយ ។ ប៉ុន្តែយើងនឹងមានចៅក្រមអន្តរជាតិក្នុងតុលាការ ឬយ៉ាងហោចណាស់កូនក្តីចាស់ៗទាំងនោះនឹងត្រូវបាននាំខ្លួនទៅកាន់សាលាក្តី ។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៤ អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍សុំឲ្យព្រះរាជអាជ្ញាខេត្តបាត់ដំបង ខេត្តបន្ទាយ- មានជ័យ និងខេត្តសៀមរាប នាំពាក្យបណ្តឹងប្រឆាំងលោក ខៀវ សំផន និង នួន ជា ហើយសុំឲ្យអង្គចៅក្រមចេញដីកាស្របតាមច្បាប់សវនាការ ។ ចំពោះលោក អៀង សារី ចាំបាច់ត្រូវត្រួតពិនិត្យព្រះរាជក្រឹត្យលើកលែងទោស ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ សម្តេចព្រះ នរោត្តម សីហនុ កត់សម្គាល់ក្នុងខួបលើកទី ២៩ ដែលក្រុងភ្នំពេញធ្លាក់ក្នុងដៃខ្មែរក្រហមដោយអំពាវនាវឲ្យមានការកប់អដ្ឋិធាតុជនរងគ្រោះនៃរបបពិឃាដនិងបោះបង់ចោលសាលាក្តីគាំទ្រដោយអង្គការសហប្រជាជាតិដែលត្រូវបានស្នើឡើង ។ ព្រះអង្គទ្រង់លិខិតជាភាសាខ្មែរថា «យើងជាពុទ្ធសាសនិកជនដែលមានជំនឿ និងប្រពៃណីកប់សាកសព ហើយនាំយកផ្នែកនៅសល់ទៅដាក់ក្នុងចេតិយនៅវត្តតាំងពីបុរាណមក ។ ព្រះអង្គក៏បានតិទៀនដែរថា«សាលាក្តីខ្មែរក្រហមគ្រាន់តែជាការតិះដៀលដល់ជនរងគ្រោះដែលបានស្លាប់ទៅប៉ុណ្ណោះ» ។ ព្រះអង្គបញ្ជាក់ថា «សហគមន៍អន្តរជាតិនិងអង្គការសហប្រជាជាតិ ផ្តល់មូលនិធិជាច្រើនសម្រាប់ដំណើរការសាលាក្តីនេះ ។ ខ្ញុំរំពឹងថា នេះគ្រាន់តែជារឿងកំប្លែងនិងជាការតិះដៀលដល់ព្រលឹងជនរងគ្រោះប៉ុណ្ណោះ» ។

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ ក្នុងសារមួយក្នុងគេហទំព័ររបស់ព្រះអង្គ សម្តេចព្រះ នរោត្តម សីហនុ មានព្រះបន្ទូលថា សាលាក្តីខ្មែរក្រហមមិនអាចធ្វើការបានត្រឹមត្រូវ ប្រសិនបើសាលាក្តីនេះមិនធ្វើនៅទីក្រុងឡាអេ ដោយសារប្រព័ន្ធច្បាប់អសមត្ថភាព ។ ពិភពលោកទាំងមូលរួមទាំងសារព័ត៌មានដែលខ្ញុំបានអានជាទៀងទាត់វាយតម្លៃថា អង្គចៅក្រមពុករលួយនិងគ្មានសមត្ថភាព ។

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៤ លោក ខៀវ សំផន ចេញលិខិតចំហមួយសំដែងពីមតិសាធារណៈចំពោះរូបព្រះអង្គនិងថ្លែងថា ព្រះអង្គទទួលការចាប់អារម្មណ៍ពីប្រជាជនខ្មែរជាច្រើន ។ ជនរួមជាតិកាន់តែច្រើនរួមទាំងព្រះសង្ឃផងបានសំដែងការអាណិតចំពោះខ្ញុំ ហើយខ្ញុំមិនចាំបាច់និយាយអ្វីគ្រប់យ៉ាងដែលអ្នកដទៃបានប្រាប់ខ្ញុំតាមផ្លូវដោយស្នាមញញឹមថាពួកគាត់បានអានសៀវភៅរបស់ខ្ញុំ ។

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ សម្ដេចព្រះ នរោត្ដម សីហនុ ចេញព្រះរាជសារមួយ ច្បាប់ក្នុងគេហទំព័ររបស់ព្រះអង្គថា ព្រះអង្គចង់ធ្វើជាសាក្សីនៅឯសាលាក្ដីខ្មែរក្រហម ។ ខ្ញុំធ្វើជាសាក្សី នៅមុខតុលាការមិនត្រឹមតែម្ដងនោះទេ តែគ្រប់ពេលដែលតុលាការបើកសវនាការសួរចម្លើយអ្នកនេះ និងអ្នកនោះរាល់ថ្ងៃ រាល់សប្ដាហ៍ រាល់ខែ រាល់ឆ្នាំដែលខ្ញុំនៅមានជីវិត ។

នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់កម្ពុជា លោក គាត ឈន់ មានប្រសាសន៍ថា គាត់ស្ម័គ្រចិត្តបង្ហាញមុខធ្វើជាសាក្សីនៅឯសាលាក្ដីគាំទ្រដោយអង្គការ សហប្រជាជាតិដែលត្រូវបានធ្វើឡើង ។ គាត់ថ្លែងថា គាត់នឹងធ្វើជាសាក្សីដើម្បីការពារឈ្មោះគាត់ ប្រសិនបើសាលាក្ដីសម្រេចចោទគាត់ពីបទចូលរួមជាមួយខ្មែរក្រហម ។ រដ្ឋមន្ត្រីដែលទទួលការអប់រំនៅ ប្រទេសបារាំងដើម្បីបម្រើជាអ្នកបកប្រែឲ្យលោក ប៉ុល ពត ដែលបានដឹកនាំចលនាតស៊ូក្នុងពាក់ កណ្ដាលទសវត្សរ៍ឆ្នាំ១៩៨០ ។

នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ ឧបនាយករដ្ឋមន្ត្រី ស ខេង យល់ស្របចំពោះការ បង្កើតគណៈកម្មាធិការពិសេសមួយ ដើម្បីធានាសុវត្ថិភាពអ្នកចូលរួមក្នុងសាលាក្ដី ។ គណៈកម្មាធិការ នេះនឹងត្រូវដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក ឯម សំអាន និងអនុប្រធានជាច្រើន រូបទៀតរួមមាន លោក មៅ ចាន់ដារ៉ា អគ្គនាយករងនគរបាលជាតិ លោក ប៉ុល សារឿន មេបញ្ជា ការរងកងយោធពលខេមរភូមិន្ទ លោក នេត សាវឿន អគ្គនាយករងនគរបាលជាតិ និង លោក នៅ សំ នាយសេនាធិការរងនៃកងយោធពលខេមរភូមិន្ទ ។ គណៈកម្មាធិការពិសេសនេះក៏មានតំណាងម្នាក់ មកពីក្រសួងហិរញ្ញវត្ថុ និងតំណាងអភិបាលខេត្ត-ក្រុង ព្រមទាំងសាក្សីនិងជនសង្ស័យរស់នៅទីនោះ ចូលរួមផងដែរ ។

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៤ ព្រះរាជអាជ្ញាមកពីខេត្តបន្ទាយមានជ័យ បាត់ដំបង និង សៀមរាប ព្រងើយកន្តើយចំពោះដីកាសាលាឧទ្ធរណ៍ដែលឲ្យចាប់ខ្លួនមេដឹកនាំខ្មែរក្រហម លោក ខៀវ សំផន និង នួន ជា ។ លោក យ៉ឹម យ៉េត ព្រះរាជអាជ្ញាខេត្តបាត់ដំបងបាននិយាយថា គាត់បានទទួល ដីកានៅថ្ងៃទី៩ ខែមេសា រួចហើយ ប៉ុន្ដែគាត់មិនទាន់ធ្វើសកម្មភាពទេ ។ មានតែចៅក្រមពិសេសរបស់ សាលាក្ដីខ្មែរក្រហម និងអន្តរជាតិប៉ុណ្ណោះដែលអាចចេញដីកាចាប់ខ្លួនបាន ។ លោក សូ វ៉ា ព្រះរាជ-អាជ្ញាខេត្តសៀមរាបក៏បានអះអាងដែរថា គាត់បានទទួលដីកាពីអគ្គព្រះរាជអាជ្ញាហើយ ប៉ុន្ដែគាត់ខ្វះ ភ័ស្ដុតាងដែលជាឯកសារប្រឆាំងនឹងអតីតមេដឹកនាំទាំងនោះ និងនីតិវិធីស៊ើបអង្កេតពួកគេ ។ លោក ឪម យិនទៀង ទីប្រឹក្សានាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាអនុប្រធាន ក្រុមការងាររៀបចំសាលាក្ដី បាននិយាយថា គាត់មានការភ្ញាក់ផ្អើលពេលសាលាឧទ្ធរណ៍សម្រេចចេញដីកាខណៈដែលអ្នកច្បាប់ គណ

បក្សប្រឆាំងលោក សុន ឆៃ បានតវ៉ាថា មន្ត្រីរដ្ឋាភិបាលបានគាបសង្កត់ព្រះរាជអាជ្ញាខេត្តមិនឲ្យចាប់អតីតមេដឹកនាំខ្មែរក្រហម ។ ព្រះរាជអាជ្ញាទាំងនោះគួរតែត្រូវពិន័យ ដោយសារពួកគេមិនគោរពតាមការបញ្ជារបស់អគ្គព្រះរាជអាជ្ញា ។

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា តុលាការកម្ពុជាមិនមានយុត្តាធិការចេញបញ្ជាឲ្យចាប់ខ្លួនអតីតមេដឹកនាំខ្មែរក្រហមទេ ប៉ុន្តែមានតែសាលាក្តីគាំទ្រដោយអង្គការសហប្រជាជាតិប៉ុណ្ណោះទើបមានអំណាចនាំពួកគេមកកាត់ទោសបាន ។ គ្មានការចាប់ខ្លួនត្រូវបានធ្វើឡើងទេរហូតដល់សាលាក្តីត្រូវបានបង្កើត ។ ការធ្វើសច្ចាប័ននៃសាលាក្តីនឹងក្លាយជាវារៈដំបូងសម្រាប់រដ្ឋសភាជាតិដែលទើបបង្កើតថ្មី ។ គាត់បានថ្លែងថា គាត់មិនព្រួយបារម្ភថា ខៀវ សំផន ឬ នួន ជា នឹងព្យាយាមគេចពីសាលាក្តីទេ ។ អ្នកទាំងពីរមិនដឹងថា ត្រូវគេចទៅកន្លែងណាឡើយ ។ គាត់នឹងប្រឈមមុខនឹងសាលាក្តី ។ ការចំណាយប៉ាន់ស្មាននៃការកាត់ទោសខ្មែរក្រហមនេះឥឡូវអស់ជាង ៦០លានដុល្លារច្រើនជាងការប៉ាន់ស្មានដំបូង១០លានដុល្លារ ។ សមាជិកការិយាល័យរដ្ឋបាលសាលាក្តីអ្នកស្រី ហេលែន ចារីស បានអះអាងថា ការចំណាយប៉ាន់ស្មានឥឡូវអស់ជាង៦០លានដុល្លារ ហើយអាចនឹងពិភាក្សានិងត្រួតពិនិត្យឡើងវិញដោយអ្នកផ្តល់ជំនួយសំខាន់ដែលមានរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ ប្រទេសអូស្ត្រាលីសន្យាផ្តល់ទឹកប្រាក់៥លានដុល្លារអូស្ត្រាលីទៀតសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ បន្ថែមលើទឹកប្រាក់១លាន៥សែនដុល្លារអូស្ត្រាលី ដែលបានប្រកាសកាលពីពេលមុន ។ ទឹកប្រាក់សរុប៣លានដុល្លារអូស្ត្រាលី (២លាន២សែនដុល្លារអាមេរិក) ត្រូវបានបន្ថែមលើប្រាក់២៦៦.០០០ដុល្លារអូស្ត្រាលី ដែលបានផ្តល់ជាជំនួយបច្ចេកទេសទាក់ទងការកាត់ក្តីរួចហើយ ។

នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៤ ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលសាលាក្តីខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជានិយាយថា ក្រុមការងារអង្គការសហប្រជាជាតិដែលដឹកនាំដោយលោក ខាស្តែន ហ៊ែរែល នឹងមកដល់កម្ពុជានៅថ្ងៃទី២៣ ខែសីហា ដើម្បីប៉ាន់ប្រមាណពីថវិកាសាលាក្តី ។ លោកបានបន្ថែមទៀតថា ការកាត់ក្តីត្រូវបានរំពឹងថានឹងចំណាយអស់ទឹកប្រាក់៧លានដុល្លារ ហើយការចំណាយចុងក្រោយនឹងត្រូវដោះស្រាយជាមួយប្រទេសជាម្ចាស់ជំនួយឬក្រុមប្រទេសដែលចាប់អារម្មណ៍ ។

នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៤ គណៈរដ្ឋមន្ត្រីបានយល់ស្របចំពោះសេចក្តីព្រាងច្បាប់ពីរ គឺ ទីមួយ : វិសោធនកម្មច្បាប់ឆ្នាំ២០០១ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ទីពីរ : ការឲ្យសច្ចា

ប័នកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដែលបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ។

វិសោធនកម្មដែលត្រូវបានយល់ព្រម គឺមានគោលបំណង ដើម្បីភាពចុះសម្រុងរវាងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀងហើយវាឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងដែលស្នើដោយ លោក ហាន់ កូរ៉ែល នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ ។ បន្ថែមពីលើនេះ ការពង្រីកលក្ខន្តិកៈនៃដែនកំណត់ក្រោមមាត្រា៣ ត្រូវបានស្នើឡើងឲ្យផ្លាស់ប្តូរពី២០ឆ្នាំទៅ៣០ឆ្នាំ ។

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ ចៅក្រមនិងព្រះរាជអាជ្ញាចំនួន៣០រូប ដែលជ្រើសរើសដោយក្រុមប្រឹក្សានៃអង្គចៅក្រមចាប់ផ្តើមបើកវគ្គបណ្តុះបណ្តាលពីរសប្តាហ៍ ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិនៅឯសាលាភូមិន្ទចៅក្រម ។ យោងតាមសេចក្តីថ្លែងការណ៍ពីកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិដែលជួយដល់វគ្គបណ្តុះបណ្តាលចៅក្រមនិងព្រះរាជអាជ្ញានឹងត្រូវបានណែនាំពីបញ្ហាដែលរួមមានឧក្រិដ្ឋ-កម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការកាត់ទោសដោយយុត្តិធម៌ និងដំណើរការដោយរលូន ។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៤ គណៈកម្មការនីតិកម្មរបស់រដ្ឋសភាជាតិប្រគល់ទៅឲ្យក្រុមការងារសាលាក្តីនូវសេចក្តីព្រាងច្បាប់សម្រាប់បង្កើតសាលាក្តី ជាមួយនឹងការរិះគន់ពីខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ។ ប្រធានគណៈកម្មការ ឯកឧត្តម ឯក សំអុល មានប្រសាសន៍ថា សេចក្តីព្រាងច្បាប់មានកំហុសជាច្រើន ហើយតម្រូវឲ្យមានការផ្លាស់ប្តូរជាច្រើនដែរ ។ ប៉ុន្តែប្រធានការងាររដ្ឋបាល លោក ស៊ាន វិសុទ្ធ បាននិយាយថា កំហុសទាំងនោះជាកំហុសអក្ខរាវិរុទ្ធដែលអាចដោះស្រាយបាន ដោយងាយ ។ គណៈកម្មាធិការគ្រាន់តែសុំឲ្យកែកំហុសអក្ខរាវិរុទ្ធខ្លះប៉ុណ្ណោះ ។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ បន្ទាប់ពីការប្រកាសការត្រឡប់មកវិញរបស់គណៈប្រតិភូអង្គការសហប្រជាជាតិដើម្បីរៀបចំថវិកានិងភ័ស្តុភារសម្រាប់សាលាក្តី មន្ត្រីរដ្ឋាភិបាលបានលុបចោលទស្សនកិច្ចរបស់ក្រុមអង្គការសហប្រជាជាតិ ។ ទស្សនកិច្ចនេះត្រូវបានពន្យារពេលរហូតដល់រដ្ឋសភាជាតិផ្តល់សច្ចាប័នលើច្បាប់សម្រាប់បង្កើតសាលាក្តី ។ ទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី លោក ឱម យិនទៀង បាននិយាយថា ក្រុមនេះនឹងត្រូវអញ្ជើញឲ្យត្រឡប់មកវិញពេលសេចក្តីព្រាងច្បាប់ត្រូវបានអនុម័ត ។ គាត់បានបន្ថែមថា "ខ្ញុំគិតថាការពន្យារពេលមិនមែនជាការខ្ជះខ្ជាយពេលវេលាទេ" ។

នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា កម្ពុជានឹងមិនរួមចំណែកសម្រាប់ការកាត់ក្តី អតីតមេដឹកនាំខ្មែរក្រហមដែលពន្យារពេលយូរនោះទេ ។ ឆាប់ៗនេះនឹងមានការជជែកពីថវិកា ។ ខ្ញុំចង់និយាយថា កម្ពុជាអាចផ្តល់ឲ្យតែសាលប្រជុំ បង់ថ្លៃទឹកភ្លើង និងកង

សន្តិសុខប៉ុណ្ណោះ ។ ពួកគេមិនអាចសុំឲ្យកម្ពុជាចំណាយសម្រាប់សាលាក្តីទេ ។ បើអ្នកចង់ឲ្យមានសាលាក្តី អ្នកត្រូវចំណាយ ។ គាត់បានមានប្រសាសន៍បន្ថែមថា យើងត្រូវតែច្បាស់លាស់លើរឿងនេះ ។ កម្ពុជាអាចដំណើរការកាត់ក្តីបាន ប៉ុន្តែពួកគេនិយាយថា ពួកគេមិនជឿថាកម្ពុជាអាចផ្តល់នូវយុត្តិធម៌បានទេ ។

នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤ រដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង មានប្រសាសន៍ថា លោក កូហ្វី អាណាន់ បានសុំឲ្យរាជរដ្ឋាភិបាលកម្ពុជាផ្ញើលិខិតមួយទៅអង្គការសហប្រជាជាតិ បន្ទាប់ពីផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិ ដើម្បីឲ្យគាត់ស្នើ ឬរៀបចំការប្រជុំជាមួយម្ចាស់ជំនួយដើម្បីស្វែងរកថវិកាគាំទ្រសាលាក្តី ។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រាប់អ្នកយកព័ត៌មានថា ធ្វើអ៊ីចឹងទើបអង្គការសហប្រជាជាតិស្វែងរកអ្នកផ្តល់ជំនួយសម្រាប់ប្រាក់ប្រមាណជា៥០លានដុល្លារដែលត្រូវការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ សមាជិក១០៧រូបនៃរដ្ឋសភាជាតិក្នុងចំណោម១២៣រូបបានបោះឆ្នោតផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាល កម្ពុជាស្តីពីការកាត់ទោសក្រោមច្បាប់កម្ពុជា ពីព្រោះឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិប-តេយ្យ ។ បន្ទាប់ពីការបោះឆ្នោត នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា «អ្វីដែលយើងបានរង់ចាំដ៏យូរនោះបានកើតឡើងនៅថ្ងៃនេះហើយ» ។

ក្នុងសន្និសីទកាសែតមួយនៅមុខរដ្ឋសភាជាតិបន្ទាប់ពីការប្រជុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា គាត់នឹងឲ្យមន្ត្រីរដ្ឋាភិបាលនិងប្រជាជនកម្ពុជាឈប់សម្រាកមួយថ្ងៃនៅថ្ងៃដែលសាលាក្តីខ្មែរក្រហមបើកសវនាការដំបូង ។ ការប្រកាសនេះត្រូវបានធ្វើឡើងដើម្បីជាការឆ្លើយតបទៅនឹងសំណូមពររបស់ លោក ឆាំង យុ ដើម្បីបង្កើតជាថ្ងៃនៃការចងចាំនិងយុត្តិធម៌ ។

លិខិតមួយច្បាប់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើទៅលោក កូហ្វី អាណាន់ ស្តីពីការយល់ព្រមរបស់រដ្ឋសភាជាតិ លើសេចក្តីព្រាងច្បាប់ដែលឯកភាពលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាអំពីការកាត់ទោសក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៤ សមាជិក៩៦រូបក្នុងចំណោមសមាជិក៩៨រូបនៃរដ្ឋសភាជាតិបោះឆ្នោតយល់ព្រមចំពោះការធ្វើវិសោធនកម្ម២៩មាត្រានៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មាត្រាទាំង២៩ នោះរួមមានមាត្រា ២ ៣ ៩ ១០ ១១ ១៤ ១៧ ១៨

២០ ២១ ២២ ២៣ ២៤ ២៧ ២៩ ៣១ ៣៣ ៣៤ ៣៥ ៣៦ ៣៧ ៣៩ ៤០ ៤២ ៤៣ ៤៤ ៤៥ ៤៦ និងមាត្រា៤៧ ។ វិសោធនកម្មជារួមពឹងផ្អែកលើទិដ្ឋភាពបច្ចេកទេសនៃតុលា-ការពិសេសដូចជា របនាសម្ព័ន្ធ យុត្តាធិការ និងនីតិវិធី ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ពីរសប្តាហ៍បន្ទាប់ពីធ្វើជាអធិបតីក្នុងការផ្តល់សច្ចាប័នកិច្ចព្រមព្រៀងនិងវិសោធនកម្មមាត្រានៃខបញ្ញត្តិដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ប្រធានរដ្ឋសភា សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រានចោលថវិកាសម្រាប់សាលាក្តី ដោយមានព្រះរាជបន្ទូលថា ថវិកាគ្រោងនោះគួរតែចំណាយលើការអភិវឌ្ឍវិស័យកសិកម្មរបស់ប្រទេសប្រសើរជាង ។ ព្រះអង្គមានព្រះបន្ទូលប្រាប់អ្នកយកព័ត៌មាននៅក្រៅរដ្ឋសភាជាតិថា «បើសិនខ្ញុំមានប្រាក់៥៥លានដុល្លារ ខ្ញុំនឹងយកប្រាក់នោះទៅអភិវឌ្ឍប្រទេសវិញ ។ វាមានប្រយោជន៍ជាងការកាត់ទោសមេដឹកនាំចាស់ៗនៃរបបខ្មែរក្រហម ។ វាមានយុត្តិ ធម៌ពីរប្រភេទ គឺយុត្តិធម៌សម្រាប់ជនរងគ្រោះ និងយុត្តិធម៌ សម្រាប់ជនក្រីក្រ ។ ប្រាក់៥០លានដុល្លារគឺច្រើនខ្លាំងណាស់» ។ ព្រះអង្គបានបន្ថែមថា «តើយើងអាចដឹកប្រឡាយ បានប៉ុន្មានជាមួយនឹងប្រាក់ទាំងនោះ» ។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលយល់ព្រម ដោយរដ្ឋសភាជាតិនៅថ្ងៃទី២៤ ខែតុលា ត្រូវបានប្រកាសដោយប្រមុខរដ្ឋស្តីទីសម្តេច ជា ស៊ីម ។

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ ក្រុមប្រឹក្សាធម្មនុញ្ញបានយល់ស្របចំពោះការកែប្រែច្បាប់ស្របតាមរដ្ឋធម្មនុញ្ញ ។

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ច្បាប់ខ្មែរក្រហមដែលបានធ្វើវិសោធនកម្មនឹងយល់ព្រមដោយរដ្ឋសភាជាតិនៅថ្ងៃទី៥ ខែតុលា ត្រូវបានប្រកាសដោយប្រមុខរដ្ឋស្តីទីសម្តេច ជា ស៊ីម ។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា ចេញសេចក្តីថ្លែងការណ៍មួយប្រកាសបញ្ចប់ការងារផ្នែកច្បាប់សម្រាប់សាលាក្តី ។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ឧបនាយករដ្ឋមន្ត្រី សុខ អាន ផ្ញើលិខិតមួយច្បាប់ទៅអគ្គលេខាធិការរងនិងទីប្រឹក្សាផ្នែកច្បាប់នៃអង្គការសហប្រជាជាតិ លោក នីកូឡា មីសែល ដើម្បីណែនាំគាត់ថា យោងតាមមាត្រា៣២នៃកិច្ចព្រមព្រៀង តម្រូវការផ្នែកច្បាប់ដើម្បីឲ្យកម្ពុជាប្រើប្រាស់អំណាចត្រូវបានគោរពតាម ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន សម្តែងក្តីព្រួយបារម្ភថា ការមិនស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិដើម្បីចំណាយសម្រាប់សាលាក្តីនឹងពន្យារពេល ហើយដំណើរការយូរនេះអាចធ្វើឲ្យអតីតមេដឹកនាំខ្មែរក្រហមស្លាប់មុនពេលកាត់ក្តី ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ពេលធ្វើបុណ្យខួបរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាថ្ងៃទី៧ធ្នូ ថា ឥឡូវនេះយើងមានច្បាប់សម្រាប់កាត់ទោសខ្មែរក្រហម ប៉ុន្តែអង្គការសហប្រជាជាតិថ្លែងថាពួកគេមិនមានថវិកា ។ គាត់បានបន្ថែមថា ប្រជាជននិងខ្ញុំព្រួយបារម្ភថា អតីតមេដឹកនាំខ្មែរក្រហមនឹងស្លាប់មុនពេលកាត់ក្តី ។ នេះជាក្តីបារម្ភរបស់យើង ។ ថវិកាជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន សុំឲ្យសហគមន៍អន្តរជាតិផ្តល់ជំនួយដល់ប្រទេសដែលត្រូវបានបំផ្លិចបំផ្លាញដោយរលកស៊ូណាមិនៅថ្ងៃទី២៦ ខែធ្នូ ដោយមិនទាន់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា «ចំនួនប្រជាជនដែលស្លាប់ដោយស៊ូណាមិមានចំនួនតិចជាង១០ភាគរយបើប្រៀបធៀបនឹងការខូចខាតនិងចំនួនមនុស្សស្លាប់នៅក្នុងរបបខ្មែរក្រហម» ។ លោកបន្ថែមទៀតថា «គ្មាននរណាម្នាក់ចង់យកខ្មែរក្រហមទៅកាត់ទោសជាង ហ៊ុន សែន ទេ» ។

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៥ សម្តេចព្រះ នរោត្តម សីហនុ មានព្រះរាជបន្ទូលថា ការកាត់ទោសមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមួយក្តាប់តូច គ្រាន់តែជា«រឿងកំប្លែងនិងការលាក់ពុត»ប៉ុណ្ណោះ ព្រោះបានចំណាយអស់ជាង៥៦លានដុល្លារអាមេរិក ដើម្បីបង្កើតតុលាការ ហើយការ «ជួយឧបត្ថម្ភក្នុងរយៈពេលបីឆ្នាំ អាចធ្វើឲ្យចៅក្រមមានជីវភាពខ្ពង់ខ្ពស់» ។ ព្រះអង្គស្នើថា វាប្រហែលជាមានយុត្តិធម៌ជាង ប្រសិនយើងអាចផ្តល់ដីដែលមានដីជាតិនិងប្រព័ន្ធដូវទឹកទៅឲ្យគ្រួសាររបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ព្រះអង្គបានសរសេរនៅលើគេហទំព័ររបស់ទ្រង់ថា «ខ្ញុំដឹងថាការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមដោយប្រើប្រាស់អង្គជំនុំជម្រះរបស់កម្ពុជា និងអង្គការសហប្រជាជាតិអាចធ្វើឲ្យខ្ញុំមាន អារម្មណ៍ធូរស្រាល» ។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៥ សម្តេចព្រះ នរោត្តម សីហនុ រំឭកថា គួរតែកាត់ទោសការបះបោរប្រឆាំងនឹងរដ្ឋាភិបាលរបស់អតីតខ្មែរក្រហមផង ប្រសិនបើមានការកាត់ទោសដោយអង្គជំនុំជម្រះដែលមានការផ្តល់ជំនួយពីអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ ប្រទេសអង់គ្លេសប្រកាសថា នឹងផ្តល់ជំនួយ៩៨ម៉ឺនដុល្លារអាមេរិកទៅឲ្យអង្គជំនុំជម្រះ ។

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន ជំរុញឲ្យអ្នកផ្តល់ជំនួយជាតិឆាប់ផ្តល់មូលនិធិទៅឲ្យអង្គជំនុំជម្រះមុនពេលមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ស្លាប់បាត់បង់ជីវិត ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៥ ជប៉ុនតាំងចិត្តថានឹងផ្តល់ថវិកា ២១,៥លានដុល្លារអាមេរិកទៅឲ្យអង្គជំនុំជម្រះតាមរយៈអង្គការសហប្រជាជាតិនៅចុងខែមីនា ។

នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៥ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ដែលជាលេខាផ្ទាល់ខ្លួនរបស់សម្តេចព្រះ នរោត្តម សីហនុ តាំងចិត្តថានឹងប្តឹងរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ដើម្បីស្វែងរកការស្លាប់របស់ព្រះមាតាបិតាទ្រង់ ពេលដែលតុលាការខ្មែរក្រហមត្រូវបង្កើតឡើង ។ ដើម្បីបង្ហាញចម្ងល់ទៅកាន់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលចំពោះអង្គជំនុំជម្រះដែលប្រជាជនទន្ទឹងរង់ចាំជាយូរណាស់មកហើយ ព្រះអង្គម្ចាស់ ធម្មិកោ មានព្រះរាជបន្ទូលថា ទ្រង់ចង់ស្វែងរកយុត្តិធម៌អំពីការស្លាប់របស់ព្រះ មាតាបិតាព្រះអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មេថាវី និងព្រះនាង ណាណែត មេថាវី ដែលជាបងស្រីរបស់ម្ចាស់ក្សត្រី នរោត្តម មុនីនាថ ។

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធាកម្ពុជានិយាយថា តាម៉ុក និង កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានចោទប្រកាន់នៅខែកុម្ភៈ ពីបទឧក្រិដ្ឋកម្មសង្គ្រាមនិងការធ្វើទុកបុកម្នេញលើជនជាតិបរទេសនៅអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥ រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ព្រះអង្គម្ចាស់ ធម្មិកោ ដោយរំពឹកថា លោកនឹងទាមទារសំណងជាប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ចំពោះពាក្យបណ្តឹងដែលប្តឹងគាត់នៅក្នុងតុលាការដែលនឹងមាននៅខាងមុខ ។ ចំពោះសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះអង្គម្ចាស់ ធម្មិកោ ក្នុងការតាំងចិត្តដាក់ពាក្យប្តឹងប្រឆាំងលោករដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង លោកបានប្រាប់អ្នកសារព័ត៌មានថា អ្នកដែលមានបំណងប្តឹងលោកពីករណីនេះ សុំត្រៀមប្រាក់ដើម្បីបង់ជាសំណងឲ្យហើយទៅ ។

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា “មកដល់សព្វថ្ងៃនេះរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិមានប្រាក់គ្រប់ចំនួនដើម្បីចំណាយសម្រាប់អង្គជំនុំជម្រះនៅឆ្នាំដំបូង ការប៉ាន់ស្មានទឹកប្រាក់មានចំនួន ៥៦លានដុល្លារអាមេរិក ក្នុងនោះមានប្រាក់ចំនួន ៣៩លានដុល្លារ ដែលជាជំនួយមកពីប្រទេសជប៉ុន អូស្ត្រាលី ចក្រភពអង់គ្លេស និងបារាំង” ។ លោកអំពាវនាវឲ្យមានជំនួយនិងការជួយគាំទ្រពីសហគមន៍អន្តរជាតិដើម្បីធ្វើឲ្យអង្គជំនុំជម្រះដែលប្រជា- ជនរង់ចាំជាយូរណាស់មកហើយក្លាយទៅជាការពិត ។ គាត់និយាយថា “ខ្ញុំសង្ឃឹមថាសហគមន៍អន្តរជាតិ

នឹងចាប់ផ្ដើមជួយដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សនៅអាស៊ីខ្លាំងក្លាជាងមុន ដូចជានៅអឺរ៉ុប និងអាហ្វ្រិក» ។ «ការជួយប្រជាជនកម្ពុជាដើម្បីស្វែងរកយុត្តិធម៌ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួន គឺជារឿងប្រវត្តិសាស្ត្រមួយ» ។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ យោងទៅតាមលោក រួម រិត អ្នកសរសេរលិខិតឆ្លើយឆ្លងជាមួយសម្ដេច សីហនុ បានឲ្យដឹងថា សម្ដេចព្រះ នរោត្តម សីហនុ ដែលបានដាក់រាជ្យមានព្រះរាជបន្ទូលថា ទ្រង់នឹងផ្ដល់ប្រាក់ចំនួន១ម៉ឺនដុល្លារជូនសព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ប្រសិនបើរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ប្ដឹងព្រះអង្គម្ចាស់ពីបទបរិហារកេរ្ដិ៍ ។

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ ប្រទេសកាណាដាប្រកាសថា នឹងផ្ដល់លុយ២លានដុល្លារកាណាដា(១,៦៨លានដុល្លារអាមេរិក) ទៅឲ្យអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយចំណាយ១លានដុល្លារកាណាដាទៅលើប្រតិបត្តិការនៅឆ្នាំដំបូង និង៥សែនដុល្លារកាណាដានៅឆ្នាំទីពីរនិងទីបី ។

រដ្ឋាភិបាលកម្ពុជាប្រកាសថា មានតែ១,៥លានដុល្លារអាមេរិកក្នុងចំនួនថវិកា១៣,៣ដុល្លារដែលបានរំពឹងទុក ដូច្នេះត្រូវតែស្នើសុំមូលនិធិបន្ថែមពីប្រទេសដែលចាប់អារម្មណ៍លើបញ្ហានេះ ដើម្បីបំពេញលើការខ្វះខាត១១,៨លានដុល្លារទៀត ។ ទីប្រឹក្សាជាន់ខ្ពស់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន លោក ឱម យិនទៀង មានប្រសាសន៍ថា ប្រទេសកម្ពុជានឹងទទួលខុសត្រូវថវិកាចំនួន៦,៧លានដុល្លារ ប៉ុន្តែសន្តិសុខនិងអ្វីផ្សេងៗទៀតដែលមិនរួមបញ្ចូលក្នុងថវិកានេះគឺជាការព្រួយបារម្ភ ។

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ ប្រទេសជាសមាជិករបស់ អង្គការសហប្រជាជាតិសន្យាថានឹងផ្ដល់ថវិកា៣៨,៤៨លានដុល្លារ ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូច្នេះ ខ្វះថវិកា៤,៥២លានដុល្លារ ទើបគ្រប់គោលដៅ ៤៣លានដុល្លារ ។ ប្រទេសដែលសន្យានោះរួមមាន : ជប៉ុន ២១លាន៦សែនដុល្លារ, បារាំង ៤លាន៨សែនដុល្លារ, ចក្រភពអង់គ្លេស ២លាន៨សែន៧ម៉ឺនដុល្លារ, អូស្ត្រាលី ២លាន៣សែន៥ម៉ឺនដុល្លារ, ហូល្លង់ ២លានដុល្លារ, កាណាដា ១លាន៦សែន១ម៉ឺនដុល្លារ, ន័រវ៉េស ១លានដុល្លារ, អាល្លឺម៉ង់ ១លានដុល្លារ, ដេនម៉ាក ៥សែន២ម៉ឺន៥ពាន់ដុល្លារ, អូទ្រីស ៣សែន៦ម៉ឺនដុល្លារ, ស៊ុយអែត ១សែន៥ម៉ឺនដុល្លារ, សាធារណរដ្ឋកូរ៉េ ១សែន៥ម៉ឺនដុល្លារ, លុចសំបួរ ៦ម៉ឺន៦ពាន់ដុល្លារ ។

អ្នកតំណាងសហរដ្ឋអាមេរិកមានប្រសាសន៍ថា កាលពីដប់ឆ្នាំមុនសហរដ្ឋអាមេរិកបាន«ចំណាយ៧លានដុល្លារទៅលើថ្លៃស្រាវជ្រាវនិងថ្លៃឯកសារដើម្បីស្វែងរកឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា» ដូច្នេះមិនអាចផ្ដល់ថវិកាទៅឲ្យអង្គជំនុំជម្រះថែមទៀតទេ» ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា គាត់ជឿជាក់ថាវាប្រាកដជាមានការខុះខាតខាងថវិកា ដូច្នេះរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាសុំឲ្យក្រុមហ៊ុនឯកជននៅក្នុងប្រទេសជួយបំពេញបន្ថែម ។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៥ សាលាក្រុងភ្នំពេញបានផ្តល់សិទ្ធិទៅឲ្យក្រុមហ៊ុនជប៉ុនដើម្បីអភិវឌ្ឍនិងគ្រប់គ្រងវាលពិឃាតជើងឯក ។ មន្ត្រីម្នាក់មានប្រសាសន៍ថា «កិច្ចសន្យាបានអនុញ្ញាតឲ្យក្រុមហ៊ុនយកបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ជាទិសដៅទេសចរណ៍សម្រាប់រយៈពេល៣០ឆ្នាំ ដោយផ្តល់ប្រាក់១ម៉ឺន៥ពាន់ដុល្លារក្នុងមួយឆ្នាំ ។ ច្បាប់ចម្លងកិច្ចសន្យាដែលយកមកពីអ្នកគ្រប់គ្រងទូទៅនៅវាលពិឃាតជើងឯកត្រូវបានផ្ញើជូនទៅក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់នៅខណ្ឌដង្កោ ដែលកិច្ចសន្យានេះធ្វើឡើងនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ ដោយអភិបាលក្រុង កែប ជុតិម៉ា និងអ្នកតំណាងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ លោក ខូជី យ៉ាម៉ាតូ ។ អាសយដ្ឋានរបស់ក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ដែលសរសេរនៅក្នុងកិច្ចសន្យាគឺផ្ទះលេខ៩៧ ផ្លូវ១១០ ខណ្ឌទួលគោក ។ ប៉ុន្តែលោកអភិបាលខណ្ឌទួលគោក សេង រតនៈ មានប្រសាសន៍ថា លោកមិនបានដឹងថាមានផ្លូវនេះនៅក្នុងខណ្ឌដែលលោកគ្រប់គ្រងទេ ។ ផ្លូវ១១០ នៅក្នុងខណ្ឌដូនពេញគឺជាអគារផ្ទះល្វែង ។ ប្រជាជនដែលរស់នៅទីនោះនិយាយថា គេមិនដែលឮពីក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ និងអ្នកតំណាងក្រុមហ៊ុនដែលមានឈ្មោះថា ខូជី យ៉ាម៉ាតូ ទេ ។

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៥ ក្រុមប្រឹក្សារដ្ឋមន្ត្រីម្នាក់ ដែលបានចុះហត្ថលេខាលើកិច្ច-សន្យាដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនយកវាលពិឃាតជើងឯកធ្វើជាកន្លែងទាក់ទាញភ្ញៀវទេសចរណ៍បានមានប្រសាសន៍ថា លោកក៏ជាប្រធានគ្រប់គ្រងក្រុមហ៊ុនម្នាក់ដែរ ។ ក្រុមប្រឹក្សាប្រធានខុទ្ទកាល័យរដ្ឋមន្ត្រីជា វណ្ណដិត មានប្រសាសន៍ថា លោកបានកំពុងតែធ្វើការនៅក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ដែលមានទីតាំងនៅប្រទេសជប៉ុនតាំងពីក្រុមហ៊ុននោះទើបតែបង្កើតឡើងបានប្រហែល៧ខែមកម្ល៉េះ ។

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៥ លោក ឆាំង យុ សរសេរលិខិតមួយច្បាប់ផ្ញើទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយស្នើឲ្យលោកលុបចោលកិច្ចសន្យាដែលធ្វើឡើងដោយសាលាក្រុងភ្នំពេញនិងក្រុមហ៊ុនជេស៊ីរ៉ូយាល់ ដោយនិយាយថា វាលពិឃាតជើងឯកនេះត្រូវបានបង្កើតឡើង២៥ឆ្នាំមកហើយ ដូច្នេះវាគួរតែគ្រប់គ្រង និងការពារដោយកម្ពុជា ។

អ្នកគ្រប់គ្រងទូទៅនៅវាលពិឃាតជើងឯកនិយាយថា មន្ត្រីនៅឯសាលាក្រុងភ្នំពេញបានសំណូមពរឲ្យលោកឈប់រៀបរាប់ពីគម្រោងលក់បូជនីយដ្ឋានអំពើប្រល័យពូជសាសន៍នៅសម័យខ្មែរក្រហម ។ ការស្រាវជ្រាវតាមអ៊ីនធឺណេតនៅក្នុងគេហទំព័ររបស់ក្រុមហ៊ុនជេស៊ីរ៉ូយាល់ដែលចុះឈ្មោះនៅក្រុមហ៊ុន

អ៊ីអិលជី ផ្លាស់នៅទីក្រុងតូក្យូមានតែអាសយដ្ឋាននិងលេខទូរស័ព្ទប៉ុណ្ណោះ ហើយអ្នកយាមជាអ្នកឆ្លើយតបទូរស័ព្ទ ។

នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៥ សាលាក្រុងភ្នំពេញនិយាយថា គេមិនញញើតនឹងការរិះគន់ចំពោះការចុះហត្ថលេខាលើកិច្ចសន្យាអនុញ្ញាតឲ្យក្រុមហ៊ុនជប៉ុនគ្រប់គ្រងវាលពិឃាតជើងឯករយៈពេល ៣០ឆ្នាំទេ ។

លោក ឆាំង យុ ផ្ញើលិខិតទៅឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា រដ្ឋាភិបាលគួរតែលុបចោលកិច្ចសន្យា ហើយអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាគ្រប់គ្រងលើវាលពិឃាតជើងឯកវិញ ។ លោកនិយាយថា «ខ្ញុំសុំឲ្យលោកនាយករដ្ឋមន្ត្រីពិចារណាទៅលើកិច្ចសន្យាម្តងទៀត ពីព្រោះកិច្ចសន្យានេះនៅមិនទាន់បានបោះត្រានៅឡើយទេ ហើយខ្ញុំគិតថា លោកនាយករដ្ឋមន្ត្រីមិនទាន់បានដឹងពីកិច្ចសន្យានេះនៅឡើយទេ» ។ សាលាក្រុងនិយាយថា ក្រុងភ្នំពេញកំពុងតែអភិវឌ្ឍ... ហេតុអ្វីបានជាក្រុមហ៊ុនឯកជនមិនអាចថែរក្សាវាលពិឃាតជើងឯក?» ។

នៅក្នុងលិខិតផ្ញើឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី៩ ខែមេសា លោក ឆាំង យុ មានប្រសាសន៍ថា «ជើងឯកមិនគួរគ្រប់គ្រងដោយក្រុមហ៊ុនឯកជនទេ ប្រទេសមួយគួរតែការពារប្រវត្តិសាស្ត្រដោយខ្លួនឯង គ្មានប្រទេសដទៃណាអាចគ្រប់គ្រងល្អជាងទេ ។ លោកបន្ថែមទៀតថា ប្រាក់ចំណូលដែលបានមកពីភ្ញៀវទេសចរណ៍រាល់ឆ្នាំមានចំនួនច្រើនជាងប្រាក់ដែលក្រុមហ៊ុនផ្តល់ឲ្យទៅទៀត ដូច្នេះជើងឯកមិនគួរលក់ទៅឲ្យក្រុមហ៊ុនឯកជនទេ ។

នៅក្នុងសេចក្តីប្រកាសព័ត៌មាន ក្រុមប្រឹក្សារដ្ឋមន្ត្រីបង្ហាញពីសេចក្តីលម្អិតរបស់កិច្ចព្រមព្រៀងវាលពិឃាតជើងឯកដែលមានការរិះគន់យ៉ាងខ្លាំងថា សាធារណជននៅមិនទាន់បានដឹងពី«រូបភាពពិតប្រាកដ»របស់កិច្ចព្រមព្រៀងនៅឡើយទេ ។ សេចក្តីថ្លែងការណ៍ដែលមិនទាន់ចុះហត្ថលេខារបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី បានឲ្យដឹងថា ការធ្វើកិច្ចព្រមព្រៀងនេះគឺដើម្បី«ការពារនិងអភិវឌ្ឍ»ជើងឯក «ក្នុងគោលបំណងតម្រូវទៅតាមភ្ញៀវទេសចរណ៍ដែលរំពឹងទុកថានឹងកើនឡើងនៅពេលអនាគត» ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានអះអាងថា «ទោះបីជាសាលាក្រុងអាចការពារជើងឯកបានរយៈពេល២៥ឆ្នាំ ហើយក៏ដោយ ប៉ុន្តែសាលាក្រុងមិនមានលទ្ធភាព ដោះស្រាយបញ្ហាទឹកជំនន់ដែលកើតឡើងរាល់ឆ្នាំនិងការថែរក្សាអគារដែលប៉ះពាល់ដល់វាលពិឃាតជើងឯកទេ» ។

លោក ឆាំង យុ ឆ្លើយតបថា លោកនៅមិនទាន់បានឃើញសេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៅឡើយទេ យ៉ាងណាមិញសេចក្តីលម្អិតរបស់សេចក្តីថ្លែងការណ៍នេះក៏មិនមានពាក់ព័ន្ធអ្វីដែរ ព្រោះនៅក្នុងកិច្ចសន្យាមិនបាននិយាយអំពីការចុះហត្ថលេខាលក់និមិត្តរូបជាតិទៅឲ្យក្រុមហ៊ុន

បរទេសទេ ។ “ដូច្នេះសេចក្ដីថ្លែងការណ៍មិនមែនជាចំណុចសំខាន់ទេ ។ ការចងចាំមិនអាចធ្វើកិច្ចសន្យាលក់បានទេ” ។

នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៥ មន្ត្រីរដ្ឋាភិបាលបដិសេធនឹងក្រុមហ៊ុនដេស៊ីរ៉ូយ៉ាលដែលចង់អភិវឌ្ឍផ្លូវទៅកាន់ជើងឯក ។ ការបដិសេធនេះធ្វើឡើងមួយថ្ងៃមុនពេលមានសេចក្ដីថ្លែងការណ៍លម្អិតរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលគាំទ្រការសម្រេចចិត្តរបស់រដ្ឋាភិបាលដើម្បីលក់បូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ ការស្នើសុំរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងបទបញ្ញត្តិនៃការអភិវឌ្ឍផ្លូវទៅកាន់វាលពិឃាតជើងឯក ។ ប្រធានធនាគារអភិវឌ្ឍអាស៊ី លោក ស៊ីយ៉ាម បាដៃ ផ្ដល់ដំណឹងថា ធនាគារលោកបានរៀបចំមូលនិធិ ដើម្បីអភិវឌ្ឍផ្លូវពីភ្នំពេញទៅកាន់ជើងឯកហើយ ។ លោកនិយាយថា “លោកនៅមិនទាន់ដឹងថាមានអ្នកផ្សេងចង់អភិវឌ្ឍផ្លូវនេះនៅឡើយទេ” ។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៥ រដ្ឋាភិបាលប៊ែលហ្សិកសន្យានឹងផ្ដល់ប្រាក់១៩.៥០០ ដុល្លារទៅឲ្យតុលាការខ្មែរក្រហមដែលនឹងបង្កើតឡើងនៅថ្ងៃអនាគត ។ ដើរើន ខរមេន នាយករងនៃគណៈកម្មាធិការស្ថានទូតប៊ែលហ្សិកប្រចាំនៅបាងកកសរសេរអ៊ីមែលថា ប្រទេសប៊ែលហ្សិកមិនអាចប្រកាសនៅក្នុងសន្និសីទនៅទីស្នាក់ការអង្គការសហប្រប្រជាជាតិកាលពីថ្ងៃទី២៨ ខែមីនា បានទេ ពីព្រោះ“ការសម្រេចចិត្តនៅមិនទាន់បានសម្របសម្រួលគ្នាជាផ្លូវការនៅឡើយនៅពេលមានសន្និសីទ” ។

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៥ នៅក្នុងលិខិតផ្ញើទៅឲ្យអភិបាលក្រុងភ្នំពេញ លោក ឆាំង យុ និយាយថា ប្រជាជនកម្ពុជាបានខិតខំការពារបូជនីយដ្ឋានប្រល័យពូជសាសន៍អស់រយៈពេល២៥ ឆ្នាំមកហើយ ការលក់វាទៅឲ្យក្រុមហ៊ុនឯកជនអាចមានផលប៉ះពាល់ទៅដល់ប្រវត្តិសាស្ត្រជាតិ ។

លោក ឆាំង យុ បានស្នើទៅរដ្ឋាភិបាលជប៉ុនដើម្បីបង្ហាញពីទំនាក់ទំនងរបស់ខ្លួនជាមួយនឹងក្រុមហ៊ុនដេស៊ីរ៉ូយ៉ាល ហើយនឹងបង្ហាញពីអ្វីដែលលោកអភិបាលរងក្រុង ម៉ម ប៊ុននាង និយាយនៅក្នុងកាសែតខេមបូឌាដេលីដែលថា ជប៉ុនប្រហែលជាឈប់ផ្ដល់ជំនួយដល់ប្រទេសយើងប្រសិនបើយើងលុបចោលកិច្ចសន្យាលក់វាលពិឃាតជើងឯក ។

ជូនចំពោះលោកអគ្គរាជទូត

នៅក្នុងកាសែតខេមបូឌាដេលីថ្ងៃនេះ លោកអភិបាលរង ក្រុងទីមួយលោក ម៉ម ប៊ុននាង បាននិយាយថា “ប្រទេសជប៉ុនប្រហែលជាឈប់ផ្ដល់ជំនួយដល់ប្រទេសយើង ប្រសិនបើយើងលុបចោលកិច្ចសន្យាលក់វាលពិឃាតជើងឯក” ។

ការគំរាមកំហែងមិនច្បាស់លាស់នេះធ្លាប់កើតមាននៅក្នុងនយោបាយកម្ពុជា ហើយតែងតែត្រូវបានយកមកប្រើប្រាស់នៅពេលដែលសមាជិករដ្ឋាភិបាលក៏ដូចជាបក្សនយោបាយបម្រុងនឹងធ្វើអ្វីមួយមិនល្អ ។ នៅពេលនេះរដ្ឋាភិបាលជប៉ុនក៏ប្រើមធ្យោបាយនេះដើម្បីបង្ហាញពីមហិច្ឆតារបស់ខ្លួនដែរ ។

ទីមួយ ខ្ញុំសង្ឃឹមថារដ្ឋាភិបាលរបស់លោកនឹងបង្ហាញឲ្យច្បាស់ពីទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ។ ដូចដែលលោកបានដឹងច្បាស់ហើយថា គ្មាននរណាម្នាក់អាចស្វែងរកក្រុមហ៊ុន ឬមន្ត្រីរាជការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ប្រទេសជប៉ុន ឬក៏តាមអ៊ីនធឺណែតបានទេ ។ ដូច្នេះដឹងពីស្ថានភាពរបស់ក្រុមហ៊ុននេះ អាចធ្វើឲ្យប្រជាជនកម្ពុជាអស់ការសង្ស័យបាន ។

ទីពីរ វាប្រាកដជាមានលទ្ធផលល្អ ប្រសិនបើរដ្ឋាភិបាលរបស់លោកបង្ហាញពីទំនាក់ទំនងជាមួយក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ។ តើប្រទេសជប៉ុនដែលធ្លាប់ជាម្ចាស់ជំនួយអាចលុបចោលទំនាក់ទំនងជាមួយកម្ពុជាដោយសារតែប្រាក់មួយចំនួនតូចដែលវាលពិឃាតជើងឯករកបាននោះទេ? ហើយប្រសិនបើរដ្ឋាភិបាលរបស់លោកគាំទ្រក្រុមហ៊ុនជប៉ុនឲ្យគ្រប់គ្រងជើងឯកនោះ ខ្ញុំតំណាងឲ្យប្រជាជនកម្ពុជាសង្ឃឹមថា ក្រុមហ៊ុននេះនឹងអនុញ្ញាតឲ្យប្រជាជន ដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យអាចជួយការពារបូជនីយដ្ឋាននេះដែរ ។

ពី ឆាំង យុ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាស្នើទៅរដ្ឋាភិបាលដែលមានស្ថានទូតមួយចំនួននៅប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនិងស្ថានទូតមួយចំនួនទៀតប្រចាំនៅទីក្រុងបាងកកដែលបានតាមដានព្រឹត្តិការណ៍ខ្មែរក្រហមថា សូមឲ្យអង្គភាពនិងបុគ្គលទាំងនោះផ្តល់ភ័ស្តុតាងដែលគេ មានទៅឲ្យអង្គជំនុំជម្រះ ។ មជ្ឈមណ្ឌលក៏បានថ្លែងអំណរគុណដល់បណ្ឌិត ស៊ីវ ហេដ័រ នៃសាកលវិទ្យាល័យទីក្រុងឡុង និង ដេវីដ ហក អតីតមន្ត្រីនៅការិយាល័យកម្ពុជារបស់អង្គការសហប្រជាជាតិ ដើម្បីសិទ្ធិមនុស្សដែលបានផ្តល់ឯកសារពាក់ព័ន្ធនឹងខ្មែរក្រហមទៅអង្គជំនុំជម្រះដែលបានគ្រោងទុក ហើយមជ្ឈមណ្ឌលក៏បានសង្ឃឹមថាអ្នកឯទៀតនឹងធ្វើបែបនេះដែរ ។

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ ទោះបីជាមានការប្រឆាំងយ៉ាងណាក្តី ក៏ពិធីផ្តល់សិទ្ធិជាផ្លូវការត្រូវបានប្រារព្ធឡើងនៅសាលាក្រុងដែរ ។

នៅថ្ងៃ២១ ខែមេសា ឆ្នាំ២០០៥ ក្រសួងការបរទេសសហរដ្ឋអាមេរិកធ្វើសេចក្តីថ្លែងការណ៍ថា «ខណៈពេលដែលសហរដ្ឋអាមេរិកផ្តល់វិភាគទានដល់ដំណើរការនេះ យើងជឿថា វិធានច្បាប់របស់អាមេរិកនឹងធ្វើឲ្យអង្គជំនុំជម្រះមានបទដ្ឋានយុត្តិធម៌ ។ នៅពេលដែលអង្គជំនុំជម្រះមានដំណើរការ

ទៅមុខ យើងត្រូវតែបង្កើតទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ ព្រមទាំងប្រទេសដែលចាប់អារម្មណ៍ដើម្បីសម្រេចគោលដៅនេះ" ។

នៅថ្ងៃ២២ ខែមេសា ឆ្នាំ២០០៥ រដ្ឋាភិបាលវៀតណាម ឆ្លើយតបនឹងការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃទី១៧ ខែមេសា ចំពោះភ័ស្តុតាងដែលពាក់ព័ន្ធនឹងខ្មែរក្រហម ដោយសរសេរថា "លិខិតរបស់អ្នកនឹងត្រូវបានផ្ញើឲ្យរដ្ឋាភិបាល ដែលពាក់ព័ន្ធនៃប្រទេសវៀតណាម ។ ខ្ញុំជឿជាក់ថាគេនឹងចាប់អារម្មណ៍រឿងនេះ" ។

នៅថ្ងៃ២៥ ខែមេសា ឆ្នាំ២០០៥ ដើម្បីឆ្លើយតបនឹងការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃទី១៧ ខែមេសា ដែលត្រូវការភ័ស្តុតាងពាក់ព័ន្ធនឹងខ្មែរក្រហម អាល្លឺម៉ង់ផ្ញើឯកសារមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅថ្ងៃ២៩ ខែមេសា ឆ្នាំ២០០៥ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆាប់មានប្រសិទ្ធភាព ។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ អគ្គលេខាធិការអង្គការសហប្រជាជាតិសរសេរលិខិតមួយផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីជម្រាបថា តម្រូវការផ្នែកច្បាប់ខាងប្រទេសរបស់លោកបានរៀបចំរួចរាល់អស់ហើយ ។ យោងទៅតាមមាត្រា៣២នៃកិច្ចព្រមព្រៀងច្បាប់នេះនឹងមានប្រសិទ្ធភាពនៅថ្ងៃទី២៩ខែមេសា ឆ្នាំ២០០៥ ។ នៅថ្ងៃបន្ទាប់ លោក សុខ អាន បានជូនដំណឹងដល់លោក នីកូឡា មីសេល អំពីតម្រូវការផ្នែកច្បាប់សម្រាប់ប្រទេសកម្ពុជាដែលបានស្នើកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ថាបានរៀបចំរួចរាល់ដែរ ។

យោងទៅតាមរបាយការណ៍សារព័ត៌មានរបស់អង្គការសហប្រជាជាតិ កិច្ចសន្យាដែលមានប្រសិទ្ធភាពនិងវិភាគទានបច្ចុប្បន្នតម្រូវឲ្យផ្តល់ប្រាក់ខែដល់បុគ្គលិកជាតិនិងអន្តរជាតិដែលធ្វើការនៅអង្គជំនុំជម្រះ ។

គណៈកម្មាធិការសហភាពអឺរ៉ុបសន្យាថាផ្តល់ប្រាក់១លាន៣សែនដុល្លារដល់តុលាការខ្មែរក្រហម ។

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៥ កម្ពុជាស្វាគមន៍ចំពោះការប្រកាសរបស់អង្គការសហប្រជាជាតិដែលថាមានថវិកាគ្រប់គ្រាន់ នៅក្នុងដៃដើម្បីបង្កើតសាលាក្តី ។

ថ្ងៃទី៦ ខែឧសភា ឆ្នាំ ២០០៥ ប្រទេសបារាំងប្រកាសថា នឹងផ្តល់ថវិកាចំនួន១លាន៣សែនដុល្លារបន្ថែមនៅឆ្នាំ២០០៥ សម្រាប់ដំណើរការកាត់ទោសសម្រាប់ឆ្នាំ២០០៦ ។ តាមសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសបារាំងបានឲ្យដឹងថា "ប្រទេសបារាំងធ្វើបែបនេះ គឺដើម្បីលើក

ទឹកចិត្តប្រទេសជាដៃគូឲ្យខិតខំប្រឹងប្រែងរកជំនួយនិងថវិកាដែលមានស្រាប់សម្រាប់ចាប់ផ្ដើមសវនាការដែលមានរយៈពេល៣ឆ្នាំ» ។

ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៥ ជាការឆ្លើយតបនឹងការស្នើសុំសម្ភារៈដែលទាក់ទងនឹងខ្មែរក្រហម នៅថ្ងៃ១៧ ខែមេសា របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចក្រភពអង់គ្លេសបានផ្ញើឯកសារមកឲ្យមជ្ឈមណ្ឌល ។

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ រដ្ឋាភិបាលជប៉ុនបង្ហាញ ពីទំនាក់ទំនងជាមួយក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ថា ៖

១) វាស្រេចទៅលើការសម្រេចចិត្តរបស់អាជ្ញាធរកម្ពុជា ថាតើបូជនីយដ្ឋានអំពើប្រល័យពូជ-សាសន៍ជើងឯកគួរតែថែរក្សាអភិវឌ្ឍនិងគ្រប់គ្រងដោយរបៀបណា បើពិចារណាទៅតាមអារម្មណ៍របស់ប្រជាជនកម្ពុជាចំពោះទីកន្លែងនេះ ។

២) រដ្ឋាភិបាលជប៉ុនមិនជាប់ពាក់ព័ន្ធនឹងបញ្ហាផ្ដល់សម្បទាន ការពារអភិវឌ្ឍនិងគ្រប់គ្រងបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ជើងឯកទេ ។ គ្មានបុគ្គលឬអង្គភាពណាធ្លាប់បានពិគ្រោះពីបញ្ហានេះឡើយ ។

៣) ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានខ្លះបានឲ្យដឹងថា ការលុបចោលកិច្ចសន្យាអាចធ្វើឲ្យមានផលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចរបស់ជប៉ុននិងកម្ពុជា ។ យ៉ាងណាមិញ វាគ្មានការទាក់ទងរវាងគោលនយោបាយរបស់រដ្ឋាភិបាលជប៉ុនទៅលើជំនួយអភិវឌ្ឍកម្ពុជាជាផ្លូវការនិងការធ្វើសម្បទាននេះទេ ដូចដែលបានអះអាងនៅចំណុច១និង២ ។ ការព្យាយាមភ្ជាប់បញ្ហាទាំងពីរនេះជាមួយគ្នាមានលក្ខណៈឥតប្រយោជន៍និងមិនសមស្រប ។

៤) រដ្ឋាភិបាលជប៉ុនបានផ្ដួចផ្ដើមគំនិតនៅក្នុងសហគមន៍អន្តរជាតិ ហើយនឹងបន្តធ្វើទៅមុខទៀតដើម្បីសម្រេចឲ្យបាននូវសន្តិភាពក្នុងប្រទេសកម្ពុជា និងជួយកសាងឡើងវិញ ព្រមទាំងកិច្ចប្រឹងប្រែងកសាងជាតិរបស់ប្រជាជនកម្ពុជា ។ យើងទាំងអស់គ្នាសុទ្ធតែដឹងពីស្លាកស្នាមដែលខ្មែរក្រហមបន្សល់ទុកនៅក្នុងសង្គមកម្ពុជា ដូច្នេះយើងគួរតែគាំទ្រកិច្ចខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជាដើម្បីឲ្យមានការទទួលស្គាល់តុលាការខ្មែរក្រហមដែលមានបទដ្ឋានអន្តរជាតិ និងជំរុញវិធានច្បាប់កម្ពុជាបន្ថែមទៀត ។

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ ប្រទេសជប៉ុនបាត់បង់»កាសជួយប្រទេសកម្ពុជា ។

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាស្នើឲ្យរដ្ឋាភិបាលជប៉ុនបង្ហាញពីឥរិយាបថខ្លួនចំពោះការលក់ជើងឯកទៅឲ្យក្រុមហ៊ុនឯកជន ។ មួយខែក្រោយមក ស្ថានទូតជប៉ុនចេញសេចក្ដីប្រកាសព័ត៌មានមួយដោយនិយាយថា ១) វាអាស្រ័យទៅលើការសម្រេចចិត្តរបស់អាជ្ញាធរកម្ពុជា ថាតើត្រូវចាត់ចែងវាលពិឃាតជើងឯកដោយរបៀបណា ។ ២) រដ្ឋាភិបាលជប៉ុនមិនជាប់ពាក់

ព័ន្ធនឹងការធ្វើសម្បទាន ហើយបញ្ហានេះមិនទាន់ត្រូវបានយកមកពិគ្រោះទេ ។ ៣) ជំនួយអភិវឌ្ឍរបស់ប្រទេសជប៉ុនមិនមានទំនាក់ទំនងនឹងការធ្វើសម្បទានទេ ។ ៤) រដ្ឋាភិបាលជប៉ុនគាំទ្រតុលាការខ្មែរក្រហមដែលអាចនឹងជំរុញឲ្យមានវិធានច្បាប់នៅក្នុងកម្ពុជា ។

ប្រជាជនកម្ពុជាភាគច្រើនពេញចិត្តយ៉ាងខ្លាំងនូវការគាំទ្ររបស់ជប៉ុនចំពោះតុលាការ ។ ប៉ុន្តែដោយរង់ចាំនូវសេចក្តីប្រកាសព័ត៌មានអំពីកិច្ចសន្យាយូរពេក ស្ថានទូតបានបាត់បង់»កាសជួយជំរុញឲ្យមានវិធានច្បាប់កម្ពុជា ។ ការពន្យារពេលនេះហាក់ដូចជា ជំរុញឲ្យមន្ត្រីរាជការបំភ័យប្រជាជនកម្ពុជាថាជប៉ុននឹងឈប់ផ្តល់ជំនួយដរាបណាក្រុមហ៊ុនជប៉ុនទទួលបានដើងឯក ។

ប្រទេសជប៉ុនអាចប្រើប្រាស់ឥទ្ធិពលគាបសង្កត់ទៅលើមន្ត្រីរាជការចំពោះកិច្ចសន្យានោះ ដើម្បីក្លាយខ្លួនទៅជាដើងឯកក្នុងការគ្រប់គ្រងដ៏មានតម្លាភាព ។ ប៉ុន្តែ ជប៉ុនបែរជាដកខ្លួនឆ្ងាយពីកិច្ចការនេះ ហើយផ្តល់ការជឿជាក់ទៅឲ្យអ្នកដែលលក់មរតកវប្បធម៌ទៅវិញ ។

«បច្ចុប្បន្នទំនាក់ទំនងវៀតណាម-កម្ពុជានៅខេត្តសៀមរាបបានឈប់ដំណើរការ ហើយមន្ត្រីរាជការដែលអនុម័តកិច្ចសន្យាមិនចាំឈ្មោះក្រុមហ៊ុនដែលទិញដីនោះទេ ។ ដូច្នេះហេតុអ្វីបានជារដ្ឋាភិបាលត្រូវទទួលខុសត្រូវ? បន្ទាប់ពីនេះ យើងចាំមើលថា តើនឹងមានអ្វីកើតឡើងនៅវាលពិឃាតដើងឯក ។ យើងទាំងអស់គ្នាបានត្រឹមតែឆ្ងល់ថា តើបូជនីយដ្ឋានប្រល័យពូជសាសន៍មួយណាទៀតនឹងត្រូវបានលក់» ។

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ សហរដ្ឋអាមេរិកនិយាយថានឹងមិនចូលរួមក្នុងសាលាក្តីខ្មែរក្រហមទេ បើសិនជាសាលាក្តីមិនយុត្តិធម៌និងមានឥទ្ធិពលនយោបាយ ។ លោក ព្យែរ រីឆាតប្រូស្ពើ (Pierre Richard Prosper) អគ្គរដ្ឋទូតអាមេរិកទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមបានប្រាប់អ្នកយកព័ត៌មាននៅអំឡុងទស្សនកិច្ចពីរថ្ងៃក្នុងក្រុងភ្នំពេញថា «សហរដ្ឋអាមេរិកចង់ស្ថិតនៅក្នុងជំហរមួយ ដែលយើងអាចគាំទ្របញ្ហានេះដោយផ្នែកនយោបាយនិងហិរញ្ញវត្ថុ» ។ លោកបន្ថែមទៀតថា «អ្វីដែលយើងចង់ចៀសវាងនោះ គឺបញ្ហាខ្លះដែលកើតឡើងក្នុងប្រព័ន្ធតុលាការធម្មតា ដែលត្រូវផ្លាស់ប្តូរទៅជាសាលាក្តីខ្មែរក្រហម ។ សាលាក្តីត្រូវតែគ្មានអំពើពុករលួយ ។ ត្រូវតែគ្មានការគ្រប់គ្រងឬឥទ្ធិពលនយោបាយនិងត្រូវតែមានតម្លាភាព ។

ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ប្រជាជនខ្មែរចំនួន១០០០នាក់ បានជួបជុំគ្នានៅវាល-ពិឃាតជើងឯក ដើម្បីរំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ និងស្នើឲ្យអតីតមេដឹកនាំខ្មែរក្រហមប្រឈមមុខនឹងតុលាការឲ្យបានឆាប់ ។ ញាតិសន្តានជនរងគ្រោះ សិស្សនិស្សិត មន្ត្រីរាជការ និងព្រះសង្ឃបានចូលរួមក្នុងកម្មវិធីនោះ ដែលគេប្រារព្ធធ្វើជារៀងរាល់ឆ្នាំដើម្បី

រំពុកដល់របបកសិកម្ម សមូហភាវូបនីយកម្មម៉ៅ និយមនៅវាលពិឃាតជើងឯក ប៉ែកនិរតីនៃទីក្រុងភ្នំពេញ ។

ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ ឧបនាយរដ្ឋមន្ត្រីកម្ពុជា សុខ អាន ស្នើឲ្យអ្នកការទូតបរទេសនៅទីក្រុងភ្នំពេញជួយកម្ពុជា ក្នុងការចំណាយទឹកប្រាក់មួយចំណែក (១៣,៣លានដុល្លារ) នៃទឹកប្រាក់ចំណាយរបស់សាលាក្តីដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ លោក ស៊ាន វិសុទ្ធ លេខាធិការនៃក្រុមការងារសាលាក្តីរបស់រដ្ឋាភិបាលបាននិយាយថា “ប្រទេសឥណ្ឌា សិង្ហបូរី និងថៃ បានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ។ គាត់បានបន្ថែមទៀតថា សហគមន៍អឺរ៉ុបកំពុងសម្រេចចិត្តថាតើនឹងផ្តល់ប្រាក់១,៣លានដុល្លារដែលបានសន្យាចំពោះអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា» ។

ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៥ អង្គទូតនិងអ្នកតំណាងមកពីស្ថានទូតចំនួន១៣នៅទីក្រុងភ្នំពេញបានធ្វើទស្សនកិច្ចទៅកាន់ទីតាំងអង្គជំនុំជម្រះវិសាមញ្ញដែលបានស្នើឲ្យដាក់នៅកំបូល ។

ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៥ អ្នកជំនួញកម្ពុជាសំខាន់ៗជាច្រើននាក់និយាយថា ពួកគាត់នឹងផ្តល់ប្រាក់ដើម្បីជួយចំណាយលើថវិកាដែលរដ្ឋាភិបាលនៅខ្វះចំនួន១១,៨លានដុល្លារសម្រាប់សាលាក្តីខ្មែរក្រហមប្រសិនបើរដ្ឋាភិបាលធ្វើសំណូមពរជាផ្លូវការ ។ លោក សុខ គង់ អគ្គនាយកក្រុមហ៊ុនសូគីម៉ិចបានមានប្រសាសន៍ថា “ខ្ញុំនឹងបរិច្ចាគថវិកាសម្រាប់សាលាក្តីដើម្បីជួយរដ្ឋាភិបាល ។ គាត់បានបន្ថែមទៀតថា គាត់ជឿថាមិនមែនមានតែគាត់ទេដែលជាអ្នកជំនួញត្រៀមនឹងជួយនោះ ។ លោក គិត ម៉េង ប្រធានក្រុមហ៊ុនរូយ៉ាល់គ្រុបបាននិយាយដូចគ្នាដែរថា “បើសម្តេច ហ៊ុន សែន បង្កើតគោលនយោបាយ ឬសំណូមពរជាផ្លូវការយើងនឹងមិនបដិសេធឡើយ» ។

ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៥ អ្នកនាំពាក្យគណបក្ស សម រង្ស៊ី លោក អ៊ឹង ប៊ុនអាង បានស្នើឲ្យរដ្ឋាភិបាលកម្ពុជារៀបចំការរៃអង្គាសថ្នាក់ជាតិមួយដើម្បីបំពេញថវិកាដែលខ្វះដែលរដ្ឋាភិបាលបាននិយាយថា ជាឧបសគ្គចុងក្រោយនៃការបង្កើតសាលាក្តីដែលគេរង់ចាំមើលជាយូរមកហើយ ។ គាត់បាននិយាយក្នុងសេចក្តីថ្លែងការណ៍មួយថា “ហាក់ដូចថាអ្នកគ្រប់គ្នាបានចូលរួមផ្តល់មូលនិធិសម្រាប់សាលាក្តីខ្មែរក្រហម លើកលែងតែប្រជាជនខ្មែរនៅទីនេះនិងនៅក្រៅប្រទេស» ។

ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៥ នួន ជា សារភាពថាសុខភាព របស់ខ្លួនកំពុងទ្រុឌទ្រោម ហើយសម្ពាធឈាមខ្ពស់កំពុងបង្កបញ្ហាដល់គាត់ ។ ប៉ុន្តែគាត់និយាយថា គាត់កំពុងព្យាយាមថែរក្សាសុខភាពគាត់ក្នុងករណីដែលគាត់ត្រូវកោះហៅទៅបង្ហាញខ្លួននៅសាលាក្តីខ្មែរក្រហមដែលជាប់គាំងយូរមក

ហើយនោះ ។ គាត់បានថ្លែងថា «ខ្ញុំកំពុងថែរក្សាខ្លួននិងសុខភាពរបស់ខ្ញុំ ពីព្រោះខ្ញុំកំពុងត្រៀមខ្លួនទៅកាន់តុលាការ ប៉ុន្តែខ្ញុំមិនដឹងថាខ្ញុំអាចទ្រាំទ្រដល់ពេលណាទេ» ។

ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៥ សម្តេច ហ៊ុន សែន បានបដិសេធសំណើរៃអង្គាសមូលនិធិថ្នាក់ជាតិដើម្បីជួយបំពេញថវិកាដែលខ្វះខាត១១,៨លានដុល្លាររបស់រដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម ។ នេះជាទង្វើមួយដែលអ្នកអង្កេតខ្លះជឿថា អាចបង្កភាពងឿងឆ្ងល់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសាលាក្តីដែលខ្លួនរង់ចាំអស់រយៈពេលដ៏យូរនេះ ។ ជាការផ្តល់យោបល់លើសំណើរៃអង្គាសប្រាក់សម្រាប់សាលាក្តីខ្មែរក្រហមពីការបរិច្ចាគរបស់ប្រជាជនខ្មែរក្នុងប្រទេស ហ៊ុន សែន មានប្រសាសន៍ថា «ខ្ញុំគិតថា សំណើបែបនេះមិនអាចទទួលបានទេ ប្រជាជនខ្មែររកប្រាក់គ្រាន់តែចិញ្ចឹមជីវិតប៉ុណ្ណោះ» ។ លោក ឪម យិនទៀង សមាជិកក្រុមការងារសាលាក្តីខ្មែរក្រហមរបស់រដ្ឋាភិបាលបាននិយាយបន្តថា វាមិនគួរមានការអំពាវនាវទៅអ្នកជំនួញធំៗ ឬអ្នកដទៃទៀតដើម្បីឲ្យគេជួយនោះទេ» ។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ក្រសួងការបរទេសជប៉ុននិយាយថា «ប្រទេសជប៉ុនមិនអាចផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ដើម្បីចំណាយទឹកប្រាក់១១,៨លានដុល្លារ ដែលខ្វះសម្រាប់សាលាក្តីខ្មែរក្រហមរបស់កម្ពុជាទេ ប៉ុន្តែគេកំពុងសិក្សាពីលទ្ធភាពនៃការបង្កើតមូលនិធិតាមរយៈជំនួយទ្វេភាគីរបស់ជប៉ុនមកកម្ពុជា» ។ លោក ហាតស៊ុយហ៊ី តាកា ស៊ីម៉ា (Hatsuhisa Taka Shima) បានប្រាប់អ្នកយកការណ៍នៅក្នុងសន្និសីទកាសែតមួយថា «រដ្ឋាភិបាលជប៉ុនតាមរយៈរដ្ឋមន្ត្រីក្រសួងការបរទេស Nobutaka Machimura ចង់ឃើញសាលាក្តីខ្មែរក្រហមចាប់ផ្តើមឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ ធ្វើដូច្នោះរដ្ឋាភិបាលជប៉ុនស្ម័គ្រចិត្តពិភាក្សាដោយលម្អិតអំពីជំនួបដែលអាចឲ្យជប៉ុនមានមធ្យោបាយផ្តល់ហិរញ្ញវត្ថុតាមរយៈជំនួបទ្វេភាគីរវាងកម្ពុជានិងជប៉ុន» ។

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥ រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ថ្លែងថា ឧបសគ្គមួយទៀតនៃការបង្កើតសាលាក្តីខ្មែរក្រហមត្រូវបានដោះស្រាយជាមួយនឹងសេចក្តីប្រកាសដែលថា កម្ពុជានឹងប្រើប្រាស់មូលនិធិពិសេសមួយដែលបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុនដើម្បីចំណាយលើចំណែកដែលនៅសល់នៃថវិកាសាលាក្តីខ្មែរក្រហម ។ លោករដ្ឋមន្ត្រីបានបន្ថែមថា «រដ្ឋាភិបាលជប៉ុនបានផ្តល់ប្រាក់រួចហើយ ។ យើងនឹងប្រើប្រាស់លុយនេះ ដូច្នេះយើងសង្ឃឹមថាសាលាក្តីខ្មែរក្រហមអាចដំណើរការបានក្នុងពេលឆាប់ៗនេះ» ។

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ សេចក្តីប្រកាសរបស់ លោក ហោ ណាំហុង ដែលថាកម្ពុជានឹងប្រើប្រាស់មូលនិធិពិសេសមួយ ដែលបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុនដើម្បីចំណាយលើចំណែកដែលនៅសល់នៃថវិកាសាលាក្តីខ្មែរក្រហមបានបង្កភាពភ្ញាក់ផ្អើលដល់ស្ថានទូតជប៉ុននៅទីក្រុងភ្នំពេញ ។

មន្ត្រីកិច្ចការនយោបាយរបស់ស្ថានទូតនេះ Fumio Goto បានមានប្រសាសន៍ថា កម្មវិធីជំនួយទ្វេភាគីរបស់ជប៉ុនមិនអាចចេញការចំណាយទាំងអស់របស់កម្ពុជាទេ ហើយគាត់បានសុំឲ្យប្រទេសដទៃរួមចំណែកផងដែរ ។ គាត់បានបន្ថែមថា «ដោយសារមិនមែនមានតែជប៉ុនទេ ដែលជួយសាលាក្តីខ្មែរក្រហម ដូច្នេះយើងអាចយល់បានថា ឥឡូវរាជរដ្ឋាភិបាលកម្ពុជាត្រៀមខ្លួនអំពាវនាវដល់ប្រទេសផ្តល់ជំនួយទាំងអស់ដើម្បីជួយរួមចំណែកដល់កម្ពុជាដែលត្រូវចំណាយផង» ។

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ០០៥ ប្រទេសអាល្លឺម៉ង់ជំរុញឲ្យសាលាក្តីខ្មែរក្រហមខិតទៅរកការចាប់ផ្តើម ដោយប្រកាសបរិច្ចាគប្រាក់១៩លានដុល្លារបន្ថែមទៀតសម្រាប់ថវិកាចំណាយ៥៦,៣លានដុល្លាររបស់សាលាក្តី ។

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អ្នកការទូតម្នាក់បាននិយាយដោយមិនបញ្ចេញឈ្មោះថា អង្គការសហប្រជាជាតិយល់ព្រមយកអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទនៅជាយក្រុងភ្នំពេញដាក់ជាទីតាំងសាលាក្តីខ្មែរក្រហម ។ ការសម្រេចចិត្តនេះ ត្រូវបានធ្វើឡើងនៅក្នុងការប្រជុំសម្ងាត់មួយនៅទីក្រុងញូវយ៉ក កាលពីថ្ងៃទី៣០ ខែមិថុនា រវាងអង្គការសហប្រជាជាតិ និងអ្នកតំណាងមកពីប្រទេសដែលជាប់ពាក់ព័ន្ធនឹងសាលាក្តីនេះ ។

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ០០៥ អង្គការសហប្រជាជាតិស្នើឲ្យប្រទេសជាសមាជិកប្រគល់ឈ្មោះចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិដែលត្រូវបានតែងតាំងសម្រាប់សាលាក្តីខ្មែរក្រហម ។ លេខាធិការដ្ឋានអង្គការសហប្រជាជាតិបានផ្ញើលិខិតមួយច្បាប់ទៅប្រទេសជាសមាជិកនៅថ្ងៃទី៣០ ខែមិថុនា ជាមួយការតែងតាំង សម្រាប់តំណែងសរុប៩ ពីសហគមន៍អន្តរជាតិដែលត្រូវប្រគល់ត្រឹមថ្ងៃទី២៩ ខែសីហា ។ នីកូឡា មីសែល អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលខុសត្រូវកិច្ចការច្បាប់បានសរសេរថា តាងនាមឲ្យអគ្គលេខាធិការ កូហ្វី អាណាន់ ខ្ញុំមានកិត្តិយសស្នើសុំឲ្យរដ្ឋាភិបាលស្នើឈ្មោះអ្នកដែលអគ្គលេខាធិការអាចតែងតាំងបាន ។ លិខិតនោះត្រូវបានសរសេរថា មន្ត្រីតុលាការអន្តរជាតិនឹងត្រូវការលុយ១២៩ ។៤០០ដុល្លារក្នុងមួយឆ្នាំដោយគណនាលើរយៈពេលដែលមន្ត្រីទាំងនោះធ្វើការងារជាក់ស្តែង ។ មន្ត្រីទាំងនោះនឹងចាប់ផ្តើមនៅពេលផ្សេងគ្នានិងបម្រើសម្រាប់អំឡុងពេលផ្សេងគ្នាផ្អែកលើដំណាក់កាល ដូចជាដំណាក់កាលស៊ើបអង្កេតការកាត់ទោស និងការប្តឹងនៃសាលាដែលពួកគេចូលរួម ។

ខែមិថុនា ២០០៥ លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាស្នើឲ្យរដ្ឋាភិបាលអាស៊ានចូលរួមបន្ថែមទៀតនៅក្នុងដំណើរការសាលាក្តីខ្មែរក្រហម (ដោយផ្តល់ជំនួយដែលត្រូវការខ្លាំងដូចជាជំនួយបច្ចេកទេស ការផ្តល់ឯកសារ ដោយផ្តល់ឯកសារដែលពាក់ព័ន្ធនឹងខ្មែរក្រហមទៅសាលាក្តី)

ការប្រឹក្សាជួយប្រជាជនដែលរងការឈឺចាប់ដោយសារជំងឺបាក់ស្បាត) កុំព្យូទ័រ មធ្យោបាយដឹកជញ្ជូន រថយន្តដឹកទំនិញធំៗ ឬរថយន្តក្រុងតូចៗ សម្រាប់ដឹកប្រជាជនពីជនបទមកចូលរួមការកាត់ក្តីនៅទីក្រុង) និងវិទ្យុ ។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ មន្ត្រីរដ្ឋាភិបាលម្នាក់និយាយនៅក្នុងសន្និសីទស្តីពីសាលាក្តីថា "រដ្ឋាភិបាលនៅកំពុងរង់ចាំអ្នកផ្តល់ជំនួយអន្តរជាតិដើម្បីបំពេញថវិកាជាចំណែករបស់កម្ពុជាសម្រាប់សាលាក្តីខ្មែរក្រហមដែលនៅខ្វះ១១,៨លានដុល្លារ និងដើម្បីអង្គការសហប្រជាជាតិតែងតាំងតំណាងអ្នកសម្របសម្រួលមុនពេលដំណើរការទៅមុខ ។ ស៊ាន វិសុទ្ធ លេខាធិការនៃក្រុមការងារសាលាក្តីខ្មែរក្រហមរបស់រដ្ឋាភិបាលបាននិយាយថា "ពេលណាយើងទទួលបានព័ត៌មានពីអង្គការសហប្រជាជាតិអំពីអ្នកដែលនឹងមកកាន់តំណែងជាតំណាងអ្នកសម្របសម្រួល ពេលនោះកម្ពុជានឹងស្វែងរកអ្នកសម្របសម្រួលរបស់ខ្លួន ។ យើងកំពុងរង់ចាំអង្គការសហប្រជាជាតិ" ។ អង្គការសហប្រជាជាតិបានបិទប្រកាសជ្រើសរើសតំណាងអ្នកសម្របសម្រួលនៅខែមេសា ។ ការដាក់ពាក្យផុតកំណត់នៅថ្ងៃទី៨ ខែឧសភា ។ យោងតាមមន្ត្រីទាំងនោះ អង្គការសហប្រជាជាតិបានទទួលពាក្យសុំជាង១០០ច្បាប់ ។ អគ្គរាជទូត ជប៉ុន ហ្វូមីអាគី តាកាហាស៊ី (Fumiaki Takahashi) បានមានប្រសាសន៍នៅឯសន្និសីទដែលរៀបចំឡើងដោយសាកលវិទ្យាល័យកម្ពុជាថា វាជាដំណាក់កាលចុងក្រោយ នៃការសម្រេចថានរណានឹងកាន់ការងារនោះ ។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ អ៊ាន ភាសិន (Ian Pearson) រដ្ឋមន្ត្រីការិយាល័យបរទេសសម្រាប់កិច្ចការពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេសបាននិយាយបន្ទាប់ពីជំនួបជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន ពិភាក្សាពីសាលាក្តីថា "ចក្រភពអង់គ្លេសនឹងបរិច្ចាគប្រាក់ប្រមាណ២,៦លានដុល្លារដល់សាលាក្តីខ្មែរក្រហមដែលគេទន្ទឹងរង់ចាំជាយូរមកហើយ ។ យើងបាននិយាយហើយថា យើងប្តេជ្ញាផ្តល់ប្រាក់ ២,៦លានដុល្លារសម្រាប់ពេល៣ឆ្នាំខាងមុខទៅឲ្យភាគីអន្តរជាតិរបស់សាលាក្តី" ។

ថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ ហារុហិស្សា ហាន់ដា (Haruhisa Handa) អ្នកបរិច្ចាគ មេដឹកនាំសាសនា អ្នកជំនាញពាណិជ្ជកម្ម តាមស្ទីលផ្ទាល់ខ្លួន និងជាអ្នកនិពន្ធដែលមានឈ្មោះថា តូស្យុ ហ្វុកាមី (Toshu Fukami) ប្រកាសផ្តល់មូលនិធិរំឭកនិងសង្ជឹងចិត្ត ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមចំនួន១,៣លានដុល្លារ ។ គាត់បាននិយាយថា " ហារុហិស្សា ហាន់ដា ដែលជាស្ថាបនិកសមាគមកីឡាកូនហ្គោលជនពិការជប៉ុននឹងផ្តល់មូលនិធិ៣០០.០០០ដុល្លារ ចំណែកឯអង្គការសុខុមាលភាពរបស់គាត់ឈ្មោះ វើល មេត (World Mate) នឹងចេញចំណាយថវិកាដែលនៅសល់ ។ អ្នកដែលនៅរស់ពីរបបនេះនឹងត្រូវបានហៅឲ្យទៅដាក់ពាក្យសុំថវិកាពីមូលនិធិនេះ ដែលមានគោលបំណងផ្តល់ប្រាក់១០០ដុល្លារក្នុងមួយ

គ្រួសារសម្រាប់គ្រួសារចំនួន១០.០០០។ ហារុហិស្សា ហាន់ដា បាននិយាយថា «បើខ្ញុំទទួលប្រាក់បរិច្ចាគច្រើនដាងនេះ ខ្ញុំអាចផ្តល់ប្រាក់ដល់ប្រជាជនច្រើនជាងនេះដែរ» ។

ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៥ មុនពេលបញ្ចប់ដំណើរការតែងតាំងសម្រាប់ការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាទៅអង្គជំនុំជម្រះវិសាមញ្ញថ្មីមិនដល់មួយខែផង អង្គការលើកលែងទោសអន្តរជាតិកំពុងស្នើឲ្យគ្រប់រដ្ឋទាំងអស់តែងតាំងបេក្ខជនដែលសក្តិសមបំផុតទៅអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយសារតែចំណុចខ្សោយដ៏ធ្ងន់ធ្ងរនៅក្នុងប្រព័ន្ធតុលាការជាតិ អង្គការលើកលែងទោសអន្តរជាតិត្រូវបានប្រានចោលដោយសម្រេចតែងតាំងចៅក្រមកម្ពុជាភាគច្រើនដើម្បីបម្រើការងារក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រម១១រូបក្នុងចំណោម១៩រូប និងសហព្រះរាជអាជ្ញាម្នាក់ក្នុងចំណោម២នាក់ជាជនជាតិខ្មែរ ។ អង្គការលើកលែង ទោសអន្តរជាតិគិតឃើញថា ប្រព័ន្ធតុលាការកម្ពុជាបន្តចុះខ្សោយហើយប្រឈមមុខនឹងសម្ពាធនយោបាយជាពិសេសករណីសំខាន់ ។ ពេលថ្មីៗនេះវាមិនអាចធានាថាសាលាក្តីនឹងធ្វើឡើងស្របទៅតាមច្បាប់អន្តរជាតិ និងស្តង់ដារយុត្តិធម៌បានទេ ។